ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-2013, 10:26
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី១៩៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ស៊ីម៉ុន មេសិនប៊ឺជ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក឴ ឃីត រេយ៍ន័រ*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អង់តា ហ្គីសសេ (*Ms. Anta GUISSE*)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

(*Ms. Elisabeth SIMONNEAU-FORT*)

លោក ឡៅ ជុនធី

លោកស្រី បេនី យេ (*Ms.Beini YE*)

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អង់តា ហ្គីសសេ | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |
| នូ ម៉ៅ (TCW-801) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នូ ម៉ៅ** (TCW-801)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២
សួរដោយលោក ឃីត វេយ៍ន័រ ផ្ដើមពី....................ទំព័រ ៥
សួរដោយលោក ឡៅ ជុនធី ផ្ដើមពី....................ទំព័រ ៤៦
សួរដោយលោកស្រី បេនី យេ ផ្ដើមពី ....................ទំព័រ ៥២
សួរដោយលោក សុន អរុណ ផ្ដើមពី ....................ទំព័រ ៥៨
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៦៣

E1/209.1

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ តាមកាលវិភាគបានកំណត់គឺអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-801។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួន ដែលនៅពីខាងក្រោមសាលសវនាការ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដំបូង ដោយមានបញ្ហាសុខភាព។

តាមកាលវិភាគសម្រាប់សវនាការនៅថ្ងៃនេះនឹងស្តាប់សក្ខីកម្មសាក្សី TCW-801 ហើយសាក្សីនេះ បានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ ហើយគាត់បានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយ កាលពីថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៣។

សាក្សីនេះនឹងមានមេធាវីប្រឹក្សា លោក ម៉ម រិទ្ធា។ សម្រាប់សវនាការនៅថ្ងៃនេះ មិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ហើយនិងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៣៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីលោកសាក្សី តើលោកឈ្មោះអី? លោកសាក្សីកុំអាលទាន់ឆ្លើយតប រង់ចាំក្បាលមីក្រូហ្វូននៅចំពោះលោកហ្នឹងប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមនៅក្បាលមីក្រូហ្វូន ឬក៏នៅប៊ូតុងចុចនេះ លោកចាប់ផ្តើមនិយាយ ទើបសំឡេងរបស់លោកចូលទៅប្រព័ន្ធចែកចាយសំឡេង ហើយសម្រាប់ភាគី សាធារណជន ហើយនិងដល់ក្រុមអ្នកបកប្រែភាសា ដែលត្រូវបកប្រែរបស់លោកជាពីរភាសាផ្សេងទៀត ភាសាបារាំង និងភាសាអង់គ្លេស។ សូមលោកឆ្លើយ!

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំបាទឈ្មោះ នូ ម៉ៅ ហៅ មោក សូមគោរពលោកប្រធាន។

**ស៖** បាទ អរគុណ ហើយលោក ម៉ៅ។ តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** អាយុ៧៨ឆ្នាំ។

**ស៖** អរគុណ។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា? ទីកន្លែងកំណើតរបស់លោកៗកើតនៅទីកន្លែងណា?

**ឆ៖** ឃុំយុទ្ធសាមគ្គី ពីដើមឈ្មោះ ឃុំជើងរាស់ តែឥឡូវហ្នឹងដាក់ឃុំយុទ្ធសាមគ្គី។

**ស៖** ស្រុកអី? ខេត្តអី? លោក ម៉ៅ។ លោក ម៉ៅ ឆ្លើយ ឃុំហ្នឹងគឺនៅក្នុងស្រុកអី? ខេត្តអី?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកឆ្លើយម្តងទៀត។ អំមិញហ្នឹង គឺសំឡេងរបស់លោកមិនបានចូលទៅប្រព័ន្ធចែកចាយសំឡេងទេ ជាកន្លែងកំណើតរបស់លោកហ្នឹង គឺនៅក្នុងស្រុកអី? ខេត្តអី?

**ឆ៖** នៅខេត្តកំពង់ស្ពឺ ស្រុកឧដុង្គ ឃុំយុទ្ធសាមគ្គី។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃ លោកនៅកន្លែងណា?

**ឆ៖** ស្រុកឧដុង្គ ហើយនិងឃុំយុទ្ធសាមគ្គី ភូមិត្រពាំងធំ។

[០៩:០៩:២៦]

**ស៖** តើលោកប្រកបមុខរបរអីសព្វថ្ងៃនេះ?

**ឆ៖** មុខរបរកសិករ ខាងដើមនោះឡើងត្នោត ធ្វើស្រែ។

**សៈ** តើឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី?

**ធៈ** ឈ្មោះ នូ។ ខ្ញុំឈ្មោះ នូ ម៉ៅ តែក្នុងនោះនៅក្នុងការរស់នៅ នៅក្នុងភូមិត្រពាំងធំ។

**សៈ** ចុះម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ធៈ** ហួន ប៊ុត។

**សៈ** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ធៈ** ប្រពន្ធឈ្មោះ ឡាច ណន កូនមានប្រាំពីរនាក់។

**សៈ** អរគុណលោក នូ ម៉ៅ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីរនាក់ដែរគឺលោក នួន ជា និងលោក ខៀវ សំផន។ ហើយថាលោកបានស្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០១៣។ តើពិតមែនដែរឬទេ?

[០៩:១១:៥៤]

**ធៈ** ពិតមែន ដែលខ្ញុំបានមកស្បថនៅលោកតាដំបងដែក។

**សៈ** អរគុណលោក នូ ម៉ៅ ។ ឥឡូវនេះអង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិនិងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញ។ នាពេលនេះក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរឬក៏ការសុំឱ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច លោក នូ ម៉ៅ ក្នុងនាមលោកជាសាក្សីត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ ហើយលោកត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះឬក៏បានធ្វើការអង្កេតនៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងសំណួរ ដែលសួរចំពោះលោកនូវព្រឹត្តិហេតុទាំងឡាយ ឬក៏ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ។

លោក នូ ម៉ៅ តើរយៈពេលកន្លងមកនេះតើលោកដែលផ្ដល់នូវកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

[០៩:១៣:៤៦]

**ឆ៖** ខ្ញុំបានសម្ភាសជាមួយកាសែតបរទេស។

**ស៖** អរគុណ។ តើលោកចងចាំទេថា លោកផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកកាសែតបរទេសហ្នឹង តើលោកផ្តល់កិច្ចសម្ភាសន៍ហ្នឹងនៅទីកន្លែងណា? ហើយនៅក្នុងឆ្នាំណាដែរ លោកចងចាំបានទេ?

**ឆ៖** ការចងចាំនោះវាអស់រយៈយូរហើយ ជាង៣០ឆ្នាំហើយ វាបាត់បង់ភ្លេចបាត់ចំណែកណាមួយ ខ្ញុំចាស់ហើយវាចេះតែភ្លេច ហើយការចងចាំនោះវាបាត់បង់។ អ៊ីចឹងសូមអង្គប្រជុំ លោកប្រធានអធ្យាស្រ័យដល់ខ្ញុំថា ក្តាប់មិនបានជុំទេ ដូចប្រាប់ពីខាងដើមដោយបាត់ម្ចាស់ការស្មារតី សូមអធ្យាស្រ័យឲ្យខ្ញុំផង។

**ស៖** អរគុណ។ ហើយលោក ម៉ៅ លោកអំមិញបានឆ្លើយថា លោកបច្ចុប្បន្ននេះ គឺឈ្មោះ នូ ម៉ៅ ហៅ មោក។ សំណួរសួរថា តើលោកប្រើឈ្មោះ នូ ម៉ៅ ហ្នឹងចាប់ពីពេលណាមក? ហើយឈ្មោះ មោក ហ្នឹងលោកប្រើនៅពេលណាដែរ?

**ឆ៖** ឈ្មោះ ម៉ៅ នាមពីខាងដើមហ្នឹងដាក់ នូ ម៉ៅ។ ក្រោយមកនៅក្នុងអង្គភាពដែលធ្វើការនៅក្នុងឃុំមាន ម៉ៅ ពីរនៅក្នុងគណៈកម្មការឃុំដែលការរៀបចំ ហើយខ្ញុំគ្រាន់តែជានៅក្រោមអាណាព្យាបាលរបស់ឃុំ គ្រាន់តែសម្រាប់គេប្រើប៉ុណ្ណោះ។ សូមអស់ប៉ុណ្ណឹង។

[០៩:១៦:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី ហើយតំណាងសហព្រះរាជអាជ្ញា រួមនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត រេយ៍ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ អរុណសួស្តីមេធាវីការពារក្តី ភាគីទាំងអស់ និងជាពិសេសសូមសួស្តីលោក នូ ម៉ៅ។ ខ្ញុំឈ្មោះ ឃីត រេយ៍ន័រ ខ្ញុំជាតំណាងសហព្រះរាជអាជ្ញាមួយរូបនៅក្នុងរឿងក្តីនេះ។

**សៈ** លោកបានជម្រាបជូនអង្គជំនុំជម្រះរួចមកហើយថា លោកចាំថា លោកបានធ្លាប់ផ្តល់សម្ភាសទៅដល់កាសែតអន្តរជាតិមួយរូបយូរមកហើយ។ នៅក្នុងសំណុំរឿងឯកសារតុលាការ យើងមានឯកសារ D313/1.2.405។ ឯកសារនេះមានប្រាំបួនទំព័រ ដែលជាឯកសារសរសេរដោយដៃៗ របស់បុគ្គលមួយរូបជាជនបរទេសឈ្មោះ ប៉ែន ឃៀរនិន។ ឯកសារប្រាំបួនសន្លឹកនោះ មានឈ្មោះរបស់លោកដែលគេដាក់ឈ្មោះថា នូ ម៉ុក ហើយក៏មានដាក់ថា ឧដុង្គថ្ងៃទី២៦ ខែសីហា ឆ្នាំ(១៩)៨១ នៅលើនោះផងដែរ។ តើលោកនៅចាំទេ? លោកនឹកឃើញថា លោកបានផ្តល់សម្ភាសទៅដល់អ្នកកាសែតបរទេសម្នាក់ដែរឬទេ នៅក្នុងថ្ងៃខែឆ្នាំនោះ ដូចដែលបាន ខ្ញុំបានបញ្ជាក់នេះ?

[០៩:១៩:១៥]

**លោក នូ ម៉ោះ**

**ឆៈ** ខ្ញុំបានសម្ភាសក្នុងកាសែត នៅសាលាស្រុកឧដុង្គម្តង។ ម្តងទៀតមុន -- អត់ចាំ -- នៅក្នុងសង្គ្រាមហ្នឹងគាត់សម្ភាសខ្ញុំម្តង។ កាលណោះនៅក្នុងសមរភូមិ ហើយគណៈកម្មការឃុំឲ្យខ្ញុំទៅដឹកនាំប្រជាជនចូលនៅក្នុងសមរភូមិយកបាយឲ្យកងទ័ព ហើយសែងរបួសចេញមកក្រៅ យុវជន យុវនារី។ អ៊ីចឹងគាត់បានចូលមកជួបខ្ញុំ ខាងយោធាហ្នឹងយកមកឲ្យខ្ញុំៗ ក៏ភ័យអ៊ីចេះ ភ័យថា ពួកខ្មែរក្រហមមិនដែលទុកទេ ពួកកាសែតអីក៏ដោយ។ អ៊ីចឹងថា បើបានជួបខ្ញុំគឺពិសេសហើយ។ ពីលើកមុន គេវ៉ៃនៅស្រុកឧដុង្គជម្លៀសប្រជាជន ទាំងឈ្លើយសឹក ទាំងប្រជាជនទៅៗលិចទៅ ហ្នឹងហើយទៅលិចហ្នឹងហើយទៅរហូតស្រុកថ្កូងហ្នឹង តែមិនដឹងជាទៅដល់ណា។ អ៊ីចឹង វាបាត់ប្រជាជនទៅនៅរស់នៅខាងស្រុកថ្កូងហ្នឹង។ ខ្ញុំមិនបានដឹងថាយ៉ាងម៉េចយ៉ាម៉ាទេ។ អ៊ីចឹងខ្ញុំនៅក្នុងសមរភូមិ -- ឥឡូវនិយាយដូចបកមកវិញ -- នៅក្នុងសមរភូមិហ្នឹង ខ្ញុំក៏សុំឲ្យរត់ចេញ ហ្នឹងហើយរត់ចេញ។ ខ្ញុំក៏ថា "ឥឡូវទៅទិសខាងត្បូង"។ ហើយកប៉ាល់ហោះកំពុងតែទម្លាក់ វ៉ៃគ្រាប់បែកបេ កូនឃ្លី ប៊ុមប៊ី ទម្លាក់ ហ្នឹងខាងយន្តហោះ នៅ -- អ៊ីចឹងរបួសសែងមកក្រោយ បាយយុវនារីបុកចូលទៅខាងសមរភូមិ។ អ៊ីចឹងខ្ញុំក៏ថាឥឡូវជួបខ្ញុំពិសេសហើយ ឥឡូវសុំខ្ញុំឲ្យធ្វើយ៉ាងម៉េចដល់ទឹកដីខាង លន់ នល់ អ៊ីចឹងហើយ អាហ្នឹងរស់។ ហើយខ្ញុំក៏ជូនគាត់ទៅៗ ក៏រត់ៗទៅចូលទឹកដីខាងទ្រង់ ច័ន្ទរង្សី អ្នកដែលវ៉ៃគ្នាហ្នឹង។

[០៩:២២:៣៥]

ក្រោយមក ខ្ញុំ គេតាមដានៗថា ខ្ញុំហ្នឹងពង្វាងពួកអាកាសែតអាមេរិកាំង ជាប់ពិរុទ្ធ ទម្រាំតែនឹងដោះស្រាយចេញ។ ខ្ញុំថារឿងនេះវាជារឿងសមរភូមិវ៉ៃគ្នា មិនដឹងជាទៅឯណាមកឯណា ឥឡូវគេរត់

បាត់ទៅហើយឲ្យខ្ញុំទៅហៅយកមកវិញកាត់ទោស? ខ្ញុំអត់ទេ ខ្ញុំអត់មានទទួលខុសត្រូវពីរឿងហ្នឹងទេ ត្បិតអីកាសែតតែចូលសង្គ្រាមអត់ខ្លាចស្លាប់ អត់ខ្លាចអីទេ អ្នកទៅយកព័ត៌មាន នេះគ្រាន់តែថាប៉ុណ្ណឹង។ អ៊ីចឹងក៏ចប់ទៅ។ ក្រោយទៀតក៏គេចេះតែតាមដានពីរឿងខ្ញុំ។ រួចដល់ក្រោយមកទៀតហ្នឹង គាត់ឈ្មោះ ខែន ម៉េចទេ ខ្ញុំភ្លេចឈ្មោះគាត់ទៅ។ តែគ្រាន់តែមុខមាត់គាត់ហ្នឹងខ្ញុំស្គាល់ ខ្ញុំបើកមើលឲ្យបន្តិច។

**ស៖** សូមអរគុណ លោក នូ ម៉ៅ។ ខ្ញុំមិនចង់ផ្ដោតសួរលោកលើការសម្ភាសនោះទេ។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានសាក្សីបានលើកឡើងនូវរូបថតមួយសន្លឹក ដូច្នេះប្រហែលជាអាចមានភាពពាក់ព័ន្ធ ដូច្នេះខ្ញុំអាចសូមសួរអំពីឯកសារនេះដែរឬទេ?

[០៩:២៤:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អាចសួរបាន។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក នូ ម៉ៅ ខ្ញុំឃើញលោកលើកឡើងនៅក្នុងបន្ទប់សវនាការនេះ គឺមានរូបថតមួយសន្លឹកស-ខ្មៅ។ ខ្ញុំសូមសួរលោក ហេតុអ្វីលោកយករូបថតនេះមួយសន្លឹកមកជាមួយលោកនៅក្នុងបន្ទប់សវនាការនេះ? ហើយតើនរណាគេនៅក្នុងរូបថតនោះ?

[០៩:២៤:៤៥]

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំ -- ប៉ែន ឈ្មោះ ប៉ែន យៀរ និន -- អើគ្រាន់តែខ្ញុំឃើញថា គាត់ពិតជាមកសម្ភាសជាមួយខ្ញុំ ថាឈ្មោះ ប៉ែន យៀរនិន។ នេះខ្ញុំគ្រាន់តែស្គាល់មុខគាត់ដែរ តែគ្រាន់ចង់ដឹងឈ្មោះឲ្យវាច្បាស់ បានឲ្យគេសរសេរដាក់ឲ្យទៅហ្នឹង។ មានអីទៀតទេ? ខ្ញុំអ្នកបាត់បង់ដែរ។ សូមអធ្យាស្រ័យផង ខុសត្រូវអីយ៉ាងម៉េច ខ្ញុំគ្រាន់តែជាសម្រាប់តែ *(ឮមិនច្បាស់)* នៅក្នុងសម័យនោះ តែមិនដែលសម្លាប់ប្រជាជន មិនដែលបានពាក់ព័ន្ធយ៉ាងម៉េចនៅក្នុងខ្មែរក្រហមនេះ។ រឿងខ្មែរក្រហមដាក់ឈ្មោះថា ក្រហមៗហ្នឹង គឺឈាមប្រឡាក់ដៃប្រជាជនតែម្ដង ការសម្លាប់។ អានេះជាទស្សនៈខ្ញុំ។ ហៅថាខ្មែរក្រហម លាបពណ៌គ្នាសម្លាប់គ្នាអត់រើសមុខ។ ដូច្នេះ ខ្ញុំក្លាប់មិនបានដែរទេ តែគ្រាន់ថាឈ្មោះថា ខ្មែរក្រហមហ្នឹង គឺក្រហមហ្នឹងគឺប្រឡាក់ដៃតែម្ដង ឈាមប្រឡាក់ដៃ រវាងប្រជាជននិងប្រជាជនឯងហ្នឹង។ ហ្នឹងសូមជូនយោបល់

អស់ប៉ុណ្ណឹង។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ដោយសារតែសាក្សី នូ ម៉ៅ បានបញ្ជាក់ថាគាត់ផ្ដល់កិច្ចសម្ភាសន៍ឱ្យទៅលោក ប៉ែន យៀរនិន ហើយក៏បានបង្ហាញរូបថតមួយសន្លឹករបស់ ប៉ែន យៀរនិន ហើយនៅពេលដែលគាត់លើករូបថតនេះ គឺគាត់ចង់បញ្ជាក់ប្រាប់ឈ្មោះឱ្យបានច្បាស់លាស់។ ហើយកិច្ចសម្ភាសន៍នេះ គឺបានធ្វើឡើង៣១ឆ្នាំកន្លងមកហើយ។ ដូច្នេះសាក្សីនេះ ដូចនឹងសាក្សីដទៃទៀតគួរតែទទួលបានឯកសារពាក់ព័ន្ធដែលខ្ញុំចង់ផ្ដល់ឱ្យនេះ ដើម្បីឱ្យយើងសួរសំណួរទាំងឡាយដែលពាក់ព័ន្ធនោះឱ្យគាត់បានយល់។ ដូច្នេះសូមអនុញ្ញាតពីលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

[០៩:២៧:៤២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព ហើយនិងភាគីទាំងអស់ជាទីគោរព។ ខ្ញុំគិតថាមានការទៅមុខលឿនបន្តិចហើយចំពោះខ្ញុំ។ មុននឹងពេលដែលបង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោកសាក្សីនេះ ខ្ញុំគិតថាត្រូវតែមានសំណួរមួយចំនួនត្រូវសួរសិន។ ត្រូវចង់ដឹងថាតើគេកត់កំណត់ហេតុនោះក្នុងពេលណា? ក្នុងកាលៈទេសៈណា? ហើយត្រូវពិនិត្យមើលចំណុចទាំងអស់នេះឡើងវិញជាបឋម។ អ៊ីចឹង ខ្ញុំគិតថាការអនុវត្តចំពោះតុលាការយើងនេះ ត្រូវតែបង្កើតជាមូលដ្ឋានសិនមុននឹងបង្ហាញឯកសារហ្នឹងសួរលោកសាក្សីសិន ថាតើគាត់ស្គាល់ឯកសារនេះ ឬក៏អត់ ឬក៏ឱ្យគាត់ពិនិត្យឯកសារជាមុនសិន។ អ៊ីចឹងខ្ញុំសូមជំទាស់ក្នុងការបង្ហាញឯកសារនេះភ្លាម មុននឹងចោទសំណួរបឋមមួយចំនួន លោកប្រធាន។ សូមអរគុណ។

[០៩:២៨:៥៥]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំពេញចិត្តនឹងសួរសំណួរបឋម ក៏ប៉ុន្តែយើងត្រូវចងចាំថា លោក នូ ម៉ៅ បានជម្រាបជូនតុលាការរួចមកហើយ ហើយហេតុការណ៍នេះបានកើតឡើងជាង៣០ឆ្នាំកន្លងមកហើយ។ ហើយមិនអាចឱ្យគាត់ចាំគ្រប់ចំណុចទាំងអស់នោះទេ។ គាត់ថាគាត់ចាស់ ហើយការចងចាំរបស់គាត់

ហ្នឹងក៏ភ្លេចភ្លាំងមិនសូវល្អផងដែរ។ ដូច្នេះនៅពេលនេះ ខ្ញុំសូមសួរសំណួរបឋមមួយចំនួនសិន បន្ទាប់មកខ្ញុំនឹងលើកឡើងសំណើររបស់ខ្ញុំសាជាថ្មីជូនអង្គជំនុំជម្រះ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក នូ ម៉ៅ នៅពេលដែលលោក ប៉ែន យៀវនិន បានធ្វើដំណើរទៅធ្វើការ ទៅសម្ភាសលោកនោះ តើលោកនៅចាំទេ គាត់ទៅតែម្នាក់ឯងទេ ឬក៏គាត់ទៅរួមជាមួយនឹងជនបរទេសម្នាក់ទៀតទៅជាមួយគាត់?

[០៩:២៩:៥៤]

**លោក នូ ម៉ៅ៖**

**ឆ៖** ក្រោយមក គាត់ទៅស្រាវជ្រាវនៅកន្លែងស្រុក ស្រុកឧដុង្គ។ ហើយកាលណោះ វាចង់ចូលចោទប្រកាន់ដែរ គេចោទប្រកាន់។ អ៊ីចឹងបាន មិនបានដាក់គុក ដាក់ច្រវាក់អីទេ តែគ្រាន់គេឲ្យខ្ញុំចិញ្ចឹមជ្រូក ចិញ្ចឹមទា ចិញ្ចឹមមាន់ នៅក្នុងស្រុកឧដុង្គ។ អ៊ីចឹងគាត់អញ្ជើញទៅស្រុកឧដុង្គដល់ហ្នឹង។

**ស៖** លោក នូ ម៉ៅ ខ្ញុំអធ្យាស្រ័យ ខ្ញុំសូមផ្តោតការដែល ពេលដែលលោកសម្ភាសជាមួយនឹង ប៉ែន យៀវនិន នោះ។ ឯកសារគាត់នោះ គឺថាបានលើកឡើងថា ការសម្ភាសនោះ គឺធ្វើឡើងក្រោយពេលវៀតណាមចូលលុកលុយ គឺបានន័យថា ២ឆ្នាំក្រោយវៀតណាមចូល។ សម្ភាសនៅក្នុងឆ្នាំ១៩៨១ ថ្ងៃ២៦ សីហា ឆ្នាំ១៩៨១។ តើពិតដែរឬទេ ថាថ្ងៃ២៦ ខែសីហា ឆ្នាំ៨១ នេះ គឺជាថ្ងៃដែលលោកផ្តល់កិច្ចសម្ភាសន៍ឲ្យលោក ប៉ែន យៀវនិន។ តើត្រឹមត្រូវដែរឬទេ?

[០៩:៣១:២១]

**ឆ៖** អាហ្នឹងត្រឹមត្រូវ ខ្ញុំទទួល។ គាត់ទៅឡានពីរ។ ទៅដល់សួររកមុខខ្ញុំថា ពីឧដុង្គ ទៅឃុំជើងរាស់ហ្នឹងដីប៉ុន្មានគីឡូ? អ៊ីចឹងខ្ញុំក៏នៅហ្នឹងដែរ នៅកន្លែងស្រុកហ្នឹង។ អ៊ីចឹងផ្នែកខាងស្រុកហ្នឹងសួរ--

**ស៖** នៅពេលដែល ប៉ែន យៀវនិន ជិះឡាន មានឡានពីរទៅសម្ភាសលោកនៅទីនោះ។ តើគាត់ទៅតែម្នាក់ឯង ឬក៏មានមនុស្សផ្សេងទៀតទៅរួមដំណើរជាមួយគាត់? គាត់ទៅតែម្នាក់ឯងទេ ឬក៏គាត់ទៅជាមួយគេ តាមអ្វីដែលលោកចាំនោះ?

**ឆ៖** គាត់ដែលទៅសម្ភាសខ្ញុំហ្នឹង ឡានពីរ។ មានស្រីក៏មាន ប្រុសក៏មាន។ តែមុននឹងសម្ភាសជាមួយខ្ញុំហ្នឹង គាត់ឲ្យបារីខ្ញុំ – អាបារីវែងនោះ បារីថ្នាំ – ហើយគាត់ឲ្យខ្ញុំហូបបារីហ្នឹងអស់ប្រហែល ១នាទី ២នាទីហ្នឹង ហើយបានគាត់ចាប់ផ្តើម។ គាត់ -- កន្លែងស្រុកហ្នឹង ដាក់គ្រែពីរ មុខមួយ -- អ៎!

មុខទាំងសងខាង ហើយបានគាត់ដាក់ខ្ញុំនៅកណ្ដាលហ្នឹង ហើយឲ្យបារីមួយដើមហ្នឹងឲ្យហូបសិន ហើយចាំបានសម្ភាសជាមួយខ្ញុំ។ អ៊ីចឹងខ្ញុំដែលនៅក្នុងឯកសារនេះ វាត្រឹមត្រូវហើយ ដែលខ្ញុំសម្ភាសជូនគាត់។ សូមអស់តែប៉ុណ្ណឹង។ វាបាត់ការចងចាំច្រើន។

**ស៖** តើគាត់នៅសម្ភាសលោកហ្នឹងនៅក្នុងភូមិណាដែរ?

**ឆ៖** នៅកន្លែងសាលាស្រុកហ្នឹងតែម្ដង។

**ស៖** តើលោក យៀវនិន សួរសំណួរលោកជាភាសាខ្មែរ ឬក៏ជាភាសាបរទេស ក្រោយមកទើបបកប្រែទៅជាភាសាខ្មែរឲ្យលោកស្ដាប់?

[០៩:៣៤:០៧]

**ឆ៖** គាត់បក បកមកភាសាខ្មែរ ដែលនៅជុំវិញខ្ញុំដែល--

**ស៖** នៅពេលដែលគាត់សួរសំណួរទៅកាន់លោក តើគាត់មានកាន់ក្រដាស និងប៊ិក កត់ត្រាទុកនូវអ្វីដែលលោកឆ្លើយដែរឬទេ?

**ឆ៖** ខ្ញុំអត់បានកត់ទេ ហ្នឹងហើយ។ គាត់ប្រហែលជាកត់ហើយ ដំណើរ គាត់យកព័ត៌មានពីខ្ញុំ។

**ស៖** តើលោកចាំទេ តើមនុស្សណាមួយនៅក្នុងបន្ទប់សម្ភាសលោកនោះ គេមានប្រើប្រាស់ម៉ាញ៉េទុកសំឡេង ថតអីទេ?

**ឆ៖** មាន១ មានថតសំឡេងខ្ញុំ។ កាលថតហ្នឹងគាត់ដាក់នៅអមភ្លៅខ្ញុំហ្នឹង។

**ស៖** តើឈ្មោះ ម៉ៃខល វីកឃើរី នេះលោកប្រហែលជានឹកឃើញទេថាមានឈ្មោះហ្នឹងនៅពេលនោះដែរឬទេ ម៉ៃខល វីកឃើរី?

**ឆ៖** ខ្ញុំនឹកឃើញតែបានជួបគ្នាសម្ភាសនៅក្នុងសមរភូមិ ខ្ញុំស្គាល់គាត់ដែរ។ បានជាគាត់កាត់មករកខ្ញុំ មកសម្ភាសនៅកន្លែងស្រុកខដុង្គតែម្ដង។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានយើងឃើញថាភស្តុតាងមូលដ្ឋាន ខ្ញុំបានបង្ហាញរួចមកហើយ។ ដូច្នេះសូមអនុញ្ញាតពីលោកប្រធានផ្ដល់កំណត់ហេតុកិច្ចសម្ភាសន៍មួយច្បាប់នេះជាភាសាខ្មែរសូមផ្ដល់ជូនទៅលោក នូ ម៉ៅ។

[០៩:៣៦:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំក៏ជំទាស់នឹងនីតិវិធីដែលស្នើសុំដូច្នេះផងដែរ។ តើលោក លោកស្រីចៅក្រមស្ដាប់ឮទេ? អរុណសួស្ដី លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ដូចដែលខ្ញុំសូមបញ្ជាក់អ៊ីចឹងគឺថាខ្ញុំជំទាស់នីតិវិធីនេះ មិនមានការបង្ហាញមូលដ្ឋានណាមួយនៅឡើយនោះទេ។ វាបង្ហាញច្បាស់ថាសាក្សីរូបថាគាត់មិនចេះភាសាអង់គ្លេសនោះឡើយ ហើយឯកសារដែលយើងមាននៅចំពោះមុខយើងនេះ ជាកំណត់ហេតុសរសេរដោយដៃដែលរៀបរាប់អំពីខ្លឹមសារនៃកិច្ចសម្ភាសន៍។ សាក្សីនេះចេះតែនិយាយភាសាខ្មែរនោះទេ។ ដូច្នេះ ឯកសារអង់គ្លេសវាមិនពាក់ព័ន្ធនោះទេ មិនពាក់ព័ន្ធទៅក្នុងការបង្ហាញទៅកាន់សាក្សីនោះឡើយ។ ដូច្នេះខ្ញុំសូមជំទាស់ចំពោះនីតិវិធីបែបនេះ។

[០៩:៣៧:៣៦]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមបន្ថែមទៅលើការជំទាស់ខ្ញុំអម្បាញ់មិញនេះ នៅមិនទាន់មានការឆ្លើយតបនឹងការជំទាស់របស់ខ្ញុំនៅឡើយ។ បើខ្ញុំយល់មិនខុសទេ សហព្រះរាជអាជ្ញាបានប្រាប់ថាសាក្សីនេះចាំថាត្រូវបានគេសម្ភាស -- ត្រូវបានសម្ភាសដោយលោក ប៉ែន យៀវនិន។ សំណួរចោទនោះ គឺថាតើមានការបកប្រែជាភាសាខ្មែរ ហើយយើងមិនដឹង -- ហើយនេះការបកប្រែនេះសំខាន់ណាស់ ការសម្ភាសគាត់នេះ។ ហើយសំណួរដែលត្រូវចោទសួរទៅសាក្សីជាបឋមនោះត្រូវដឹងថា តើគាត់មានបានអានកំណត់ហេតុនោះឡើងវិញដែរឬទេ? កំណត់ហេតុដែលគេធ្វើនៅថ្ងៃហ្នឹង? ដើម្បីឲ្យគាត់ដឹង ឬក៏ផ្ទៀងផ្ទាត់ថាតើមានការកែដែរឬទេ ទៅលើកំណត់ហេតុទាំងអស់ហ្នឹងកែប្រែនោះ។ អ៊ីចឹងសំណួរជាដំបូងនោះត្រូវបង្ហាញកំណត់ហេតុដែលគេធ្វើនៅថ្ងៃនោះជាភាសាអង់គ្លេសដោយលោក ប៉ែន យៀវនិន ហ្នឹងហើយនិងដឹងថាសាក្សីហ្នឹងគាត់បានអានកំណត់ហេតុហ្នឹងដែរឬទេ ឬក៏គេអានកំណត់ហេតុហ្នឹងឲ្យគាត់ស្ដាប់ដែរឬទេ? ហើយត្រូវដឹងទៀតថាអ្នកណាជាអ្នកបកប្រែកិច្ចសម្ភាសន៍គាត់ហ្នឹង។

[០៩:៣៨:៥៦]

ហើយចំណុចមួយទៀតគឺថា យើងនៅមិនដឹងថាតើពិតជាកំណត់ហេតុរបស់លោក ប៉ែន យៀវនិន មែនឬទេនៅថ្ងៃនោះ? ឬក៏កំណត់ហេតុនេះជាលទ្ធផលនៃការធ្វើក្រោយៗមកទៀតនោះទេមិនមែនបានធ្វើថ្ងៃនោះទេ។ អ៊ីចឹងសំណួរទាំងអស់នេះគឺតែសួរទៅសាក្សីជាមុនសិន ដោយហេតុថាយើងមិនដឹងថាកាលៈទេសៈនៃការសរសេរកំណត់ហេតុទាំងអស់នោះយ៉ាងម៉េចនោះទេ។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តីគឺគាត់លើកបញ្ហាចោទ សំណួរណាក៏បានដែរនៅពេលដែលគាត់សួរដេញដោលនោះ។ ពាក់ព័ន្ធទៅនឹងទម្ងន់នៃភស្តុតាងនេះគាត់អាចសួរសំណួរនោះពេលណាក៏បាន ប៉ុន្តែនៅពេលគឺគាត់កំពុងតែលើកឡើងបញ្ហានេះ គឺគាត់មិនបានបញ្ជាក់អំពីការទទួលយកឯកសារនេះបាន ឬក៏មិនបាននោះឡើយ អ្វីដែលខ្ញុំស្នើសុំនេះ។ ឯកសារនេះដាក់នៅក្នុងសំណុំរឿងច្រើនឆ្នាំមកហើយ ហើយភាគីទាំងអស់មានលទ្ធភាពអាចរក និងពិនិត្យមើលបាន។ វាស្ថិតនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា យោងតាមវិធាន៨០ គឺនៅក្នុងឧបសម្ព័ន្ធដែលកែសម្រួលលេខ 12។ ដូច្នេះតាមសេចក្តីសន្និដ្ឋានរបស់ខ្ញុំគឺថាយើងមិនគួរមិនឲ្យឯកសារនេះទៅដល់សាក្សីនោះទេ ដោយយើងពិចារណាទៅលើពេលវេលាយើងកើតឡើងយូរមកហើយក្រោយពេលសម្ភាសន៍។

[០៩:៤០:៤២]

ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបរួចមកហើយ សាក្សីទាំងឡាយដែលមកតុលាការនេះមានសិទ្ធិមើលឯកសារឡើងវិញដើម្បីឲ្យគាត់ចងចាំ ជាពិសេសឯកសារដែលបានបង្កើតឡើងតាំងពីឆ្នាំ២០០៩។

នៅទីនេះ គឺជាសាក្សីដែលគាត់មានវ័យចំណាស់ ហើយគាត់បានបញ្ជាក់ហើយថា គាត់មិនអាចនឹកឃើញគ្រប់ចំណុចហេតុការណ៍ដែលបានកើតឡើងទាំងអស់នោះឡើយ។ ហេតុដូច្នេះយើងខ្ញុំសូមសន្និដ្ឋានថា ដើម្បីជាភាពយុត្តិធម៌ សាក្សីរូបនេះគួរតែមានសិទ្ធិដូចសាក្សីដទៃទៀតទទួលបាននូវឯកសារដើម្បីរំឭកនូវការចងចាំរបស់គាត់ឡើងវិញ។ ខ្ញុំសូមបន្ថែមផងដែរថា វាមិនត្រឹមត្រូវដែលយើងខ្ញុំកំណត់អង្គហេតុនេះដែលវាពាក់ព័ន្ធទៅនឹង ប៉ែន យៀរនិន ថាគាត់មិនមកផ្តល់សក្ខីកម្មនោះឡើយ។ តាមពិតទៅលោក ប៉ែន យៀរនិន ត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្មតាមវីដេអូលីង។ ហេតុដូច្នេះ លោកប្រធាន ខ្ញុំសូមស្នើឲ្យខ្ញុំមានសិទ្ធិអនុញ្ញាតធ្វើឡើងតាមសំណើរបស់ខ្ញុំ។ ខ្ញុំឃើញមេធាវីការពារក្តីគាត់ក្រោកឈរឡើងហើយ ក៏ប៉ុន្តែតាមនិតិវិធីរបស់យើង គាត់មិនមានសិទ្ធិក្នុងការឆ្លើយតបម្តងទៀតនោះទេ។

[០៩:៤២:០៧]

**ប្រធានអង្គជំនុំ៖**

បាទ ត្រឹមត្រូវហើយមិនអនុញ្ញាតឲ្យជំទាស់តវ៉ាអីផ្សេងទៀតទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយទៅនឹង -- បញ្ជាក់ជូនទៅនឹងភាគីពាក់ព័ន្ធនឹងបញ្ហាឯកសារដែលត្រូវដាក់ដេញដោលនៅពេលនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

ចំណុចទី១ ពាក់ព័ន្ធទៅនឹងនិតិវិធី។ ការជំទាស់បានធ្វើឡើង ហើយការឆ្លើយបានធ្វើរួចមកហើយ ហេតុដូច្នេះហើយ មិនអាចឲ្យមានការឆ្លើយតបទៅនឹងការជំទាស់នេះម្តងហើយម្តងទៀតនោះឡើយ។ ចំពោះការជំទាស់ដែលបានធ្វើឡើងអង្គជំនុំជម្រះទទួលស្គាល់ថា ឯកសារនេះគឺបានបង្ហាញមូលដ្ឋានបឋមរួចមកហើយចំពោះឯកសារនេះ ដែលឯកសារនេះជាកម្មវត្ថុនៃការសួរដេញដោលទៅកាន់សាក្សីរូបនេះ។ ហេតុដូច្នេះ គឺក៏រួមបញ្ចូលនូវការសួរសំណួរទាំងឡាយដែលនឹងត្រូវធ្វើឡើងដោយមេធាវីការពារក្តីរួមទាំងការសាកសួរ និងដាក់ទម្ងន់ទៅលើភស្តុតាងដែលអង្គជំនុំជម្រះនឹងពិចារណានៅពេលក្រោយ។ ហេតុដូច្នេះហើយការជំទាស់នេះគ្មានប្រសិទ្ធភាពនោះឡើយ។ សូមអរគុណលោកប្រធាន។

[០៩:៤៤:៥០]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក នូ មោក តើលោកអាចបញ្ជាក់ជូនយើងខ្ញុំដែរឬទេថា នៅពេលដែលលោកចូលបដិវត្តន៍នោះ តើលោកចូលក្នុងឆ្នាំណាដែរ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំភ្លេចអស់ហើយ ភ្លេចភ្លាំងអស់ហើយវាយូរពេកដែរហើយ។ ទាល់តែមើលក្នុងឯកសារហ្នឹងបានដឹងថាឆ្នាំណោះខែណោះបាទ។ ហើយបើឲ្យនឹកឃើញ វាបាត់បង់អស់ទៅហើយផ្នែកខាងសតិអារម្មណ៍ហ្នឹងវាមិនចងចាំបាន អានេះចូលខែណោះ ថ្ងៃណោះ ខ្ញុំវានេះហើយ--

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំស្នើសុំការអនុញ្ញាតពីលោកប្រធាន។ នៅពេលនេះ ខ្ញុំសូមអនុញ្ញាតផ្តល់នូវកំណាត់ហេតុនៃការសម្ភាសនេះមួយច្បាប់ជូនទៅកាន់សាក្សី។ បាទ ជាភាសាខ្មែរតែម្តង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៤៦:០៩]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំឃើញថាមេធាវីការពារក្ដី វ៉ិចទ័រ កូប៉េ ក្រោកឈរហើយ ដូច្នេះគឺយើង -- ហេតុអ្វីមិនឲ្យឯកសារនេះទៅកាន់សាក្សីទៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ទេ ហេតុអ្វីបានជាឯកសារភាសាខ្មែរផ្ដល់ទៅកាន់សាក្សី វាមិនមែនជាឯកសារដើមផងនោះ ឯកសារដើមនោះជាភាសាអង់គ្លេស ហើយប្រសិនបើគាត់អាចនោះ គឺថាគួរតែទទួលយកឯកសារជាភាសាអង់គ្លេសទៅឲ្យមានការបកប្រែផ្ទាល់តែម្ដងទៅ។

**លោក ឃីត រេយ៍ន័រ៖**

ចំណុចលើកឡើងនេះ វាមិនមែនជាការលើកឡើងមួយត្រឹមត្រូវនោះទេ។ ដូច្នេះខ្ញុំសូមអនុញ្ញាតបន្តតែម្ដងទៅលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

[០៩:៤៧:១២]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក នួ មោក ឯកសារនេះគឺថាវាមានលេខសម្គាល់ជាអក្សរខ្មៅនៅខាងឆ្វេង ខាងលើនោះគឺថាមានលេខសម្គាល់ពណ៌ខ្មៅនោះគ្រប់ទំព័រតែម្ដង។ ប្រសិនបើលោកមើលខ្មែរ 00909936 សូមឲ្យលោកមើលលេខហ្នឹងទៅ 00909936, ចំពោះអង់គ្លេសគឺ 00419458, បារាំង 008935 -- សូមអធ្យាស្រ័យ បារាំងគឺ 00893548។ ចំពោះភាសាខ្មែរសូមកែតម្រូវគឺលេខសម្គាល់ 00909939។ សូមឲ្យលោក នួ មោក មើលទៅ។ លោកបានលើកឡើងនូវក្នុងនោះថា លោកបានចូលបដិវត្តន៍ឆ្នាំ១៩៧១ ហើយលោកចូលជាសមាជិកបក្សនៅក្នុងឆ្នាំ១៩៧២។ អ៊ីចឹងឆ្នាំហ្នឹងតើលោកនឹកឃើញទេ ពិតជាអ៊ីចឹង

ដែរឬទេ?

*(សម្រាករយៈពេលខ្លី)*

[០៩:៤៩:១៣]

**ស៖** ខ្ញុំសូមឲ្យមេធាវីប្រឹក្សាសាក្សីជួយរកឯកសារដល់សាក្សី គឺឯកសារត្រង់លេខ 00909936 ទំព័រដំបូង សូមឲ្យជួយបើកឲ្យគាត់មើលទៅ។ នៅក្នុងទំព័រនោះគឺលោក នូ ម៉ៅ បានលើកឡើងថា គាត់ចូលបដិវត្តន៍ក្នុងឆ្នាំ១៩៧១។ ដូច្នេះតាមការចងចាំរបស់លោក នូ ម៉ៅ នោះ តើលោកគិតថាត្រឹមត្រូវដែរឬទេនៅពេលដែលលោកចូលបដិវត្តន៍នោះ គឺលោកចូលក្នុងឆ្នាំ១៩៧១?

*(សម្រាករយៈពេលខ្លី)*

[០៩:៥០:២៩]

**លោក នូ ម៉ៅ៖**

**ឆ៖** នៅពេលនោះ ខ្ញុំជាសមាជិកគណបក្សឃុំជើងរាស់ ខ្ញុំចូលបដិវត្តន៍នៅឆ្នាំ១៩៧១។ ហើយនៅមុនពេលនោះ ខ្ញុំគឺជាកសិករនៅខេត្តកំពត។ កាលហ្នឹង អត់បានទេ ខ្ញុំ ខេត្ត--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** នៅខេត្តកំពង់ស្ពឺនោះ ដាក់នៅខេត្តកំពត ក្នុងឆ្នាំ--

**ស៖** សូមអរគុណលោក នូ ម៉ៅ។ ខ្ញុំសូមសួរលោកអំពីការប្រជុំមួយ ដែលគេលើកឡើងនៅក្នុងកំណត់ហេតុនេះផងដែរ។ ការប្រជុំនោះ គឺក្នុងឆ្នាំ១៩៧២ នៅក្នុងពេលប្រជុំនោះ តាម៉ុក លើកឡើងអំពីព្រះសង្ឃ។ ខ្ញុំសូមដកស្រង់សម្ដីចេញពីកំណត់ហេតុនេះតែម្ដង៖ “នៅក្នុងឆ្នាំ១៩៧២ ក្នុងពេលប្រជុំជាមួយសង្ឃជាង៣០០០នាក់នៅកំពង់ឆ្នាំង ម៉ុក បាននិយាយថា កុំឲ្យកងទ័ពវៀតណាមស្នាក់នៅក្នុងវត្ត ឬក្នុងភូមិអី។ ទ័ពវៀតណាមទាំងអស់នោះ គឺអាចទិញម្ហូបអាហារបាន ប្រសិនបើមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរទើបទិញបាន”។ សូមបញ្ចប់ការដកស្រង់។

តើ តាម៉ុក មានបានពន្យល់ដែរឬទេ ហេតុអ្វីបានជាការហាមឃាត់ គោលនយោបាយហាមឃាត់មិនឲ្យទិញម្ហូបដូច្នេះ អនុវត្តចំពោះកងទ័ពវៀតណាម?

[០៩:៥២:៤០]

**ឆ៖** តាម៉ុក គាត់បើកមហាសន្និបាតមួយនៅ -- ភ្លេចហើយ អាលើនេះ គេថា --

**ស៖** នៅក្នុងឯកសារដដែល អង់គ្លេស គឺអង់គ្លេស 00 -- ខ្មែរគឺមានលេខ 00909943។ លោក

បានលើកឡើងអំពីកិច្ចប្រជុំនេះដូចតទៅ។ ខ្ញុំសូមដកស្រង់សម្ដីលោក “ខ្ញុំនៅទីនោះ គឺមានអញ្ជើញពីព្រះសង្ឃពីរអង្គ បន្ទាប់មកគ្មានលោកសង្ឃស្នេហាជាតិមួយណាពាក់ព័ន្ធនោះឡើយ។ ការប្រជុំសង្ឃគឺដើម្បីឲ្យព្រះសង្ឃផ្សឹក ចុះចូលធ្វើទាហាន” បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំនោះគឺ តើលោកបានដឹងដែរឬទេ មានសង្ឃបានចូលរួមធ្វើជាទ័ពទេ ក្រោយពេលប្រជុំនោះ? បញ្ជាក់លេខ ERN ជាភាសាបារាំងគឺ 0089354, ហើយនិងអង់គ្លេសគឺ 00419464។

**ឆ៖** ភ្លេច បាត់បងអស់ហើយ ច្រើនពេក។

**ស៖** ខ្ញុំសូមបន្តទៅមុខទៀត។ តើ ជូ ជេត និងតាម៉ុក មានតួនាទីអ្វីដែរនៅក្នុងភូមិភាគនិរតី? តើ ជូ ជេត កាន់តួនាទីអ្វីដែរ?

**ឆ៖** ជូ ជេត កាន់ខាងផ្នែកនយោបាយ ហើយ តាម៉ុក គាត់កាន់ខាងយោធា។ អ៊ីចឹង តាម៉ុក ហើយនិង ជូ ជេត ហ្នឹង ពីខាងដើម គឺដូចថាប្រៀបចាញ់ ជូ ជេត បាទ ជូ ជេត។ អ៊ីចឹងគាត់ចាត់តាំងឲ្យធម្មការៗសម្រាប់ខាងផ្នែកព្រះសង្ឃ។ អ៊ីចឹងគាត់ធ្វើចលនាឲ្យព្រះសង្ឃហ្នឹង ផ្សឹក ដើម្បីចេញទៅធ្វើកងទ័ព។ អ៊ីចឹងពេលនោះគ្រប់វត្តទាំងអស់ ដែលតាម៉ុក ត្រូវជំរុញធម្មការឲ្យផ្សឹក ឲ្យលោកផ្សឹកដើម្បីមកធ្វើទ័ព។ ក្នុងឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចអស់ទៅហើយ។ ហើយបើនិយាយពីព្រះសង្ឃផ្សឹកអស់ហើយ ដើម្បីបញ្ជូនទៅធ្វើទាហាន កងទ័ព។ ខ្ញុំបានដឹងតែប៉ុណ្ណឹង។

[០៩:៥៧:២៣]

**ស៖** នៅក្នុងកំណត់ហេតុនោះ លោកបានឆ្លើយថា “លោក ជូ ជេត មានឈ្មោះហៅក្រៅថា ស៊ី” ហើយលោកបានបញ្ជាក់ថា “លោក ជូ ជេត នេះ ក៏ជាសមាជិកស្ថិតនៅក្នុងគណៈមជ្ឈិមផងដែរ”។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី កូបេ!

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការពិតលោកប្រធាន ខ្ញុំជំទាស់របៀបសួរសំណួរបែបនេះ ដោយសហព្រះរាជអាជ្ញា។ នៅពេលនេះគឺបានលើកឡើងថា សាក្សី គាត់និយាយថា សាក្សីឆ្លើយអ៊ីចឹងនៅក្នុងកំណត់ហេតុ។ នៅក្នុងឯកសាររបស់យើងនេះ គឺថាយើងឃើញថាវាជាភាសាអង់គ្លេស យើងក៏មិនដឹងថាយ៉ាងម៉េចនោះដែរ តើជាកំណត់ហេតុនោះធ្វើឡើងដោយចៅក្រមស៊ើបអង្កេត ឬក៏ដោយចៅក្រម? វាជាកំណត់ហេតុមួយដែលគេរាយការណ៍ថា ប្រហែលជាសាក្សីហ្នឹង អាចឆ្លើយដូច្នេះនៅក្នុងពេលសម្ភាស។ យើងមិនអាចសន្មត

ថាវាជាកំណត់ហេតុពាក្យពេចន៍ដើមរបស់សាក្សីនេះឡើយ។ យើងត្រូវតែអនុវត្តតាមនីតិវិធីរបស់យើង។ វាជាឯកសារមួយច្បាប់តែប៉ុណ្ណោះ ដែលសរសេរអ្វីដែលសាក្សីបានឆ្លើយទៅកាន់ យៀរឌិន។ ដូច្នេះ សហព្រះរាជអាជ្ញាមិនគួរនិយាយថា សាក្សីបាននិយាយដូច្នេះ ដូច្នោះ នៅក្នុងកំណត់ហេតុនោះទេ។

[០៩:៥៨:៥១]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធានជាទីគោរព! នេះវាពាក់ព័ន្ធទៅនឹងទម្ងន់នៃភស្តុតាងនោះទេ។ អ្វីដែលគាត់លើកឡើង មិនមែនពាក់ព័ន្ធទៅនឹងការទទួលយកបាននៃឯកសារនោះឡើយ។ ខ្ញុំនឹងប្រើប្រាស់ពាក្យពេចន៍ផ្សេងទៀតប្រសិនបើគាត់ចង់បានដូច្នោះ។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ឯកសារនេះ កត់ត្រាទុកនូវអ្វីដែលលោកឆ្លើយប្រាប់លោក យៀរឌិន ដែលលោកនិយាយ -- ដែលគេកត់ត្រាថា “ស៊ី នេះស្ថិតនៅក្នុងគណៈមជ្ឈិម”។ តើ ស៊ី នេះ ស្ថិតនៅក្នុងគណៈមជ្ឈិមដែរឬទេ ប្រសិនបើមែននោះ តើធ្វើម៉េចដឹងទៅ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ដដែលនីតិវិធីបែបនេះ។ វិធីសួរបែបនេះ គឺខ្ញុំគិតថា វាគួរឲ្យអស់សំណើច មិនសមរម្យនោះទេ។ គឺនៅពេលដែលគាត់និយាយថា កំណត់ហេតុនោះត្រូវបានកត់ត្រាទុកថា គាត់បានឆ្លើយថា “ស៊ី នេះជាគណៈមជ្ឈិម” ហើយបន្ទាប់មកគាត់សួរសំណួរដែលនាំមុខ។ គាត់គួរតែសួរសំណួរដែលបើកចំហទៅកុំឲ្យនាំមុខ។

[១០:០០:១២]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាននេះគឺជាប្អូនដងហើយដែលមេធាវីការពារក្ដីជំទាស់នៅពេលដែលខ្ញុំសួរសំណួរ។ ការជំទាស់នេះដដែលៗធ្វើឡើងដោយលោក វ៉ិចទ័រ កូប៉េ ខ្ញុំរាប់ទៅប្អូនដងហើយ។ ហើយលោកប្រធានបានជំទាស់គាត់មិនឲ្យគាត់ជំទាស់បែបនេះបួនដងរួចមកហើយ។ ដូច្នេះ តើខ្ញុំសូមលើកឡើងម្ដងទៀតដែរឬទេ ថានីតិវិធីនេះគឺបានបង្កើតថែងច្បាស់លាស់រួចមកហើយនៅក្នុងតុលាការនេះ។ កាលពីឆ្នាំមុន

លោក រ៉ិចទ័រ កូប៉េ គាត់មិនមានវត្តមាននៅក្នុងបន្ទប់សវនាការនោះគឺគាត់មិនទាន់ចូលមកបំពេញការងារនៅក្នុងបន្ទប់សវនាការនោះទេ។ ដូច្នេះហើយខ្ញុំសូមលើកឡើងថាតើខ្ញុំគួរលើកឡើងការឆ្លើយតបនឹងការជំទាស់នេះដដែលឬក៏យ៉ាងម៉េច? ខ្ញុំដឹងច្បាស់អំពីនីតិវិធីដែលបង្កើតនៅក្នុងតុលាការនេះ។

**ប្រធានអង្គជំនុំ៖**

អាចមានបញ្ហាពីរ។ ទី១ គឺលោកបានឆ្លើយតបទៅនឹងសេចក្តីជំទាស់របស់គេដោយលោកសន្យាថាកែសម្រួលនូវសំណួររបៀបសួររបស់លោកសាឡើងវិញ។ ប៉ុន្តែការកែសម្រួលរបស់លោកមិនមានការកែប្រែអ្វីខុសពីរបៀបសំណួរពេលដែលជំទាស់ទេ។ នេះហើយបង្កើតជាបញ្ហា។ ប្រសិនបើលោកកែសម្រួលឲ្យបានច្បាស់លាស់នោះគឺវាលែងមានបញ្ហាទៀតហើយ។ អង្គជំនុំជម្រះមិនបានសម្រេចលើសេចក្តីជំទាស់ចំពោះរបស់មេធាវី រ៉ិចទ័រ កូប៉េ អម្បាញ់មិញនេះដោយមូលហេតុតំណាងសហព្រះរាជអាជ្ញាមិនបានឆ្លើយតបទៅសេចក្តីជំទាស់របស់មេធាវីការពារក្តីទេ។ លោកសហព្រះរាជអាជ្ញាបានប្រើពាក្យថា លោកនឹងកែសម្រួលនូវសំណួររបស់លោកឲ្យបានសមស្រប។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះទុកលទ្ធភាពឲ្យលោកតាំងសំណួរឲ្យបានសមស្រប មិនសម្រេចលើសេចក្តីជំទាស់ដោយលោកសាឡើងវិញសំណួរទម្រង់ដដែល។ អ៊ីចឹងហើយបានជាមានការជំទាស់សាជាថ្មី។ សេចក្តីជំទាស់គឺមាន លក្ខណៈសមស្រប! លោករៀបចំនូវសំណួរឲ្យបានសមស្របចៀសវាងនូវសំណួរនាំមុខ ឬក៏សំណួរបែបម្យ៉ាងមានបញ្ហាពាក់ព័ន្ធទៅនឹងឯកសារនេះ ដែលលោកដកស្រង់ចាត់ទុកឯកសារនេះគឺវាត្រឹមត្រូវជាមូលដ្ឋានដូចឯកសារដែលធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ឯកសារនេះវាខុសពីខ្លឹមសារនៃកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីរូបនេះនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។

[១០:០២:៤៣]

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក នូ ម៉ៅ ថាតើឈ្មោះ ជូ ជេត មានតួនាទីអ្វីក្រៅពីតួនាទីនៅភូមិភាគនិរតីនោះដែរឬទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ជូ ជេត ហៅ ស៊ី គាត់ខាងផ្នែកនយោបាយ។ ខាងផ្នែកនយោបាយគឺខ្លាំងមែនទែន ចលនា

ប្រជាជន។ ខាងម៉ុក ខាងយោធា ហ្នឹងខាងផ្នែកយោធា តែលើការចលនាវា ប្រជាជនគាំទ្រគឺ ជូ ជេត ដែលប្រជាជនគាំទ្រចំពោះគាត់ លើកឡើងគឺចលនាការតស៊ូ។ ខ្ញុំសូមអស់ប៉ុណ្ណឹង។

**ស៖** តើលោកដែលបានទទួលសេចក្ដីណែនាំការបង្រៀន ឬក៏ការរៀនសូត្រណាមួយដែល ជូ ជេត ជាអ្នកបង្រៀនដែរឬទេ?

**ឆ៖** គាត់បង្រៀនខ្ញុំនៅខាងថ្ពង នៅវត្ត -- ភ្លេចវត្តទៀតហើយ កែវទក ខាងជើងវត្តកែវទក ចំនួនជាមនុស្ស អានេះខ្ញុំប៉ាន់ស្មានទេ បើតាមដាក់ក្នុងនោះថា៣០០ តាមប៉ាន់ស្មានរបស់ខ្ញុំវាមានតែ២០០ លើសបន្តិចបន្តួចប៉ុណ្ណឹង ដែលនៅការរៀនសូត្រហ្នឹង គឺចំនួនជិត១ខែ ដើម្បីចូលកម្មាភិបាលដែលត្រូវដឹកនាំទៅតាមស្រុកទៅតាមតំបន់ បំផុសប្រជាជនឡើងដើម្បីតស៊ូស្វែងរកសន្តិសភាព។ ហ្នឹងគាត់បើកសាលាហ្នឹង សាលាបង្រៀនហ្នឹងវាមនុស្សប្រហែលជាង ២០០តែប៉ុណ្ណឹង។ ហ្នឹងហើយ រៀន១ខែ, ១ខែ លើសបន្តិចបន្តួចប៉ុណ្ណឹង។ ខ្ញុំសូមអស់ប៉ុណ្ណឹង។

**ស៖** នៅពេល ជូ ជេត បង្រៀន តើគាត់មាននិយាយអ្វីអំពីវៀតណាម ហើយថាតើលោកគួរប្រព្រឹត្តបែបណាចំពោះវៀតណាមនោះដែរឬទេ?

[១០:០៦:២០]

**ឆ៖** គាត់ -- ចំពោះវៀតណាមគាត់អត់លើកនិយាយពីវៀតណាមទេ។ គាត់បើតាម -- តែគាត់មិនបានប្រាប់នៅក្នុងសាលានោះផងទេ តែគាត់គ្រាន់តែថា "វៀតណាមជាមិត្តរបស់កម្ពុជា ជួយកម្ពុជា" គ្រាន់តែគាត់លើកឡើងតែប៉ុណ្ណឹង។ ខ្ញុំអស់តែប៉ុណ្ណឹងហើយ។

**ស៖** ឥឡូវនេះ តើលោកនៅចាំបានទេ? តើការរៀនសូត្រហ្នឹងរៀនសូត្រនៅទីកន្លែងណាដែរ?

**ឆ៖** រៀនសូត្រនៅខាងស្រុកថ្ពង នៅវត្តកែវទក ខាងជើងវត្ត ដីចំនួនពីរគីឡូនៅអមមាត់ស្ទឹង។ រៀនហ្នឹងចង់១ខែ ១ខែលើសបន្តិចបន្តួច ដើម្បីបំផុសចលនា។ បើនិយាយពីគាត់បង្រៀន ពាក់ព័ន្ធនយោបាយអត់យកវៀតណាមជាសត្រូវទេ ដើម្បីជួយនៅកម្ពុជា។ ហ្នឹងបើគាត់លើក តែគ្រាន់តែការលើកនេះ វាចំពោះដែលកម្មាភិបាលដែលគាត់ហៅទៅសិក្សា ទាំងរៀនខាងផ្នែកនយោបាយហ្នឹង កុំសត្រូវជាមួយវៀតណាម។ ដ្បិតអីវៀតណាមជួយកម្ពុជា ដើម្បីរំដោះនៅប្រទេសជាតិ។ ហ្នឹងសូមអស់ប៉ុណ្ណឹង ខ្ញីអ៊ីចឹង។ ខ្ញុំចេះតែភ្លេចបាត់បង់ដែរ។

[១០:០៨:២៥]

**ស៖** ក្រៅពី ជូ ជេត ដែលជាអ្នកបង្រៀននោះ តើឥឡូវនេះលោកនៅចាំថាមានអ្នកណាទៀតគេ

ធ្វើជាអ្នកបង្រៀនដូច ជូ ជេត នោះដែរឬទេ?

**ឆ៖** ខ្ញុំចាំអត់ៗអស់ទេ ចេះតែភ្លេចឈ្មោះហ្នឹងហើយ ភ្លេចឈ្មោះហើយ។ ខ្ញុំមិនអាចនឹងថា អ្នកនេះ អ្នកនោះ។ ខ្ញុំអត់លាក់ទេ តែគ្រាន់តែខ្ញុំភ្លេចអស់ហើយអ្នកទៅបង្រៀន វាយូរពេកហើយ ក្តាប់ក្រុមហ្នឹងវាអត់ចាប់ជាប់ទៅហើយ។

**សៈ** ឥឡូវនេះលោកចាំច្បាស់ទេ តើឆ្នាំណាដែល ជូ ជេត បង្រៀនហ្នឹង ឆ្នាំណាពិតប្រាកដដែល ជូ ជេត បង្រៀនលោកនោះ?

[១០:០៩:៣២]

**ឆ៖** មិនចាំឆ្នាំទៀតខ្ញុំ។ ថាអត់តែម្តងទៅ អត់ចាំទេក្នុងឆ្នាំ។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ឥឡូវហ្នឹងលោកសាក្សីនិយាយថា គាត់មិនចាំពេលវេលា មិនចាំឈ្មោះអ្នកបង្រៀនដទៃទៀត។ ឯកសារនេះមានកំណត់ត្រារបស់ ប៉ែន យៀរនិន ថាតើខ្ញុំសួរសំណួរបើកដើម្បីយកឯកសារហ្នឹងមកប្រើប្រាស់ដើម្បីរំឭកដល់ការចងចាំរបស់សាក្សីរូបនេះបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**សៈ** កំណត់ត្រានៃកិច្ចសម្ភាសន៍នេះគឺសរសេរដូចតទៅ សូមដកស្រង់៖ "នៅកន្ទួត នៅឆ្នាំ១៩៧៣ មានប្រជាជនចូលរួមជួនកាលមាន១៥០នាក់ចូលរួមក្នុងការបង្រៀន។ អ្នកបង្រៀននោះ គឺមានឈ្មោះ ស៊ី, ម៉ុក និង ផល"។ បញ្ចប់ការដកស្រង់។ នេះគឺទំព័រអង់គ្លេសគឺ 00419458, ខ្មែរ 00909936, បារាំង 00893546។ លោក នូ ម៉ៅ ថាតើចំណុចនេះរំឭកដល់ការចងចាំរបស់លោកដែរទេ ថាការបង្រៀនគឺឆ្នាំ៧៣ និងមានអ្នកដទៃទៀតមកជួយបង្រៀនក្រៅពី ស៊ី នោះគឺមាន ម៉ុក ផងដែរ មាន ផល មួយទៀត?

[១០:១១:៣២]

**លោក នូ ម៉ៅ៖**

**ឆ៖** បាទ មាន ម៉ុកៗ នុំង មកក្រោយទេ។ មកក្រោយការសិក្សាហ្នឹងបានជិតចប់ហើយ បាន ម៉ុក មកបង្ហាត់បន្ថែម។ បាទ គាត់ខាងយោធា។ រួចដទៃទៀតខ្ញុំភ្លេចអស់ហើយ ហ្នឹងហើយការចងចាំ

ឈ្មោះហ្នឹងវាអត់បានគិត កត់ត្រាទុក។

**ស៖** ឥឡូវនេះលោកចាំទេ តើលោករៀនសូត្រអ្វីនៅក្នុងវគ្គរៀនសូត្រហ្នឹង?

**ឆ៖** ក្នុងការសិក្សា រៀនសូត្រហ្នឹង ទី១ បំពាក់បំប៉នកម្មាភិបាលដែលបានចូលបម្រើការងារក្នុងបក្សបដិវត្តន៍, ហើយទី២ ឲ្យធ្វើប្រវត្តិរូបម្នាក់ៗ លម្អិតពីកម្មករ និងកសិករ, ទី៣ ឲ្យកម្មាភិបាលចុះជាប់ជាមួយប្រជាជនចលនាតស៊ូ ក្រោកឡើងដើម្បីរំដោះនូវប្រទេសជាតិប៉ុណ្ណឹង។ តែទន្ទឹមនោះទៀត ខ្ញុំវាភ្លេចៗនៅក្នុងការសិក្សារៀនសូត្រអស់រលីងដែរ អត់មានអីឯកសារទុកសម្រាប់នៅជាប់ហ្នឹងខ្លួនអី អត់ទេ។ ហ្នឹងហើយ សូមអស់ប៉ុណ្ណឹងហើយដែលខ្ញុំបានដឹង។

[១០:១៣:៣១]

**ស៖** ក្នុងពេលរៀនសូត្រ (ខ្ញុំសូមសួរឡើងវិញ) ក្នុងពេលរៀនសូត្រ តើលោកដែលមានឯកសារដែរទេ?

**ឆ៖** អត់មានទេ ខ្ញុំអត់មាននៅជាប់មកទល់ឥឡូវហ្នឹង អត់មានទេ។ បានថាអត់មាន វាដូចជាចប់សង្គ្រាមហើយ មានបានទុកដាក់នៅក្នុងឯកសារឯណា អត់ មានតែឆេះផ្ទះ ឆេះសម្បែងខ្ទេចខ្ទីអស់ទៀត ក្រោយមក។

**ស៖** បាទ សំណួរគឺយ៉ាងដូច្នេះទេ នៅពេលគ្រូបង្រៀនៗលោក តើគេមានដែលយោងទៅឯកសារណាមួយដែលឬទេ?

**ឆ៖** ខ្ញុំក្តាប់អត់ជាប់ទេ សូមអធ្យាស្រ័យហើយ ហ្នឹងហើយវាបាត់បង់អស់ហើយ ខ្ញុំថារឿងចាស់ហើយ វាភ្លេចភ្លាំង អាចក្តាប់មិនបាន។ វាយូរយារដែរ កន្លងមកហើយវា ដល់សើរើទៅខាងផ្នែកអារម្មណ៍ហ្នឹង វាមិនអាចចាប់បាននូវការសិក្សារៀនសូត្រនោះទេ។ ខ្ញុំ -- ហើយក៏មិនបដិសេធដែរ ប៉ុន្តែគ្រាន់ថាខ្ញុំវាភ្លេច ការចងចាំហ្នឹងវាបាត់តាំងស្មារតី តាមកម្លាំងរោគា វាគេចទម្លាក់គ្រាប់បែក អាហ្នឹងវាឆ្លងកាត់ហ្នឹងវាច្រើនដែរ វាថាសួរហើយ វាប្រាកចាកប្រធានសំណួរ។ ហ្នឹងបានន័យថាខ្ញុំគ្រាន់តែសម្តែងចំពោះនូវអង្គប្រជុំជូនថាខ្ញុំវាបានឆ្លងកាត់ក្នុងវគ្គនយោបាយហ្នឹង។ តែគ្រាន់ថាការចងចាំអ្នកដែលមកបង្រៀនហ្នឹង វាភ្លេច ចាំបានមួយចំណែក មួយចំនួនណាអាចចាំបាន ខ្ញុំរាយការណ៍ជូនបាន។ សូមអស់ប៉ុណ្ណឹង។

[១០:១៦:២៥]

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមយកឯកសាររបស់ ប៉ែន យៀនិន ដែលគ្របដណ្ដប់ទៅលើចំណុចលម្អិត ដើម្បីសួរសំណួរបើកពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍មែន ព្រឹត្តិការណ៍នានារំឭកដល់ការចងចាំរបស់សាក្សី។ សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** ឯកសារនេះគឺនិយាយអំពី សូមដកស្រង់ "យើងបានសិក្សាអំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា ការវាយចក្រពត្តិអាមេរិក រៀនសូត្រអំពីផែនការជម្លៀសប្រជាជនចេញពីខ្មាំង អាហ្នឹងនៅពេលដែល ម៉ុក បង្រៀនរបស់ -- បង្រៀនដល់យើងខ្ញុំ"។ បញ្ចប់ការដកស្រង់។ តើ ម៉ុក មានដែលបង្រៀនលោកអំពីផែនការជម្លៀសប្រជាជនចេញពីខ្មាំងនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

[១០:១៧:៥៥]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមឲ្យតំណាងសហព្រះរាជអាជ្ញាបញ្ជាក់អំពីលេខទំព័រដែលលោកធ្វើការដកស្រង់។ សូមអរគុណ។

**លោក ឃីត វេយ៉ន័រ៖**

ឯកសារនេះគឺ ERN ដូចតែគ្នាទេ ERN 00 -- ខ្មែរ 00909936, បារាំង 00419458, អង់គ្លេស 00419458, បារាំង 00893546។

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** តើចំណុចដែលខ្ញុំលើកឡើងនេះ លោកសាក្សីជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលថាលោកក៏រៀនសូត្រអំពីផែនការជម្លៀសប្រជាជនចេញពីពួកខ្មាំងផងដែរ?

**លោក នូ ម៉ៅ៖**

**ឆ៖** តាម៉ុក គាត់លើកឡើងអំពីជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ រីឯ ជូ ជេត គាត់បានលើកឡើងថា មិនត្រូវជម្លៀសប្រជាជនទេ។ អ៊ីចឹង ម៉ុក ជាយោធា កាន់ខាងផ្នែកយោធា។ ជូ ជេត ហៅ ស៊ី គាត់លើកឡើងអំពីជម្លៀសប្រជាជន គាត់មិនឲ្យជម្លៀសចេញពីទីក្រុងភ្នំពេញទេ តែ ម៉ុក នៅតែទាមទាយ៉ាងម៉េចត្រូវតែជម្លៀសចេញឲ្យអស់ពីទីក្រុង។ ហ្នឹងដែលខ្ញុំបានដឹងប៉ុណ្ណឹង ដែលក្នុងការសិក្សារៀនខាងផ្នែកនយោបាយ។

[១០:២០:១៥]

**ស៖** បាទ ខ្ញុំយល់មិនច្រឡំទេនោះ តើលោកធ្លាប់បានស្តាប់ តាម៉ុក និយាយដោយផ្ទាល់មាត់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ? គឺនិយាយនៅក្នុងកិច្ចប្រជុំណាមួយក៏ដោយ លោកធ្លាប់ដែលឮផ្ទាល់មាត់ចេញពី តាម៉ុក នោះដែរទេ?

**ឆ៖** តាម៉ុក បានឮ នោះហើយបានឮ។ នោះហើយ ជួនណាគាត់ហៅទៅប្រជុំអ៊ីចឹងទៅ ខាងផ្នែកយោធា។ គាត់ថា "យើងវ៉ៃលុកចូលទីក្រុងភ្នំពេញ យើងត្រូវតែជម្លៀសប្រជាជនចេញឲ្យអស់ពីទីក្រុង។ មិនថាប្រជាជន ឬថ្នាក់ណា គឺជម្លៀសឲ្យអស់ ឲ្យស្អាតពីភ្នំពេញតែម្តង"។ ហ្នឹងដែលគាត់លើកឡើង។ ក្នុងការប្រជុំម្តងៗ គឺចេញពីវាចារបស់គាត់ ដែលគាត់ខាងផ្នែកយោធា។ ហ្នឹងដែលគាត់កន្លែងណាដែលគាត់ត្រូវការ កម្មាភិបាលមូលដ្ឋានគាត់ហៅទៅព្រមាន គាត់ថាត្រូវតែយល់ ហ្នឹងចេញ។ សូម្បីតែប្រជាជនហ្នឹង ក៏គាត់មិនចង់ឲ្យប្រជាជនទីក្រុងភ្នំពេញមកជនបទទេហ្នឹងហើយ។ មុខរបរខាងកសិកម្ម ធ្វើស្រែ ធ្វើចម្ការ គាត់មិនចេះទេ។ អ៊ីចឹងទុកឲ្យគាត់នៅទីក្រុងចុះ ហ្នឹងចំពោះ តាស៊ី។ ហ្នឹងខ្ញុំមានយោបល់ប៉ុណ្ណឹង ហ្នឹងហើយវាភ្លេចបាត់បង។ ដល់តែខ្ញុំមានយោបល់ថា និយាយតែពីការបាត់បងហើយមិនចងចាំ អាហ្នឹងវាជារឿងមួយដែលជារឿងខ្ញុំ វាចាស់ទ្រុឌទ្រោមទៅ វាក្តាប់ជួប និងការដឹងហ្នឹងវាមិនបានគ្រប់គ្រាន់ ហ្នឹងហើយ មិនបានគ្រប់គ្រាន់។ ខ្ញុំមានតែប៉ុណ្ណឹង។

[១០:២២:៤២]

**ស៖** តើ តាម៉ុក មាននិយាយអំពីការវាយប្រយុទ្ធទីក្រុងភ្នំពេញ ហើយនិយាយថាប្រជាជនត្រូវជម្លៀសឲ្យអស់ពីភ្នំពេញដែរទេ? តើគាត់និយាយតែម្តង ឬក៏និយាយច្រើនដង? តើលោកស្តាប់ឮពីតាម៉ុកតែម្តង ឬក៏លោកស្តាប់ឮតាម៉ុក និយាយផ្ទាល់ហ្នឹងលើសពីម្តងឡើងទៅ?

**ឆ៖** ខ្ញុំ ត្រង់ហ្នឹង វាអ៊ីចេះដែរ គ្រាន់ថាដែលគាត់បើកអង្គប្រជុំកម្មាភិបាលនៅមូលដ្ឋានហ្នឹង គឺគាត់សំដែងអ៊ីចឹងតែម្ដង ហ្នឹងហើយសំដែងប្រាប់អ៊ីចឹង។ ហ្នឹងដែលខ្ញុំអាចដឹង ទាំងកម្មាភិបាលមូលដ្ឋាន ទាំងសកម្មជនរបស់អ្នកធ្វើបដិវត្តន៍ ទាល់តែជម្លៀសហ្នឹងហើយ។ ខ្ញុំក្ដាប់បានតែប៉ុណ្ណឹង។

**ស៖** តើ តាម៉ុក មាននិយាយថា ត្រូវជម្លៀសប្រជាជនទៅទីណានោះដែរឬទេ? ត្រូវជម្លៀសចេញពីភ្នំពេញហ្នឹង យកទៅទីណាដែរទេ?

**ឆ៖** តាម៉ុក គាត់ជម្លៀសប្រជាជនទៅតាមភូមិភាគ គ្រប់កន្លែង ខាងនិរតី។ រួចប្រជាជនដែលជម្លៀសមកហ្នឹង បើនិយាយពីប្រជាជនពីខេត្តកណ្ដាល ភូមិភាគខាងលិចមកទាំងអស់ហ្នឹងហើយ។ ជម្លៀសប្រជាជនដែលចេញពីទីក្រុងភ្នំពេញទៅ រៀបចំជាសហករណ៍។ អ្នកណាស្លាប់ៗទៅ អ្នកណារស់នៅវេទនា ជីកដំឡូង ជីកក្ដួចហូបអ៊ីចឹងទៅប្រជាជន។ រឿងហ្នឹងតែប៉ុណ្ណឹងទេ ខ្ញុំរាយរបាយការណ៍យ៉ាងម៉េចឲ្យវាបានល្អិតល្អន់ អត់បានតទៅទៀតទេ អស់ហើយ។

[១០:២៥:២១]

**ស៖** នៅពេល តាម៉ុក និយាយអំពីផែនការហ្នឹងនៅក្នុងឆ្នាំ៧៣ តើគាត់និយាយថា ផែនការហ្នឹងជាផែនការសម្រាប់តែភូមិភាគនិរតី ឬក៏ជាផែនការសម្រាប់ភូមិភាគដទៃៗទៀតដែរ?

**ឆ៖** គាត់ថា ទូទៅប្រទេសតែម្ដង។ ហ្នឹងហើយ និយាយទូទៅប្រទេស មិនថានិរតី មិនថាបូព៌ា មិនថាពាយ័ព្យអីទេ ត្រូវតែឲ្យចេញពីទីក្រុងភ្នំពេញតែម្ដង។

**ស៖** នៅពេល តាម៉ុក និយាយអំពីផែនការត្រូវជម្លៀសប្រជាជនចេញពីភ្នំពេញទាំងអស់ គឺជម្លៀសគ្រប់ស្រទាបវណ្ណៈទាំងអស់ តើតាម៉ុក មានពន្យល់បន្ថែមទៀតទេដែលត្រូវថាជម្លៀសប្រជាជនគ្រប់ស្រទបវណ្ណៈទាំងនេះ? មាននិយាយអ្វីបន្ថែមពីលើកទៀតទេ?

**ឆ៖** អត់មានទេអស់ហើយ។ ខ្ញុំវា -- អង្គាល់នុំងខ្ញុំឈឺផង វាមិនសូវបានដិតដល់ផងរឿងហ្នឹង ខ្ញុំមានការគ្រោះថ្នាក់នៅក្នុងសមរភូមិផង។ ហើយខ្ញុំក៏មិនបានដិតដល់អីណាឲ្យបានជិតដិតជាមួយតាម៉ុកហ្នឹងក៏តាំងពីខ្ញុំចាប់ឈឺមក ធ្លាក់ឈាមលែង គេលែងប្រើការកើត។ គេឲ្យសម្រាកព្យាបាល។ អស់ប៉ុណ្ណឹងហើយ។

[១០:២៧:៤២]

**ស៖** តើ តាម៉ុក មានបានពន្យល់ដល់លោកថាហេតុអ្វីបានជាត្រូវជម្លៀសប្រជាជននោះដែរឬទេ?

**ឆ៖** អត់ទេ ខ្ញុំអត់បាន។ អត់ដឹង ខ្ញុំអត់ ដល់ខ្ញុំឈឺហើយ ខ្ញុំលែង គេឈប់ប្រើទៅហើយ។

**ស៖** នៅកិច្ចប្រជុំដែល តាម៉ុក និយាយអំពីផែនការជម្លៀស ហើយលោកមានវត្តមាននៅទីនោះដែរ។ តើ ជូ ជេត មានវត្តមានដែរឬទេពេល តាម៉ុក និយាយអំពីផែនការជម្លៀសប្រជាជនហ្នឹង?

**ឆ៖** ចាន់ ស៊ី ៗគាត់ -- ខ្ញុំអង្គាល់នុំង ខ្ញុំភ្លាប់អត់បានដែរ ការចងចាំហ្នឹងវាបាត់បង់អស់ហើយ។ ចង់គាត់ដឹង ឬមិនដឹង ក៏មិនដឹងយ៉ាងម៉េចដែរទេ។ ខ្ញុំវាត្រូវគ្រោះថ្នាក់ដែលនៅក្នុងសមរភូមិនោះ។ ខ្ញុំនៅតែព្យាបាលតាមពេទ្យនានាហ្នឹង ទិញថ្នាំពីតំបន់ភ្នំពេញមក ធ្វើអីកើតបើវាធ្លាក់ឈាម ទៅណាបាន បើនៅខ្លួនស្គមដូចកុកទៅហើយ ធ្វើអីទៀតទៅទៀតអត់បានទេ។

**ស៖** ក្រោយកិច្ចប្រជុំដែល តាម៉ុក និយាយអំពីផែនការជម្លៀសប្រជាជន តើលោកមានចូលរួមប្រជុំកិច្ចប្រជុំតូចៗណាដទៃទៀត ដែលគេនិយាយអំពីផែនការជម្លៀសប្រជាជននេះដែរឬទេ?

[១០:៣០:០៨]

**ឆ៖** ហ្នឹងឮតាមគ្នាតៗដែរហ្នឹងកម្មាភិបាលថ្នាក់ទាបហ្នឹងនៅក្នុងឃុំ នៅក្នុងភូមិអីហ្នឹង គេឮមិនមែនអត់ឮទេ។ ខ្ញុំអាល័យតែ ដូចខ្ញុំលើកឡើងអំពីការជំងឺឈឺរបស់ខ្លួនខ្ញុំ ហើយដេកនៅពេទ្យព្យាបាលនៅផ្ទះ ក្រៅពីនោះខ្ញុំលែងដឹងលែងឮទៅ គេក៏លែងប្រើខ្ញុំទៅ។

**ស៖** លោក នូ មោក ខ្ញុំមិនបាននិយាយចោទប្រកាន់អ្វីថាលោកនិយាយខុស និយាយមិនត្រឹមត្រូវទេលោក លោកយល់ទេ?

បាទ ខ្ញុំសូមបន្តទៅទៀត។ ពីខាងដើមនោះលោកនិយាយថា ជូ ជេត គាត់ជាអ្នកនិយាយប្រឆាំងនឹងការជម្លៀសប្រជាជន។ តើធ្វើម៉េចបានជាលោកដឹងថា ជូ ជេត និយាយប្រឆាំងនឹងការជម្លៀសហ្នឹង?

**ឆ៖** គាត់និយាយនៅក្នុងការសិក្សារៀនសូត្រហ្នឹងខាងផ្នែកនយោបាយ។ ហើយគាត់បើកសាលាបង្រៀនកម្មាភិបាលតាមនៅក្នុងព្រៃនៅក្នុងអី ពីដើមសំបូរព្រៃ ហៅទៅសាលានៅម្លប់ឈើនេះ។

**ស៖** តើលោកគិតថាដូចម្ដេចដែរនៅពេលលោកឮ តាម៉ុក និយាយអំពីផែនការជម្លៀសប្រជាជនចេញពីភ្នំពេញទាំងអស់ ហើយបន្ទាប់មកលោកឮ ជូ ជេត និយាយជំទាស់ និយាយប្រឆាំងទៅនឹងការជម្លៀសប្រជាជន។ តើលោកមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលដែលលោកទទួលបានព័ត៌មានខុសគ្នាពីរយ៉ាងដូច្នេះ?

**ឆ៖** ព័ត៌មានខាងផ្នែកមួយ ខាងផ្នែកនយោបាយ មួយខាងផ្នែកយោធា។ ខាងផ្នែកនយោបាយបំផុសចលនាប្រជាជន ហើយក៏អត់មានពាក់ព័ន្ធពីរឿងដែលត្រូវការជម្លៀសប្រជាជនឡើយ។ នោះខាង ជូ ជេត ហៅ ស៊ី។ រួច ម៉ុក គាត់ខាងយោធា គាត់លើកឡើងអំពី "ត្រូវតែជម្លៀសប្រជាជនចេញពីទីក្រុង

មិនថា ភូមិភាគ នីរតី ឬក៏ភូមិភាគបស្ចិមបូព៌ាទេ"។ បាទនេះផែនការរបស់គាត់ តែត្រង់គាត់ធ្វើបានឬមិនបាន ខ្ញុំមិនដឹង ដែរតែក្រោយមកវាត្រូវតែគាត់ជម្លៀសពិតមែនហ្នឹងហើយ។ ខ្ញុំមិនដឹងថាម៉េចវានៅក្នុងអំឡុងហ្នឹងវា--

**ស៖** លោក នូ មោក ចម្លើយតាមរយៈការបកប្រែគឺថា លោកនិយាយថាខ្ញុំមិនដឹងពីសេចក្ដីសម្រេចរបស់ពួកគេទេនៅពេលនោះ។ ដូច្នេះលោកក៏មិនបានឆ្លើយឲ្យបានពិតប្រាកដ។

*(សម្រាករយៈពេលខ្លី)*

បាទ ខ្ញុំសូមសួរលោកបន្តទៅទៀត។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថា តាម៉ុក ដែលនិយាយអំពី -- តើតាម៉ុក ដែលនិយាយថាម៉េចដែរចំពោះខ្មែរមកពីទីក្រុងហាណូយនោះ យើងហៅថាខ្មែរហាណូយនោះ?

[១០:៣៦:០០]

**ឆ៖** ខ្មែរដែលមកជួយនៅកម្ពុជា ខ្មែរអង្កាល់ហ្នឹង ខ្មែរតស៊ូហ្នឹង គេហៅថា យៀកមិញ តស៊ូ។ ថាយៀកណាមមកជួយនៅកម្ពុជា។ អ៊ីចឹងទេខ្មែរប៉ុន្មាន១ពាន់ -- ២.០០០មិនដឹង ៣.០០០មិនដឹង។ អ្នកដែលចប់ការតស៊ូ គេទៅស្រុកយួន ហ្នឹងហើយទៅនៅស្រុកយួន ប្រហែល៣.០០០។ ក្រោយមកទៀតដែលចលនាកើតឡើង ដែលវាផ្ទុះខាងតស៊ូនៅកម្ពុជានេះ ក៏គេបញ្ជូនកងទ័ពខ្មែរប៉ុន្មានមកហ្នឹងមានទាំងសាក់កាដូ មានកាំភ្លើងអាកា មានទាំងកាំភ្លើងខ្លី គ្រប់គ្នា។ ហើយចូលមកប្រទេសកម្ពុជានេះ ចែកការដឹកនាំតាមភូមិមួយៗ។ ជាអ្នកជំនាញការ អ្នកខាងយោធា ដែលគេរៀនសូត្រខាងវៀតណាម អាហ្នឹងចែកទៅខាងយោធា។ រួចខាងផ្នែកដឹកនាំបង្កបង្កើនផល ផ្តល់នូវស្បៀង ធ្វើសង្គ្រាមហ្នឹងមួយផ្នែកទៅគិតទៅបីផ្នែក។

ពេលដែលនៅក្នុងសមរភូមិដែលត្រូវវ៉ៃទាហាន លន់ នល់ ក្រោយមកទៀតគេប្រមូល ជាផែនការ ប៉ុន្តែគ្រាន់តែថា គេប្រមូលជំនាញការយៀកណាម អំ! ខ្មែរនៅវៀតណាមហ្នឹង ទាំងនៅក្នុងឃុំក៏មានជំនាញការ នៅក្នុងស្រុកក៏មានជំនាញការ នៅខាងផ្នែកយោធាក៏មានជំនាញការដឹកនាំ។ អ៊ីចឹងដល់ពេលគេប្រមូលអ្នកទាំងនោះដែលប្រមូលទៅហ្នឹងវាបាត់អស់រលីងទៅអ៊ីចេះ ហ្នឹងហើយ មិនដឹងជាទៅណា ប្រហែលជាង ៣.០០០ហ្នឹង ហៅថា ២.០០០លើសទៅចុះ។ ហ្នឹងខ្ញុំបានប៉ុណ្ណឹង មិនដឹងគេយកទៅដល់ណាមកណា គឺខ្ញុំអត់បានដឹងទេ ដឹងតែគេប្រមូលយកបាត់ទៅ។ វាអត់ឃើញមកត្រឡប់មកវិញ។ សូមមានយោបល់ អត់ប៉ុណ្ណឹង ដែលបានដឹង ហើយដើរផ្ទាល់ជាមួយគ្នាហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ តំណាងសហព្រះរាជអាជ្ញា។ អរគុណលោកសាក្សី ឥឡូវដល់ម៉ោងសម្រាក ហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះសម្រាកក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណច្រើនលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក នូ មោក មុនពេលឈប់សម្រាក លោកបានរៀបរាប់អំពីខ្មែរហាណូយ។ សំណួរដំបូងរបស់ខ្ញុំ គឺតើជាគំនិតរបស់នរណាដែរ ដែលឲ្យប្រមូលផ្ដុំខ្មែរហាណូយ២.០០០ ទៅ៣.០០០នាក់នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់នោះទេ ប្រហែលជាការយល់ច្រឡំ ឬយ៉ាងណា។ ពាក្យថា ខ្មែរហាណូយនេះ ព្រះរាជអាជ្ញាគាត់លើកឡើងពាក្យ "ហាណូយ" តែសាក្សីឆ្លើយថា "ខ្មែរវៀតមិញ" មិនមែនខ្មែរហាណូយទេ។

[១១:០៣:០០]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

សូមអធ្យាស្រ័យ មេធាវីការពារក្ដីលើកឡើងត្រឹមត្រូវហើយ។

**ស៖** តើជាគំនិតនរណាគេដែរ ដែលឲ្យគាត់ប្រមូលខ្មែរវៀតមិញនោះ?

**លោក នូ ម៉ៅ៖**

**ឆ៖** ត្រង់ហ្នឹង ដែលគេឲ្យខ្មែរយៀកមិញដែលមកជួយនៅកម្ពុជា ដែលធ្លាប់បានធ្វើសង្គ្រាមកន្លងមក។ អ៊ីចឹងគេត្រឡប់ទៅវិញ ដល់ពេលដូចថាគណៈជាតិ។ គណៈជាតិមុតគាហាហ្នឹង កាលនោះវា វៀតណាមក៏ចូលមកជាជំនាញការធ្វើសឹកសង្គ្រាមជាមួយ -- និយាយរួមទៅថាបារាំង-- ហើយវាថាតស៊ូ។ អ៊ីចឹងទ័ពយៀកមិញ ខ្មែរដែលគេឲ្យមកនេះ ខ្ញុំមិនដឹងថាអ្នកណាឲ្យមកនោះទេ ខ្ញុំមិនបានដឹង។ ប៉ុន្តែគ្រាន់តែការមកនេះ គេដាក់ឲ្យនៅក្នុងជំនាញការដូចខ្ញុំបានអធិប្បាយពីខាងដើមហើយ ថាទៅតាមតំបន់ គណៈឃុំ គណៈស្រុក គណៈខេត្ត ដែលគេវាយ។ វាយខ្មែរដែលពីហាណូយមកធ្លាប់បានធ្វើសង្គ្រាមជាមួយ វ៉ៃជំនាន់ហ្នឹង វាមិនទាន់មានសង្គ្រាមធំដុំទេ អត់មានគ្រាប់បែកទេកាលនុ៎ង។ អ៊ីចឹងមកដាក់នៅក្នុងកម្ពុជាយើងនេះ ៣.០០០នេះ វាឲ្យធ្វើជាជំនាញនៅក្នុងឃុំ នៅក្នុងស្រុក នៅក្នុងតំបន់នៅក្នុងអង្គការ អង្គការលើ។ តែខ្ញុំភ្លាប់មិនបានដែរទេរឿងអង្គការលើៗហ្នឹង មិនដឹងលើកម្ពស់ប៉ុន្មានទៅទៀតទេ? គ្រាន់តែថាអង្គការលើ។

[១១:០៤:៤៣]

អ៊ីចឹងក្រោយមកខាងអង្គការលើហ្នឹងឲ្យប្រមូលជំនាញការ តាំងឃុំរហូតទៅដល់ស្រុក, ស្រុកដល់តំបន់នោះប្រមូលយកឲ្យអស់។ រួចប្រមូលទៅហ្នឹង គឺថាទៅលើ យកទៅលើឲ្យទៅរៀនសូត្រដើម្បីឲ្យជំនាញការដែលមកពីស្រុក អ៊ែនៃ! ខ្មែរយៀកមិញហ្នឹង។ កាលនោះទៅរៀន វាបាត់ឈឹងទៅមិនដឹងជាអត់បានត្រឡប់មកវិញផង។ បើតាមប៉ាន់ស្មានរបស់ខ្ញុំប្រហែលជាស្លាប់អស់ ហើយវាយកទៅសម្លាប់ទេ មិនមែនឲ្យទៅរៀនសូត្រហើយយកកម្លាំងជំនាញការមកពីហាណូយនោះទេហ្នឹងហើយ។

អ៊ីចឹងបានន័យថាពិតជាស្លាប់ហើយ តែស្លាប់មិនដឹងនៅទីកន្លែងណា ខ្ញុំអត់បានដឹងដែរទេ។ សូមអស់ប៉ុណ្ណឹង។

**ស៖** នៅពេលដែលពួកគេត្រូវបានប្រមូលនោះ តើគេប្រមូលបុរសទេ ឬក៏យ៉ាងម៉េច?

**ផ៖** អត់មានស្រីទេ ដែលជាង ៣.០០០? ឬក៏៣០០ ទេ? -- ២០០០ជាងទេ អត់មានស្រីទេ មានតែបុរសដែលគេយកទៅហ្នឹង។ ខ្ញុំដែលបានដឹងគឺដឹងតែប៉ុណ្ណឹង មិនដឹងជាយកទៅឯណា អត់ឃើញត្រឡប់មកវិញផង វាថាទៅអង្គការលើៗទៅសិក្សារៀនសូត្របំពេញនូវវិជ្ជាខាងក្បួនយោធា។ រួចស្រាប់តែយកអស់រលីងទៅមិនដឹងជាទៅស្លាប់ ឬក៏ទៅឯណា ខ្ញុំមិនបានដឹងដែរប៉ុណ្ណឹង។ សូមអធ្យាស្រ័យ សូមអស់។

[១១:០៨:៣៥]

**ស៖** ខ្ញុំសួរអំពីឆ្នាំ១៩៧៤វិញម្តង។ លោកបានលើកឡើងអំពីការយល់ឃើញរបស់ តាម៉ុក ថា ផែនការជម្លៀសប្រជាជនទីក្រុងភ្នំពេញនោះយ៉ាងម៉េចដែរនៅពេលនោះ? លោកបានលើកឡើងការយល់ឃើញរបស់ ជូ ជេត អំពីផែនការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញផងដែរ។ តើលោកធ្លាប់បានដឹងដែរឬទេ ផែនការជម្លៀសរបស់មេដឹកនាំ ក្រៅពី ជូ ជេត និងគំនិតរបស់ តាម៉ុក នោះតើលោកដឹងផែនការរបស់គេផ្សេងទៀតដែរឬទេ អំពីការជម្លៀសមេដឹកនាំផ្សេងទៀត?

**ផ៖** ត្រង់ហ្នឹងខ្ញុំមិនបានដឹងទេ។ ហ្នឹងហើយ គេហៅថា ខ្ញុំវាត្រឹមថ្នាក់ឃុំបាទ មិនអាចបានដឹងដល់ពីរឿងថា តើ តាម៉ុក ហើយនិង តាស៊ី ហ្នឹងគាត់បាននិយាយលើកឡើងថាមួយមិនឲ្យជម្លៀសមួយឲ្យជម្លៀសនេះ។ ខ្ញុំគ្រាន់តែបានឮដែលគេទៅប្រជុំបាទ អ្នកដែលចូលប្រជុំទាល់តែបក្ខជន ហ្នឹងបានគេឲ្យទៅចូលរួម។ រីឯខ្ញុំគ្រាន់តែជាសមាជិកឃុំមួយតូចទេ គ្រាន់តែបានគេប្រើទេ។ លើកឡើងនេះមិនមែនថាខ្ញុំនេះមិនចង់រាយការណ៍ជូនដល់លោកប្រធានឲ្យជ្រាបថា តើ តាម៉ុក ហើយនិង តាស៊ី ហ្នឹងវាយ៉ាងម៉េច ដែលមួយឲ្យជម្លៀស មួយមិនឲ្យជម្លៀសហ្នឹង ខ្ញុំមិនបានដឹង។ ខាងផ្នែកនយោបាយធ្លាប់រៀនដែរគាត់ហៅទៅ។ ប៉ុន្តែគ្រាន់តែត្រង់មួយប្រជុំនៅក្នុងសន្និបាតខាងបក្សមួយៗហ្នឹង ខ្ញុំអត់បានចូលរួមទេ។ ហ្នឹងសូមអធ្យាស្រ័យ ដឹងតែប៉ុណ្ណឹង។

[១១:១១:៣៤]

**ស៖** សូមអរគុណលោកប្រធាន គឺមានការបកច្រឡំបន្តិចនៅក្នុងសំណួររបស់ខ្ញុំ តាមការលើកឡើងរបស់ខាងសហព្រះរាជអាជ្ញាជាតិ។ លោក នូ មោក នៅក្នុងឆ្នាំ១៩៧៤ តើនរណាខ្លះគាំទ្រផែនការ

ឲ្យជម្លៀស និងនរណាខ្លះប្រឆាំងនឹងផែនការជម្លៀសនេះ ក្រៅពី តាម៉ុក និង ជូ ជេត នោះ?

**ឆ៖** ចិតប៉ុន្មាន? អឺ! ខ្ញុំដូចភ្លេចបាត់បង់ហើយ យូរពេក មិនអាចឆ្លើយបាន។ ដូចខ្ញុំបានជម្រាប វាអាចដឹង បានខ្ញុំបានជម្រាបបាន។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំអំមិញសួរសំណួរបើកទេ ដើម្បីទទួលយកចម្លើយ។ ដោយសារគាត់បានឆ្លើយ នៅក្នុងកំណត់ហេតុរបស់ ប៊ែន ឃៀរនិន។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតសួរដោយផ្អែកទៅលើកំណត់ ហេតុនេះតែម្តងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រអនុញ្ញាត ប៉ុន្តែគាត់មានបញ្ហាសុខភាព បានគាត់ប្រើប្រាស់នូវទឹកភេសជ្ជៈរួចសិនទៅ សឹមតាំងសំណួរបន្តទៀត។

*(សម្រាករយៈពេលខ្លី)*

[១១:១៣:២៣]

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំយោងលើកឯកសារអង់គ្លេសគឺលេខ 00419458, ខ្មែរគឺ00909936, បារាំង 00893546។ ឯកសារនេះបានរៀបរាប់ដូចតទៅ “នៅក្នុងឆ្នាំ១៩៧៤ទេ -- នៅពេលនោះគឺថាគេរៀបចំ ផែនការចាប់យកទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនទីក្រុងភ្នំពេញ។ អ្នកខ្លះគាំទ្រឲ្យជម្លៀស ហើយ មនុស្សមួយចំនួនទៀតមិនគាំទ្រឲ្យមានការជម្លៀសប្រជាជននោះឡើយ។ ស៊ី មិនចង់ឲ្យមានការជម្លៀស ប្រជាជននោះឡើយ។ ហើយ ហ៊ូ នឹម ក៏មិនចង់ឲ្យមានការជម្លៀសប្រជាជនផងដែរ”។ បន្ទាប់មកនៅ ក្នុងរង្វង់ក្រចក គេដាក់ថា “ហ៊ូ យន់?”។ ម៉ុក និងខៀវ សំផន គាំទ្រឲ្យមានការជម្លៀសប្រជាជននៅក្នុង ឆ្នាំ១៩៧៤”។ លោក នូ មោក តើលោកនឹកឃើញទេ? នៅក្នុងពាក្យនេះ គេប្រើថា “ម៉ុក និង ខៀវ សំផន គាំទ្រឲ្យមានជម្លៀសប្រជាជននៅក្នុងឆ្នាំ១៩៧៤”។ តើលោកនឹកឃើញទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំបាទ អត់នឹកឃើញទេ ខ្ញុំបាទ។ វាបាត់បង់--

**ស៖** តើលោកនៅចាំទេ? មេបញ្ជាការអនុសេនាធំម្នាក់ឈ្មោះ ម៉េត?

**ឆ៖** ខ្ញុំស្គាល់អត់ស្គាល់មេបញ្ជាការ ម៉េត ហ្នឹង។ អត់ស្គាល់។

[១១:១៦:៤៦]

**លោក ឃីត វេឃ័ន័រ៖**

លោកប្រធានជាថ្មីម្តងទៀត ខ្ញុំសួរសំណួរបើកដូចគ្នាដែរ ហើយនៅក្នុងហ្នឹងគឺថាមានព័ត៌ -- នៅក្នុងឯកសារមានព័ត៌មានលម្អិត។ ដូច្នេះសូមអនុញ្ញាតបន្តសួរពាក់ព័ន្ធទៅនឹងឯកសារនេះបន្តទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឃីត វេឃ័ន័រ៖**

**ស៖** ដើម្បីឲ្យយើងតាមទាំងអស់គ្នាបាន អង់គ្លេសគឺ 00419465, ខ្មែរគឺ 00909944, បារាំងគឺមានលេខ 00893551។

ឯកសារនេះបានរៀបរាប់ដូចតទៅ ខ្ញុំសូមដកស្រង់សម្តី "ហ៊ូ យន់ មិនចង់ឲ្យមានការជម្លៀសទីក្រុងភ្នំពេញនោះទេ។ ខ្ញុំបានឮចំណុចនេះពីមេបញ្ជាការ និងទាហាន។ ក្រោយមកមេបញ្ជាការម្នាក់ឈ្មោះ ម៉េត នេះគឺត្រូវបានចាប់ខ្លួន គឺមេបញ្ជាការកងអនុសេនាធំ ហើយគាត់ក៏បានស្លាប់"។ បាទ ឈ្មោះ ខ្ញុំសូមបញ្ជាក់ឈ្មោះឡើងវិញ ឈ្មោះគឺ ម៉ាន គឺគាត់បានស្លាប់។ តើលោកនៅចាំទេឈ្មោះ មេបញ្ជាការឈ្មោះ ម៉ាត?

**លោក នូ ម៉ៅ៖**

**ឆ៖** ម៉ាត់ ទេយ៉ាង មិនមែន ម៉ាត ទេ។ មាន ម៉ាត់ ដែលគាត់ត្រូវស្លាប់ហ្នឹង ម៉ាត់។

[១១:១៩:១៦]

**លោក ឃីត វេឃ័ន័រ៖**

ដើម្បីឲ្យយើងយល់ច្បាស់ទាំងអស់គ្នា គឺខ្ញុំសូមអនុញ្ញាតឲ្យមេធាវីប្រឹក្សាសាក្សីនេះ ឲ្យបើកមើលឯកសារ ត្រង់ទំព័រដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញទៅ។ ខ្មែរទំព័រលេខ 00909944, នៅជួរទី៣ ឬទី៤ នៃទំព័រហ្នឹង គឺឃើញមានសរសេរជាភាសាខ្មែរ ដែលសរសេរឈ្មោះរបស់មេបញ្ជាការអម្បាញ់មិញនេះ គឺឈ្មោះ សរសេរ ដាក់លើហ្នឹងថា ឈ្មោះ ម៉ាត។ ដូច្នេះសូមឲ្យមេធាវីប្រឹក្សាសាក្សីនេះជួយចង្អុលបញ្ជាក់ប្រាប់ទៅ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យៗលោកមេធាវីប្រឹក្សាសាក្សីអាចជួយគាត់បន្តិច ជួយគ្រាន់តែរកមើលឈ្មោះនៅក្នុងទំព័រ ERN អំមិញហ្នឹង ហើយបន្ទាត់ទី៤ មើលពីលើមក។

**លោក នូ ម៉ៅ៖**

**ឆ៖** "មេបញ្ជាការឈ្មោះ ម៉ាត ដែលជាមេបញ្ជាការកងអនុសេនាធំ (កង១២០) គាត់បានស្លាប់។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជា--" បានដឹងហើយ ទាហាន ឋានៈបញ្ជាការនៅតាំងពោធិ៍ ខាងកើត ស្រុកកំណើតតាំងពោធិ៍។

[១១:២១:២៦]

**សួរដោយលោក ឃើត វេយ៍ន័រ៖**

**ស៖** តើលោកធ្លាប់និយាយជាមួយនឹងមេបញ្ជាការឈ្មោះ ម៉ាត នេះនិយាយអំពីឈ្មោះ ហ៊ូ យន់ និងមេដឹកនាំផ្សេងទៀតដែរឬទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ហ៊ូ យន់ គាត់មកធ្វើសន្និបាតនៅវត្តតាំងពោធិ៍ ហៅវត្តតាំងពោធិ៍អ៊ីចឹងទូទៅ។ នៅក្នុងនោះមានសមាជិកច្រើនដែរ ដែលគាត់មកប្រកាសនៅកន្លែងហ្នឹង។ គាត់ថា ទាមទារពីរឿងបញ្ហាគាត់ប្រឆាំងនឹងការជម្លៀសប្រជាជន។ បាទ គាត់មិនព្រមឯកភាពឲ្យជម្លៀសប្រជាជនពីក្រុងភ្នំពេញទេ ហ្នឹង។ ហ្នឹង ហ៊ូ យន់ ហ្នឹងហើយ។ រួចគាត់បាត់ខ្លួនមិនដឹងទៅឯណាមកណា លែងមានដឹងថាគាត់នៅត្រង់ណោះត្រង់ណោះ ខ្ញុំអត់បានដឹងដែរទេ។ បាទ ហ្នឹងនៅវត្តតាំងពោធិ៍ គាត់ធ្វើមហាសន្និបាតហៅក្រុមអង្គការឃុំ ស្រុក តំបន់អ៊ីចឹងទៅមកជួបជុំ។ ដែលគាត់ប្រកាសហ្នឹង គាត់ថា ហ៊ូ យន់ គាត់មិនឲ្យជម្លៀសប្រជាជនពីទីក្រុងភ្នំពេញទេ។ ក្រោយមកទៀត ខ្ញុំអត់បានដឹងដែរតែមិនដឹងគាត់ស្លាប់ ឬក៏គាត់រស់ទេ វាបាត់ទៅ ដោយសន្និដ្ឋានមិនបាន។ ខ្ញុំបានដឹងប៉ុណ្ណឹង សូមអស់។

[១១:២៣:៤៨]

**ស៖** នៅក្នុងពេលនោះ គឺឆ្នាំ១៩៧៤ ដដែល។ តើលោកបានដឹងទេ ខៀវ សំផន នេះយល់យ៉ាងម៉េចដែរអំពីផែនការជម្លៀសនោះ?

**ឆ៖** ខៀវ សំផន -- តែខ្ញុំអត់សួរគាត់ទេ -- ខៀវ សំផន, ហ៊ូ នឹមៗ, ហ៊ូ យន់ ភ្លេចបាត់ទៀតហើយ។ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន -- ហ៊ូ នឹម --

**ស៖** សូមអធ្យាស្រ័យ ខ្ញុំសូមបញ្ជាក់សំណួររបស់ខ្ញុំឡើងវិញលោកសាក្សី។ ខ្ញុំមិនបានសួរថា តើលោកស្គាល់ ឬក៏មិនស្គាល់លោក ខៀវ សំផន នោះទេ។ ខ្ញុំចង់សួរលោកថាតើលោកបានដឹងពីប្រភពណាផ្សេងមកដែរឬទេ ថាតើលោក ខៀវ សំផន គាំទ្រផែនការជម្លៀស ឬក៏គាត់ប្រឆាំងនឹងផែនការជម្លៀស?

**ឆ៖** បើតាមជំហររបស់លោក ខៀវ សំផន គាត់ថាឲ្យជម្លៀស។ ជម្លៀសប្រជាជន។ ហ៊ូ យន់ គាត់មិនឲ្យជម្លៀសប្រជាជនទេ។ បើ ហ៊ូ នឹម ក៏គាត់មិនឲ្យជម្លៀសប្រជាជនដែរ ហ៊ូ នឹម។ អ៊ីចឹងដែលពេលគាត់ចូលទីក្រុងភ្នំពេញ។ គាត់ទៅស្លាប់នៅគុកទួលស្លែង ខ្ញុំបានទៅមើលនៅក្នុងរដ្ឋកម្ពុជាយើង។ គាត់ថាអក្សរយកឈាមសរសេរនៅសាលាទួលស្លែងហ្នឹង អាបណ្ដោយអាវែងហ្នឹង ហើយនិងឃាតកម្មនៅអាមុខហ្នឹងមាន -- អ៎! ជីកដីហើយព្យួរជើងឡើងលើ ទម្លាក់ទៅក្រោម នៅគុកទួលស្លែង។ ហើយបើមួយជំនាខាងណេះ ហ្នឹងធ្វើទារុណកម្ម ដកទាំងក្រចក ដេក ដាក់ខ្នោះជើងដៃ ធ្វើទារុណកម្ម មានតាំងពីក្អែប មានតាំងពីខ្ទួយទាំងអស់ហ្នឹងហើយ។ ហ្នឹងដែលសម័យដែលរដ្ឋកម្ពុជាដែលចូលមកហ្នឹង ដែលរដ្ឋកម្ពុជាឲ្យខ្ញុំទៅមើលកន្លែងគុកទួលស្លែង។ មហាៗសម្លាប់ហ្នឹងហើយ និយាយអ៊ីចេះតែម្ដង។ ដែលខ្ញុំឃើញ ខ្ញុំគួរឲ្យព្រឺព្រួចតែម្ដង។ គ្រាន់តែឃើញស្លុត ចង់បាត់ស្មារតី។ សូមអស់។

[១១:២៧:៤៦]

**ស៖** ខ្ញុំគ្រាន់តែចង់បញ្ជាក់ចម្លើយដែលលោកឆ្លើយពីរបីនាទីមុននេះបន្តិច។ តើខ្ញុំស្ដាប់ឮត្រឹមត្រូវដែរឬទេ តាមការឆ្លើយរបស់លោក។ លោកឆ្លើយថា ហ៊ូ យន់ គឺគាត់ប្រឆាំងនឹងផែនការជម្លៀស ក៏ប៉ុន្តែ ខៀវ សំផន គឺគាត់គាំទ្រផែនការឲ្យជម្លៀស។ តើលោកឆ្លើយអ៊ីចឹងដែរឬទេ?

**ឆ៖** បាទៗ ខ្ញុំឆ្លើយថាអ៊ីចឹង។

**ស៖** តើធ្វើម៉េចទើបលោកបានដឹងថា ខៀវ សំផន ហ្នឹង គាត់គាំទ្រផែនការជម្លៀស?

**ឆ៖** ខ្ញុំដែលបានដឹងហ្នឹងនៅក្នុងធ្វើសន្និបាតនៅវត្តតាំងពោធិ៍ តែគ្រាន់ខ្ញុំអត់ស្គាល់គាត់ទេ, ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម។ ខ្ញុំអត់ស្គាល់ទេ ទាល់តែគេថាមកធ្វើសន្និបាតនៅតាំងពោធិ៍ហ្នឹង។ អ៊ីចឹងអង្គការលើ ខ្ញុំក្ដាប់មិនបាន ខ្ញុំមិនដឹង ក្រោយមកបានខ្ញុំដឹង។ ដឹងយ៉ាងម៉េច? ដឹងថាដែលអង្គការធំ គឺសាឡុត ស ហ្នឹងហើយ សាឡុត ស ដែលចេញក្រោយមកដែលបែកភ្នំពេញនោះ។ សាឡុត ស ហៅ ប៉ុល ពត។ នេះខ្ញុំដឹងគឺដឹងប៉ុណ្ណឹង។ ពីដើមឡើង -- អ៎ ពីដើមឡើយនៅក្នុងសង្គ្រាមអត់ស្គាល់ទេ។ បាទខ្ញុំអត់ស្គាល់ទេ។ ដែលក្រោយមកទៀតបានដឹងថា សាឡុត ស ជា ប៉ុល ពត។ អស់ ខ្ញុំអត់មានអីដឹង

តទៅទៀតបាន មានដឹងតែប៉ុណ្ណឹង។

[១១:៣០:១៧]

**ស៖** សូមអរគុណ។ ខ្ញុំសូមសង្កត់ធ្ងន់នៅក្នុងឆ្នាំ១៩៧៤ដដែល។ លោកបានឆ្លើយ-- នៅពេលដែលលោកឆ្លើយក្នុងថ្ងៃនេះអំពីស្រុកឧដុង្គ។ ខ្ញុំសូមដកស្រង់សម្ដី៖(សូមលោកចាំបន្តិច) លោកបានឆ្លើយពីខាងដើមថា ឧដុង្គត្រូវបានគេវាយឧដុង្គ ហើយឈ្លើយសឹកត្រូវបានគេជម្លៀសទៅទិសបស្ចិម។ ហើយមនុស្សជាច្រើននាក់ដែរពីឧដុង្គហ្នឹងត្រូវបានគេជម្លៀសទៅទិសបស្ចិមផងដែរ។ សំណួររបស់ខ្ញុំចង់សួរដូចតទៅថា តើធ្វើម្ដេចលោកបានដឹងរឿងហ្នឹង? ធ្វើម្ដេចលោកដឹងរឿងដែលកើតឡើងនៅឧដុង្គទៅ? ហើយធ្វើម្ដេចទើបលោកដឹងអំពីការជម្លៀសប្រជាជនចេញពីឧដុង្គនេះទៅ?

**ឆ៖** កាលហ្នឹងខ្ញុំនៅខាងឃុំជើងរាស់ ស្រុកឧដុង្គជាមួយគ្នា។ អ៊ីចឹងគេថ្នាក់លើគេលើកឡើងថាយើងត្រូវទទួលប្រជាជនពីឧដុង្គ ស្រុកឧដុង្គ។ ត្បិតអីកាលនុំងមានបងប្អូនវៀតណាម មាន តាម៉ុក ចូលវាយលុកជាមួយគ្នា។ ដល់អ៊ីចឹងវារ៉ៃឈ្នះទាហាន លន់ នល់ ទៅចាប់តាំងពីឈ្លើយសឹក ប្រមូលជម្លៀសប្រជាជនថាប្រជាជនទៅលើ បញ្ជូនទៅតាមផ្លូវអមលាំងហ្នឹង។ ដែលជម្លៀសហ្នឹងទៅលើមិនដឹងប៉ុន្មានលើៗហ្នឹង? ខ្លះថាទៅដាក់នៅតាំងពោធិ៍ -- វត្តតាំងពោធិ៍ ឬក៏ត្រពាំងក្រោយ។ កន្លែងហ្នឹងជាកន្លែងដុះតែព្រិចទេ មានតែព្រៃទេ រកស៊ីជីកតែក្ដិសដំឡូងអីទេ ប្រជាជនកាលនុំងដែលជម្លៀសទៅអត់មានបាយមានទឹកអីទេ។ អ៊ីចឹងងាប់ពីព្រោះអត់បាយក៏ងាប់ ស្លាប់ព្រោះអត់បាយហូរហែ។ ក្រោយមកគាត់បានសង្គ្រាមដែលត្រូវវាយលុកចូលទីក្រុងភ្នំពេញបានគាត់រត់ត្រឡប់មកវិញ មកស្រុកកំណើតរបស់គាត់វិញរដ្ឋកម្ពុជានេះ។ សូមអស់តែប៉ុណ្ណឹងហើយ។ ខ្ញុំចេះតែភ្លេចការចងចាំហ្នឹង។ ការលើកឡើងត្រង់ណាដែលខ្ញុំបានដឹង គឺខ្ញុំបំភ្លឺជូនទាំងអស់ជាសាក្សីដឹងឮនៅក្នុងពេលនោះ។ ខ្ញុំអស់ហើយមានតែប៉ុណ្ណឹងទេ។

[១១:៣៤:០១]

**ស៖** គឺខ្ញុំនឹងព្យាយាមផ្ដល់នូវព័ត៌មានបន្ថែមទៀតទៅដល់លោក។ លោកបានលើកឡើងថាលោករស់នៅក្នុងស្រុកឧដុង្គនៅពេលដែលប្រជាជនត្រូវបានជម្លៀសពីស្រុកឧដុង្គ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវនោះហើយ ដែលចម្លើយរបស់ខ្ញុំឆ្លើយនោះគឺខ្ញុំដឹង ត្រឹមត្រូវ។

**ស៖** លោកបាននិយាយថា ប្រជាជនខ្លះត្រូវបានគេជម្លៀសចេញទៅ។ ខ្ញុំសូមសួរលោក តើលោកខ្លួនឯងនេះបានឃើញមនុស្សដែលគេជម្លៀសចេញពីឧដុង្គនេះដោយផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** ខ្ញុំអត់បានឃើញផ្ទាល់ទេ តែគ្រាន់តែគណៈឃុំដែលគេលើកឡើងទៅប្រជុំ។ ថានៅស្រុក

ឧដុង្គមានកងទ័ពវៀតណាម ហើយនិងកងទ័ពខ្មែរបានវ៉ៃនៅកងទ័ព លន់ នល់ នៅក្នុងស្រុកឧដុង្គហ្នឹង។ អ៊ីចឹងដែលត្រូវជម្លៀសទៅ វាមានប្រជាជន វាមានឈ្លើយសឹក។ រួចប្រជាជនហ្នឹង យកទៅ ដូចខ្ញុំបានលើកឡើងពីខាងដើមនោះថា យកទៅចោលត្រឹមត្រពាំងត្រើញ តាំងពោធិ៍។ បាយក៏អត់ស្អីក៏អត់ដែរ។ ដឹងតែស្លាប់ដោយអត់បាយ។ អាហ្នឹងទៅតាមការប្រជុំដែលផែនការ ដែលគេថាជោគជ័យនៅក្នុងឃុំមួយៗដើម្បីប្រាប់ប្រជាជនថា កងទ័ពយើងបានវ៉ៃកងទ័ព លន់ នល់ បានជម្លៀសចេញពីទីក្រុង -- ចេញពីស្រុកឧដុង្គទៅលិច។ រួចខ្ញុំអត់បានឃើញទេ តែគ្រាន់តែអ្នកដែលបានហ្នឹងទៅនៅក្នុងឃុំមួយៗដើម្បីគេបំផុសថា យើងជោគជ័យ។ ហ្នឹងហើយ តាមគណៈឃុំ តាមតំបន់ ជោគជ័យឈ្នះនៅឧដុង្គ។ ជម្លៀសប្រជាជនទៅខាងលើ ទាំងទាហាន ទាំងប្រជាជនយកទៅនៅត្រពាំងត្រើញ នៅក្នុងព្រៃ។ និយាយរួមនៅក្នុងព្រៃតែម្តង អត់មានភូមិ មានស្រុក។ ដែលខ្ញុំដឹងហ្នឹងប៉ុណ្ណឹង ហ្នឹងហើយ ដែលឲ្យផ្នែកកងទ័ពជម្លៀសមកហ្នឹងក៏ខ្ញុំអត់បានឃើញដែរទេ។ ប៉ុន្តែគ្រាន់តែគេឲ្យដឹងតាមទៅតាមភូមិមួយៗដែលគេប្រជុំថាកងទ័ពយើងបានជ័យជម្នះវ៉ៃនៅឧដុង្គ ទាហាន លន់ នល់។ ខ្ញុំដែលបានដឹងហ្នឹងគឺប៉ុណ្ណឹងទេ។

[១១:៣៧:៤៧]

**ស៖** ក្នុងពេលជម្លៀសប្រជាជនចេញពីឧដុង្គទៅនោះ តើលោកមានមិត្តភក្តិ ឬក៏សាច់ញាតិរស់នៅឧដុង្គនោះទេ នៅក្នុងពេលដែលគេជម្លៀសពួកគេចេញទៅនោះ?

**ឆ៖** មានខ្លះហ្នឹងហើយ បងប្អូនជីដូនមួយដែលនៅភូមិខ្ញុំជាង ជិតឧដុង្គហ្នឹងក៏គេជម្លៀសយកទៅអស់។ ទៅលើៗ ប៉ុន្តែគ្រាន់តែគាត់អត់បានស្លាប់ទេ គ្រាន់តែគេជម្លៀសគាត់ទៅនោះ។ អ៊ីចឹងដល់តែពេលនេះត្រឡប់មកវិញ កងទ័ពខាង លន់ នល់ ហ្នឹងដែលកាន់កាប់ហ្នឹង ក្រោយមកទៀតដែលយកទាហានមកដាក់ការពារខ្សែក្រវាត់នៅឧដុង្គថែមទៀតនោះ កងទ័ព លន់ នល់។ អ៊ីចឹងដែលជម្លៀសមុនវាផុតកន្លងទៅហើយ។ ក្រោយមកទៀត បានរៀបចំប្រព័ន្ធខ្សែក្រវាត់ដើម្បីការពារនៅឧដុង្គ។ ហ្នឹងខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេ ជូ ជេត នៅម្តុំណាដែរ នៅពេលដែលគេជម្លៀសឧដុង្គនោះ?

**ឆ៖** ជូ ជេត នៅឯលើឯណោះ នៅភូមិភាគខាងនិរតីនៅក្រោយឯណោះ។ រឿង តាម៉ុក ហើយនិងបងប្អូនវៀតណាមហ្នឹង បាទ ប្រមូលទ័ពចូលវ៉ៃឧដុង្គ។ ហើយខាងផ្នែកនយោបាយ លោក ជូ ជេត នៅខាងនិរតីនៅហ្នឹង ហើយខ្ញុំអត់បានដឹងទេ។ គ្រាន់តែថា -- មិនប្រកែកទេ រឿង ជូ ជេត គឺមិនសប្បាយចិត្តនឹងជម្លៀសប្រជាជនទេ។ កាលណោះវាអត់ទាន់ជម្លៀសមែន ប៉ុន្តែគ្រាន់តែវាវ៉ៃ។ វ៉ៃកន្លែងណាគឺ

ជម្លៀសប្រជាជនកន្លែងហ្នឹង ទាំងកងឈ្លើយស្លឹកក៏ចាប់យកទៅ ទាំងប្រជាជនក៏វាយកទៅដែរ ទៅខាងលើ។ ទៅទី១ វាមិនមែនគិតគូរពីរឿងស្បៀងអាហារឲ្យប្រជាជនស៊ីទេ។ វាទៅចង់បង្អត់បាយ ដល់អត់បាយស្អែងស៊ីស្ពីស៊ីទៅ ស៊ីក្តួច ស៊ីគល់ប្រ៉ង់ក៏ស៊ីទៅ។ ហ្នឹងហើយតាម -- រឿងអង្ករ អារឿងស្លឹកគ្រៃអីអត់មែនទេ វាត្រូវតែងាប់ មិនវ៉ៃចោលមែន ប៉ុន្តែវាត្រូវងាប់។ តែខ្លះរស់ដែរ ខ្លះក៏បាត់ទៅ។ ខ្ញុំបានដឹងប៉ុណ្ណឹង។

[១១:៤១:១៦]

**ស៖** លោក នូ មោក លោកទើបតែបញ្ចេញពាក្យនេះទេ។ នៅពេលនោះ នៅពេលដែលទាហានមកដល់ គឺប្រជាជនត្រូវបានគេជម្លៀសចេញ។ តើលោកមានន័យថាម៉េច ថានៅទីណាក៏ដោយនៅពេលដែលទាហានមកដល់? តើលោកនិយាយតែសំដៅចំពោះខដុង្គមួយ ឬក៏និយាយចំពោះទីកន្លែងដដៃទៀតដែរ?

**ឆ៖** ខ្ញុំនិយាយសមរភូមិដែលត្រូវវ៉ៃនោះ។ អានេះតាមអ្នកដែលសែងគ្រាប់ ហើយក៏យកបាយវ៉ៃប៉ុន្មានកន្លែងណោះ ខ្ញុំក្តាប់វាមិនបានដែរ វាចូលជ្រៅដែរដោយសារវ៉ៃនុ៎ង ម្ល៉ោះហើយភ្លេចអស់ទៅហើយវាអត់ចងចាំ។ កន្លែងណាដែលខ្ញុំចងចាំ ខ្ញុំរាយការណ៍ជូន កន្លែងណាដែលបាត់បង់ទៅវាភ្លេចទៅច្រើនទៅ មិនដឹងរាយការណ៍ហ្នឹងជូនម៉េច បើវាភ្លេចភ្លាំងអស់ទៅហើយ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តចូលឆ្នាំ១៩៧៥ នៅពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ។ តើលោកបានស្តាប់ឮប្រជាជនដែលគេជម្លៀសចេញពីភ្នំពេញ គឺក្រោយពីពេលជម្លៀសហ្នឹងលោកបានស្តាប់ឮគេនិយាយថាម៉េចទេ?

[១១:៤៣:៣៦]

**ឆ៖** ប្រជាជនដែលនៅខាងក្រោយ ឬក៏ខាងមុខ ត្រូវតែជួយឧបត្ថម្ភគ្នា ដែលជម្លៀសទៅហ្នឹង។ ត្បិតអីឲ្យផុតចេញពីទីក្រុង។ កាលនុ៎ងវាដល់តែ -- អាហ្នឹងនិយាយវែងបន្តិចចុះ -- គេរៀបចំជម្លៀសទៅហើយបានពីទីក្រុងទៅ គេរៀបចំជាសហករណ៍។ ក្នុងឃុំមួយៗ គឺគេរៀបចំទៅតាមសហករណ៍ប្រមូលផ្តុំ ហើយខ្ញុំអស់សិទ្ធិហើយពេលនោះ វាឈឺផង។ គេយកខ្ញុំទៅឲ្យធ្វើសិប្បកម្ម។ អាហ្នឹងបើថាគឺចាកប្រធានក៏សូមឲ្យលោកចៅក្រមជួយបន្ថែមទៀតទៅ ថាទេត្រង់ហ្នឹងអត់ទាន់បានសួរទេ។ សូមអស់ហើយសម្រាប់មួយចំណែកហ្នឹង។

**ស៖** សូមអរគុណ។ បាទ ខ្ញុំសូមសួររបៀបនេះវិញ ក្រោយពីការជម្លៀសប្រជាជន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគី ខ្ញុំគ្រាន់តែសូមបញ្ជាក់ជម្រាបជូនលោកប្រធានថា ខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី យើងខ្ញុំត្រូវការពី ៣០នាទី ទៅ ៤០នាទី សូមលោកប្រធានជ្រាប។ សូមអរគុណ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់ជូនថា ខ្ញុំសួរបីទំព័រទៀតប្រហែលជាសួរ ១០នាទី ហើយនិង ១៥នាទីទៀត ក្រោយពេលសម្រាកបាយថ្ងៃត្រង់ ដោយសារខ្ញុំមានប្រធានបទបួនត្រូវសួរក្រោយឆ្នាំ១៩៧៥នោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៦:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ ដោយការតាំងសំណួររបស់សហព្រះរាជអាជ្ញាកន្លងមកនេះគឺថាមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១ ហេតុដូច្នេះភាពចាំបាច់ណាស់ដែលអង្គជំនុំជម្រះត្រូវការស្តាប់សំណួរបន្តទៀតតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា ក៏ដូចជាសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីស្វែងរកការពិតនៃរឿងក្តីនេះ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណច្រើនលោកប្រធាន។

[១១:៤៧:៣៧]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក នូ មោក ក្រោយពីពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ៧៥ តើលោកបានឮពាក្យសម្តីដែលគេនិយាយសំដៅលើប្រជាជនណាជាប្រជាជនថ្មី ប្រជាជនណាជាប្រជាជនចាស់ដែរទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** បាទ ត្រង់ហ្នឹងចែកជាប្រជាជនពីរ, ប្រជាជនថ្មី ហើយនិងប្រជាជនចាស់។ អ៊ីចឹងផែនការរបស់ខ្មែរក្រហមលើកឡើងថា "យើងត្រូវតែជម្លៀសប្រជាជនពីតំបន់ គ្រប់តំបន់ទាំងអស់។ ពីជើងរាស់ទៅកោះកុង, ពីកោះកុងមកជើងរាស់, ពីកំពង់ស្ពឺទៅកំពង់ឆ្នាំង, ពីកំពង់ឆ្នាំងមកកាន់ខាងកំពង់ស្ពឺ"។ អ៊ីចឹងប្រជាជនដែលជាមូលដ្ឋាន ប្រជាជនដែលជម្លៀសមកគឺគេចោទថា ប្រជាជនលន់នល់។ គេដាក់ឈ្មោះឲ្យអ៊ីចឹង។ អ៊ីចឹងយើងជម្លៀស មិនត្រឹមតែ លន់ នល់ -- អ៎! ប្រជាជនជម្លៀសពីទីក្រុងភ្នំពេញទេ សូម្បីតែប្រជាជននៅរំដោះហ្នឹងក៏វាជម្លៀសដែរ។ គ្រប់ហ្នឹងហើយ គ្រប់ភូមិទាំងអស់ សូម្បីតែភូមិខ្ញុំហ្នឹង ទាំងនៅទឹកហូតកំពង់ឆ្នាំង បងប្អូនខ្ញុំ មាខ្ញុំ ងាប់នៅទឹកហូតហ្នឹងច្រើនណាស់ពេលដែលជម្លៀសទៅ។ ហើយចំពោះខ្ញុំហ្នឹងទៀត គេនៅក្នុងសហករណ៍ខ្ញុំអស់សិទ្ធិ ហើយខ្ញុំវាត្រូវឈឺផង។ អ៊ីចឹងគេឲ្យខ្ញុំទៅកាន់នៅសិប្បកម្មធ្វើ ឲ្យយកគ្នា៤០ហ្នឹងហើយត្បាញល្ងៃ ខាងនារី, ខាងប្រុសឲ្យធ្វើរនាស់ នង្គ័ល រ៉ៃ ដែកផាល។ អ៊ីចឹងក្រោយមកទៀត -- តែឥឡូវខ្ញុំសូមជម្រាបតែប៉ុណ្ណឹងសិន ហើយចាំបន្តទៀត។ សូមអស់។

[១១:៥០:៤៣]

**ស៖** សូមអរគុណ។ លោកនិយាយអំពីការជម្លៀសប្រជាជននៅក្នុងភូមិភាគរបស់លោក។ តើពួកគេបានមកដល់នៅពេលក្រោយ ឬយ៉ាងណា នៅពេលប្រជាជនត្រូវបានគេជម្លៀសទៅកាន់ភូមិភាគដទៃនោះ?

**ឆ៖** សូមបន្តបន្តិច។ សូមបញ្ជាក់បន្តិចមក ខ្ញុំមិនដឹងអីខ្លះទេ អំមិញស្តាប់មិនបាន។
សូមបញ្ជាក់ម្តងទៀត។

**ស៖** លោកបានជម្រាបអំពីការជម្លៀសប្រជាជន ថាមានការជម្លៀសប្រជាជនទៅនៅភូមិភាគនិរតីរួចហើយ។ សំណួរខ្ញុំសួរថាយ៉ាងដូច្នេះ តើប្រជាជនទាំងនោះមកនៅពេលក្រោយ ឬយ៉ាងអីនៅពេលដែលគេជម្លៀសប្រជាជនទៅកាន់ភូមិភាគដទៃទៀតនៅទូទៅប្រទេសហើយនោះ ទើបគេជម្លៀសប្រជាជនមកកាន់ភូមិភាគនៅពេលក្រោយ ឬយ៉ាងណា?

[១១:៥២:១៤]

**ឆ៖** ពេលដែលឈ្នះ ចប់សង្គ្រាមហ្នឹង ដែលជម្លៀសប្រជាជនមកហ្នឹង ក៏គេរៀបចំផែនការធ្វើជាសហករណ៍ បាទ ធ្វើជាសហករណ៍មួយដើម្បីយើងជួយផ្តល់ដល់ប្រជាជនចាស់ -- អ៎! ប្រជាជននៅ

ទីក្រុងភ្នំពេញ ឧបត្ថម្ភ។ តែក្រោយមកទៀត ផែនការដែលថ្នាក់ដឹកនាំខាងលើនោះ គេថាមិនកើតទេ ត្រូវតែជម្លៀសប្រជាជន ហើយរៀបចំសហករណ៍ ដែលត្រូវឈ្នះហើយ យើងឈ្នះហើយត្រូវរៀបចំជាសហករណ៍ដែលយើងបានជ័យជម្នះ ហ្នឹងហើយដែលជម្លៀសមកនេះ។ ម្យ៉ាងគេរៀបរាប់ថាអ៊ីចេះ ខ្ញុំសូមបញ្ជាក់បន្តិចដើម្បីឲ្យថាគេអនុវត្តលើកឡើងប្រជុំនៅក្នុងសហករណ៍ គេថាលើកឡើងពីសម័យអង្គរនៅកម្ពុជាល្បីល្បាញនៅលើពិភពលោក តែដែលយើងឈ្នះហើយ តើយើងយកការអភិវឌ្ឍដែលយើងត្រូវជ័យជម្នះពីទីក្រុងភ្នំពេញហ្នឹង តើដាក់ក្នុងសម័យយើងហ្នឹង តើយើងដាក់ -- លើកឡើងទៅប្រជុំកូរ៉េខាងជើង។ កូរ៉េខាងជើងគេថា កូរ៉េខាងជើង យើងដាក់ថា -- ភ្លេចហើយ លើពិភពលោកៗ យើងវាត្រូវដាក់ឈ្មោះថា សញ្ញាសេះហោះ។

[១១:៥៤:៥០]

**ស៖** សូមទោសលោកសាក្សី លោក នូ មោក សូមអធ្យាស្រ័យ។ ខ្ញុំសូមសួរសំណួរមួយសំណួរទៀត ហើយក្រោយមកខ្ញុំនឹងដាក់សំណើសុំជូនអង្គជំនុំជម្រះ។ លោក នូ មោក ខ្ញុំមិនសួរលោកអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏ផ្នែកដទៃទៀតដែលគេជម្លៀសនៅខែមេសា ឆ្នាំ១៩៧៥នោះទេ សំណួរខ្ញុំនេះនិយាយអំពីពេលក្រោយបន្ទាប់ហ្នឹងមកទៀត។ ពេលក្រោយមកទៀត តើគេមានជម្លៀសប្រជាជនចេញពីភូមិភាគរបស់ខ្លួនមួយៗហ្នឹងទៅកាន់ភូមិភាគដទៃទៀតនៅក្នុងផ្ទៃប្រទេសដែរឬទេ?

**ឆ៖** ត្រង់ហ្នឹងមាន ជម្លៀសទៅតាមភូមិភាគ។ តែខាងនិរតីមួយតំបន់និរតីនេះវាជាប់រហូតដល់ជម្លៀសដល់កោះកុងទៅកំពង់ឆ្នាំង ទៅបាត់ដំបង។ សូមជូនអស់ប៉ុណ្ណឹង។

**ស៖** តើលោកមានដែលបានដឹងទេថាហេតុអ្វីបានជាគេជម្លៀសប្រជាជនទៅបាត់ដំបង?

**ឆ៖** ហ្នឹងជាផែនការខាង-- បើនិយាយទៅថាខាងលើគេដាក់ចុះ ត្រូវតែឲ្យជម្លៀសប្រជាជនកុំឲ្យវាច្របូកច្របល់ ឬក៏ប្រកាន់ប្រជាជនចាស់និងប្រជាជនថ្មី ដែលគេជម្លៀសទៅហ្នឹង ឬក៏គេបំបាត់រឿងរ៉ាវដែលកើតឡើងពីខាងដើម។ អាហ្នឹងខ្ញុំមិនទាន់យល់ដែរទេត្រង់ហ្នឹង សូមជម្រាបជូនអស់ប៉ុណ្ណឹង។

**ស៖** តើលោកមានគំនិតយ៉ាងម៉េចដែរ តើប្រជាជនដែលគេជម្លៀសទៅបាត់ដំបងហ្នឹងមានចំនួនប្រហែលជាប៉ុន្មានដែរ?

[១១:៥៧:៥៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតបសូមអញ្ជើញលោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំបានស្តាប់សំណួរមួយចំនួនពីខាងសហព្រះរាជអាជ្ញាសួរសំណួរ តើលោកយល់ឃើញថាលោកតាមគំនិតលោកយល់យ៉ាងដូចម្តេច? ការសួរបែបនេះខ្ញុំយល់ឃើញថា ហាក់បីដូចជាកំពុងតែការពារទៅដល់សាក្សីរូបនេះ ថាតើតួនាទីរបស់គាត់ជាសាក្សីគឺគាត់ត្រូវតែនិយាយ អ្វីដែលគាត់បានឃើញ បានឮ បានស្តាប់ដោយផ្ទាល់ក្នុងចន្លោះពី៧៥ទៅ ៧៩ តែប៉ុណ្ណោះ។ របៀបនៃ ការតាំងសំណួរនេះអនុញ្ញាតឲ្យសាក្សីនេះមានការយល់ដឹងអំពីរឿងរ៉ាវមុនឆ្នាំ៧៥ ជាដើម។ល។ ដូចជា ការសួរអំពីស-២១ អីជាដើម។ ដូច្នេះខ្ញុំយល់ថា រឿងនេះជារឿងមួយពេលក្រោយនោះទេ ហើយវាមិន ពាក់ព័ន្ធទៅនឹងអំឡុងពេលនៅក្នុងសំណុំរឿងនេះទេ។ ដូច្នេះ យើងខ្ញុំសូមឲ្យតំណាងសហព្រះរាជអាជ្ញា សួរសំណួរដែលច្បាស់ៗទៅកាន់សាក្សី ថាតើគាត់ពិតជាបានឃើញអ្វី បានស្តាប់ឮអ្វីនៅក្នុងអំឡុងចន្លោះ ពីឆ្នាំ៧៥ ទៅ ៧៩ ឬមុន ៧៥ នោះ?

**លោក ឃីត រេយ៍ន័រ៖**

**ស៖** ខ្ញុំសូមការអនុញ្ញាតបន្តទៅទៀតបើដូច្នេះទេ។ លោក នូ មោក យើងបាននិយាយអំពីបញ្ហា ដែលលោកបានបង្ហាញភស្តុតាងថា គេជម្លៀសប្រជាជនចេញពីភូមិភាគនិរតីទៅកាន់ខេត្តបាត់ដំបង។ តើលោកដឹងការជម្លៀសនេះដោយរបៀបណា?

[១១:៥៩:៥៥]

**ឆ៖** ខ្ញុំមិនដឹង ក្តាប់មិនបានទេចំនួនដែលយកទៅហ្នឹង។ ដែលគេជម្លៀសយកទៅហ្នឹងគេដឹក តាមផ្លូវដែកទេ ដែលយកទៅហ្នឹង ជម្លៀសទៅហ្នឹង ទៅបាត់ដំបង។ តែគ្រាន់ថារឿងហ្នឹងវា ខ្ញុំមិន ប៉ុណ្ណឹងវាស្តាប់គោលការណ៍ឲ្យច្បាស់លាស់អត់បាន ខ្ញុំវាដូច វាឈប់បម្រើនូវការងារនៅក្នុងឃុំ។ គេ ដាក់ខ្ញុំឲ្យទៅធ្វើសិប្បកម្ម។ ឲ្យខ្ញុំរាប់ ឲ្យខ្ញុំដឹងចំនួន ក៏ខ្ញុំអត់បានដឹងដែរ។ ហ្នឹងហើយខ្ញុំអត់បានដឹងថា ឥឡូវទៅកំពង់ឆ្នាំប៉ុន្មាននាក់ ឬក៏ទៅកោះកុងប៉ុន្មាននាក់ ឬក៏ទៅបាត់ដំបងប៉ុន្មាននាក់អីចឹងទៅ ខ្ញុំមិន-- កំពង់ឆ្នាំងអីអត់ដឹងរាប់យប់អីបានទេ ខ្ញុំវាអស់សមត្ថភាពជាសមាជិកឃុំ។ អីចឹងខ្ញុំវា -- គេទាត់ខ្ញុំចេញ ហើយនៅក្នុងពេលនោះ។ អីចឹងគ្រាន់តែបានដឹង ហើយនិងខ្ញុំសូមជម្រាបជូន កន្លងមកដែលខ្ញុំបាន ពាក់ព័ន្ធគ្រប់ជំនាន់ដែលនៅក្នុងប្រវត្តិរបស់ខ្ញុំនេះ ឃើញថាវាអស់សមត្ថភាពពេលដែលគេរៀបសហករណ៍ អត់មានសិទ្ធិអីតទៅទៀតទេ។ សូមអស់។

[១២:០១:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណលោកសាក្សី។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬអ្នកជំនាញ ឬកន្លែងណាមួយសមស្របសម្រាប់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់នេះ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងមួយសាមសិបនាទីរសៀល។ ហើយមេធាវីប្រឹក្សាសាក្សីសូមអញ្ជើញចូលរួមដូចគ្នា។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រងចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក នូ មោក មុនពេលសម្រាកពិសាបាយថ្ងៃត្រង់នេះ លោកបាននិយាយអំពីខេត្ត

បាត់ដំបង ហើយនៅពេលនុ៎ង គឺលោកនិយាយអំពីការជម្លៀសប្រជាជនដែលគេដឹកប្រជាជនទាំងនោះតាមរទេះភ្លើងទៅខេត្តបាត់ដំបង។ តើការជម្លៀសនេះ គឺអ្វីដែលលោកបានឃើញដោយផ្ទាល់ ឬក៏ស្តាប់ឮពីអ្នកដទៃប្រាប់លោក ពីជនដទៃប្រាប់លោក?

**លោក នូ ម៉ោះ**

**ឆ៖** បាទ ជម្លៀសប្រជាជនទៅបាត់ដំបង ខ្ញុំមិនបានឃើញផ្ទាល់ទេ តែគ្រាន់ថា គេជម្លៀសប្រជាជនទៅបាត់ដំបង កំពង់ឆ្នាំង តែប៉ុណ្ណឹងតែតើ ត្រង់ចំនួនប៉ុណ្ណោះប៉ុណ្ណោះ ខ្ញុំអត់បានដឹង ដែលជម្លៀសទៅនុ៎ង។ ត្បិតអីខ្ញុំនៅក្នុងសហករណ៍ ៗហ្នឹង នៅក្នុងឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលខ្ញុំអស់សមត្ថភាពហើយគេក៏ -- ខ្ញុំនេះវាត្រូវគេដកសិទ្ធិពីប្រធានសហករណ៍ឲ្យខ្ញុំទៅធ្វើសិប្បកម្មនៅវត្តចំបក់ ក្នុងនោះ ខ្ញុំបានដឹងដែលបងប្អូនខ្លួនហ្នឹងថា គេទៅ -- គេជម្លៀសទៅបងប្អូនទៅបាត់ដំបងកំពង់ឆ្នាំង។ អ៊ីចឹង ខ្ញុំបានដឹងប៉ុណ្ណឹង តែត្រង់ចំនួនប៉ុណ្ណោះប៉ុណ្ណោះអី ខ្ញុំមិនបានដឹងទេក្នុងពេលនោះ។ សូមអស់ប៉ុណ្ណឹងហើយ។

**ស៖** តើមានមិត្តភក្តិរបស់លោក ឬក៏សាច់ញាតិ ឬក៏អ្នកភូមិត្រូវបានគេជម្លៀសទៅបាត់ដំបងដែរឬទេ?

[១៣:៣៣:៤០]

**ឆ៖** សាច់ញាតិដែលជម្លៀសទៅបាត់ដំបង គឺជាសាច់ញាតិរបស់ខ្ញុំដែរ ទៅកំពង់ឆ្នាំង ទៅកំពង់លែងហ្នឹងក៏ជាសាច់ញាតិរបស់ខ្ញុំដែរ។ គេជម្លៀសទៅ ហើយបានដឹងទៅតាមដំណឹងដែលគេបានដឹង ប្រាប់ខ្ញុំ។ អ៊ីចឹង ខ្ញុំថាមិនដឹងជាយ៉ាងណាទេ ដែលជម្លៀសទៅហ្នឹង។ រំពឹងថា វា -- បើនិយាយពីរស់តិចណាស់ បើនិយាយពីស្លាប់វាៗច្រើន។ អ៊ីចឹងខ្ញុំដែលបានដឹងហ្នឹង គឺទៅតាមបងប្អូនដែលនៅក្នុងភូមិត្រពាំងធំ ដែលនៅក្នុងសហករណ៍ដែរ ដែលគេរាយការណ៍មក។ អ៊ីចឹងខ្ញុំបានដឹងទៅតាមដំណឹងបងប្អូនដែលនៅក្នុងភូមិត្រពាំងធំ កំណើតកើតជារបស់ខ្ញុំប៉ុណ្ណឹង។ សូមអស់ ដឹងប៉ុណ្ណឹង។

**ស៖** ប្រហែលជាសំណួរនេះវាពិបាកឲ្យលោកឆ្លើយហើយ។ ប៉ុន្តែលោកអាចជម្រាបអង្គជំនុំជម្រះបានទេ នៅពេលប្រជាជននិយាយអំពីការជម្លៀសប្រជាជនទៅកាន់បាត់ដំបងហ្នឹង តើនៅក្នុងឆ្នាំណាដែរ?

**ឆ៖** ខ្ញុំភ្លាប់ឆ្នាំអត់បានដែរ តែប្រជាជនដែលជម្លៀសមក គឺរួមជាមួយប្រជាជននៅខាងក្នុងហើយនិងខាងក្រៅដែលគេមករៀបចំជាសហករណ៍។ អ៊ីចឹងខ្ញុំបានដឹងតែប៉ុណ្ណឹងហ្នឹងហើយ។ ថាគេ

ជម្លៀសទៅហ្នឹង វារស់តិចណាស់ហ្នឹងហើយ វេទនា ដោយសារអី? បំបែកទៅជាកុំឲ្យមានការទាក់ទងរវាងប្រជាជន និងប្រជាជននេះ។ អ៊ីចឹងខ្ញុំដែលនៅក្នុងសហករណ៍ហ្នឹង វា -- គេដកសិទ្ធិរបស់ខ្ញុំហ្នឹងឲ្យទៅធ្វើសិប្បកម្មហ្នឹង អាហ្នឹងដឹងតាមខ្សែរយៈបងប្អូន ដែលគេជម្លៀសទៅហ្នឹង។ តែត្រង់ចំនួនប៉ុនណេះប៉ុណ្ណោះ គឺខ្ញុំក្តាប់អត់បានដែរទេ ត្បិតអីដឹងតាមដំណឹងសាច់ឈាមៗដែលឲ្យដំណឹងខ្ញុំហ្នឹង ខ្ញុំថាមិនដឹងយ៉ាងម៉េចទេអ៊ីចឹង។ ជម្លៀសទៅហ្នឹងប្រហែលជាមានស្លាប់ច្រើនជាងរស់ ខ្ញុំថាអ៊ីចឹង។ ខ្ញុំដឹងប៉ុណ្ណឹងដែលខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង។

[១៣:៣៦:៥៨]

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ខ្ញុំ ដោយសារពេលវេលា ខ្ញុំសូមសួរបើកចំហតែម្តង សូមបង្ហាញឯកសារដែលបានស្នើសុំពីមុនរួចមកហើយ ដើម្បីរំឭកដល់ការចងចាំរបស់សាក្សី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** ខ្ញុំយោងទៅលេខ ERN ជាអង់គ្លេសលេខ 00419463, ខ្មែរ 00909941, បារាំង 00893549។ ឯកសារនេះសរសេរដូចតទៅ៖ "ពីឆ្នាំ១៩៧០ ទៅដល់ ៧៥ ប្រជាជនគាំទ្រសង្គ្រាម ពីឆ្នាំ៧៥ ដល់ ៧៦ ប្រជាជនបាត់បង់ជំហររបស់ពួកគេ ពីព្រោះមានការជម្លៀសប្រជាជនចេញពីខេត្តកំពង់ស្ពឺទៅកាន់ខេត្តបាត់ដំបង និងចេញពីខេត្តកំពង់ស្ពឺ ទៅកាន់ខេត្តកោះកុង" បញ្ចប់ការដកស្រង់។

លោក នូ មោក ដោយជួយរំឭកទៅដល់ការចងចាំរបស់លោកអម្បាញ់មិញនេះ តើវាត្រឹមត្រូវទេ ឬក៏ថាលោកយល់ស្របទេដែលថា ពីឆ្នាំ៧៥ ដល់ ៧៦ គឺមានការនិយាយអំពីការជម្លៀសប្រជាជននេះគឺពី៧៥ ទៅ៧៦?

[១៣:៣៨:៤២]

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំបានដឹងៗត្រង់ដែលផែនការរបស់ខ្មែរក្រហមដែលរៀបចំជម្លៀសប្រជាជនទៅបាត់ដំបងនេះ ជាផែនការរបស់ខ្មែរក្រហមវាត្រូវតែធ្វើយ៉ាងម៉េចកុំឲ្យវាក្នុងគោលនយោបាយរបស់វាហ្នឹង ធ្វើយ៉ាងម៉េចកុំឲ្យមានការទាក់ទងរវាងប្រជាជនចាស់និងប្រជាជនថ្មី។ អ៊ីចឹងទេវាត្រូវតែជម្លៀសៗប្រជាជនពី

កំពង់ឆ្នាំងក៏មកកំពង់ស្ពឺ, ពីកំពង់ស្ពឺទៅកោះកុងក៏មាន, ពីកោះកុងមកកំពង់ស្ពឺក៏មាន។ អ៊ីចឹងការច្របូកច្របល់នេះ ខ្ញុំគ្រាន់តែបានឃើញថាប្រជាជនពេលនោះអ្នកនៅមូលដ្ឋានក៏ស្លាប់ អ្នកមកពីទីក្រុងក៏ស្លាប់បាទ។ អ៊ីចឹងបានថានយោបាយដែលការដឹកនាំរបស់ខ្មែរក្រហម វាមានទិសដៅដើម្បីសម្លាប់ប្រជាជនឯង។ ទាំងនេះបានជាខ្ញុំថា ខ្ញុំអត់មានសិទ្ធិ វាអស់សិទ្ធិ គេដកចេញ ហើយក៏ខ្ញុំហ្នឹងវាមានជំងឺក្អកធ្លាក់ឈាម មិនដឹងជាធ្វើអីកើត។ គេដាក់ឱ្យទៅធ្វើសិប្បកម្មនៅវត្តចំបក់ នៅក្នុងរោងតម្បាញ កម្លាំង៤០ ទាំងចាស់ ក្មេង ប្រុសស្រីទាំងអស់។ ខ្លះធ្វើផាល ខ្លះពុម្ពរ៉ើដី ខ្លះស្លរ៉ែដែក ខ្លះឈើ ខាងជាងឈើអាធ្វើជាផ្ទះតូចៗ ដើម្បីជាផ្ទះជួរ និយាយថារៀបចំសហករណ៍ហ្នឹង។ អ៊ីចឹងខ្ញុំដឹងតែប៉ុណ្ណឹង ដឹងថាធ្វើនេះធ្វើឱ្យវិនាសដល់ប្រជាជនទាំងមូលដ្ឋាន ទាំងប្រជាជនមកពីទីក្រុងភ្នំពេញ។ ជាផែនការរបស់ខ្មែរក្រហម ធ្វើយ៉ាងម៉េចកុំឱ្យវាផ្សាភ្ជាប់រវាងថ្នាក់ដឹកនាំ និងប្រជាជន រវាងមូលដ្ឋាននិងប្រជាជនដែលជម្លៀសមក។ អានេះជា -- មិនស្មានទេ។ ប៉ុន្តែដូចជាៗការពិតដែរ ត្បិតអីឃើញមានការជម្លៀសមកពីយកដូចពីកោះកុងមកស្រះធុលអ៊ីចឹងមក ដែលជាទីកន្លែងខ្ញុំ កំណើតខ្ញុំនៅហ្នឹងមក។ ហើយពីស្រះធុល ទៅកោះកុង។ ដូច្នេះវានយោបាយនេះ កុំឱ្យតាមដាន កុំឱ្យប្រជាជនដឹង ហើយការហូបចុកក៏អត់គ្រប់គ្រាន់។ អ៊ីចឹងយកឱ្យទៅស្លាប់ទាំងអស់គ្នា បើតាមយល់ខ្ញុំ។ វេទនា ខ្ញុំដែលបានដឹងហ្នឹង គឺយល់របស់ខ្ញុំហ្នឹងគឺប៉ុណ្ណឹង។ សូមជម្រាបជូនប៉ុណ្ណឹង។

[១៣:៤៣:៣៥]

**សះ** លោក នូ មោក ក្រោយពីការជម្លៀសប្រជាជននៅខែមេសា ១៩៧៥ ចេញពីក្រុងភ្នំពេញ តើលោកស្គាល់កន្លែង បើសិនណាខ្ញុំអានឈ្មោះទៅវាមិនច្បាស់នោះ តើលោកស្គាល់កន្លែងហៅថាស្រុកថ្លុង ដែរឬទេ?

**ឆះ** ស្គាល់ តែពីមុនមក ដល់ខ្ញុំមកនៅវល្លិ៍ស ឃុំវល្លិ៍ស ជារៀបចំសហករណ៍ហ្នឹង ខ្ញុំអត់បានជិតដល់ទាក់ទងទៅស្រុកថ្លុងទេ។ តែរឿងស្រុកថ្លុងខ្ញុំស្គាល់ ស្រុកៗថ្លុង តែស្គាល់មិនអស់ទេ ស្រុកថ្លុង។ ប្រជាជនក្តី កម្មាភិបាលនៅមូលដ្ឋាន ភូមិ ឃុំក្តីក៏ខ្ញុំវាអត់ស្គាល់ដែរទេ វាបាត់បង់អស់ហើយ។ អាចាស់វាត្រូវផ្លាស់ប្តូរអស់រលីងទៅ។ អ៊ីចឹងអ្នកចាស់ត្រូវជ្រុះ ដូចផ្លែក្រសាំងទុំហ្នឹង ជ្រុះអស់ហើយ អត់មានទេ។ អ្នកណាក៏ត្រូវតែទទួលទោសដែរ កម្មាភិបាលពេលនោះ។ គេត្រូវតែកម្ទេចចោលចាស់ ហើយគេរើសថ្មី។ អានេះជាផែនការរបស់ខ្មែរក្រហម។ ខ្ញុំបានដឹងប៉ុណ្ណឹង។ សូមចប់ហើយ។

[១៣:៤៥:១៥]

**សៈ** តើលោកនៅចាំទេ មានប្រជាជនណាខ្លះដែលត្រូវគេបញ្ជូនទៅកាន់ស្រុកថ្កូងដែរឬទេ?

**ឆៈ** ប្រជាជនដែលបញ្ជូនទៅស្រុកថ្កូងមាន ដែលកាលទៅវៃជម្លៀសប្រជាជនពីទីក្រុងភ្នំពេញមកពីឧដុង្គមក កាលណោះ គេយកទៅដាក់នៅថ្កូង នៅស្រុកថ្កូង ប៉ុន្តែដាក់នៅទីណាទេ។ តែគេជម្លៀសចាប់ពីស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចេញដំណើរតាមផ្លូវទៅអមលាំង ទៅស្រុកថ្កូង តែមិនដឹងនៅត្រង់ណាខ្ញុំវាមិន ខ្ញុំអត់បានដឹងនៅពេលដែលគេជម្លៀសទៅនេះ គ្រាន់តែឮតាមគណៈកម្មាធិការប្រធាន -- កម្មាធិការទទួលបន្ទុកខាងឃុំ ខាងកម្មាធិការស្រុកដែលគេជម្លៀសទៅហ្នឹង។ ដូច្នេះ អាចាស់ហ្នឹងគេផ្លាស់ចោលអស់ទៅហើយ វានៅតែចាត់តាំងថ្មីទេ ហ្នឹងហើយដែលខ្ញុំបានលើកឡើងថា ជម្លៀសប្រជាជនពីស្រុកឧដុង្គទៅនេះ វាដែលវៃអូសប្រជាជនយកទៅដាក់នៅថ្កូង ដែលខ្ញុំដឹងហ្នឹងប៉ុណ្ណឹង។ សូមជូន។

[១៣:៤៧:០៥]

**សៈ** លោកសាក្សី តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើមានអ្វីកើតឡើងចំពោះមុនមន្ត្រីរបប លន់ នល់ ឬក៏ទាហានរបប លន់ នល់?

**ឆៈ** ដែលជម្លៀសប្រជាជនគ្រប់មជ្ឈដ្ឋានមិនថាប្រជាជន ឬក៏កងទ័ព លន់ នល់ ទេ។ គេជម្លៀសទៅបាត់ៗទៅ ទៅលើទៅ គេថាឲ្យទៅរៀន ហ្នឹងហើយទៅរៀន ដើម្បីយើងវៃបក។ មិនខាងនិរតី កាលនុ៎ង ថាឲ្យទៅរៀនៗ ទៅរៀនអត់ឃើញមកវិញផង។ អ៊ីចឹងបានន័យថា ប្រហែលជាគេធ្វើឃាត គេសម្លាប់។ កងទ័ពលន់ នល់ ទៅទាំងហ្វូងៗ ឧបត្ថម្ភឲ្យ -- ប្រជាជនឧបត្ថម្ភដល់កងទ័ព។ កងទ័ពអត់មានកាំភ្លើងទេ ទោះបីមានអាវុធ ក៏គេឲ្យទុក។ គេថាឲ្យទៅរៀន ដើម្បីវៃតទៀតហ្នឹងហើយវៃយួន។ អ៊ីចឹងផែនការនេះ ជាផែនការទាំងខ្សែៗដែលនាំទៅហ្នឹង គឺពិតជាស្លាប់អស់ មិនរស់ទេ។ នេះតាមដែលគេឲ្យថា គេយកទាំងប្រជាជន ទាំងកងទ័ពដែលទៅ ដែលទៅរៀន ហើយមានបាយហូបគ្រប់គ្រាន់នៅខាងលើ។ ហេតុនេះ ខ្ញុំសន្និដ្ឋានខ្លួនខ្ញុំថា ឲ្យតែបញ្ជូនទៅអង្គការលើហ្នឹង គឺលើងាប់តែម្តង អត់មានលើរស់ទេ។ នេះខ្ញុំសូមជម្រាបជូននៅក្នុងអង្គប្រជុំ នៅក្នុងពេលនេះ។ រឿងដែលកើតឡើង គឺវាចាញ់បោកតែទាំងអស់ ចាញ់បោកខ្មែរក្រហម ហើយងាប់ដោយសារខ្មែរក្រហម ហើយស្លូត សុភាពរាបសា ប៉ុន្តែចិត្តរបស់ខ្មែរក្រហមសម្លាប់រង្គាល សម្លាប់រង្គាល់តែម្តង បើតាមខ្ញុំដឹង។ ដឹងតាមខ្សែរយៈអី? ដើម្បីតែដឹងហ្នឹង--

**ប្រធានអង្គជំនុំះ**

លោក ម៉ៅ សូមផ្អាកបន្តិចសិន!

សូមអញ្ជើញលោកមេធាវី យ៉ាងម៉េចទៅ?

**លោក សុន អរុណ៖**

លោកព្រះរាជអាជ្ញាបានសួរទៅសាក្សីខ្លី ហើយសាក្សីមិនដែលតាំងព្រឹកមកដល់ស្ពានេះមិនដែលឆ្លើយទៅសំណួររបស់លោកសាក្សីតាមសំណួររបស់គាត់ទេ ឆ្លើយវែងហើយទុកឱ្យព្រះរាជអាជ្ញាខាតពេល ហើយត្អូញថាខាតពេលច្រើនណាស់។ សាក្សីពេលណាក៏ដោយឆ្លើយវែងមែនទែនហើយ ចាកប្រធានដែលព្រះរាជអាជ្ញាសួរម្ល៉ោះហើយសូមតុលាការពិចារណារឿងនេះ។ សូមអរគុណ។

[១៣:៥០:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមបន្ថែមការកត់សម្គាល់បន្តិចពីក្រុមខ្លួន ជា នេះគឺហើយក៏ជាការជំទាស់របស់ក្រុមយើងខ្ញុំផងដែរ។ ហាក់បីដូចជាផ្តល់ឃ្លាប្រយោគមួយទៅសាក្សីហើយក៏សុំឱ្យ សុំបញ្ជាក់ទៅសាក្សីថាកុំឱ្យធ្វើការស្មានសន្និដ្ឋានដោយយោងតែអ្វីដែលគាត់បានឮ បានឃើញតែប៉ុណ្ណោះនោះ។ ការដែលគាត់បន្តធ្វើសន្និដ្ឋានបន្តទៅទៀតគឺនៅក្នុងសវនាការនេះ គឺវាមិនមែនជាការត្រឹមត្រូវទេ។ សូមអរគុណ។

**លោក ឃីត រេយ៉ន័រ៖**

សំណួររបស់ខ្ញុំមិនមានអ្វីពាក់ព័ន្ធទៅនឹងការសន្និដ្ឋាននោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានសំណួររបស់ខ្ញុំ -- ខ្ញុំប្រកាន់ជំហរនេះដដែលសូមមេត្តាបង្គាប់ទៅសាក្សីកុំឱ្យស្មានឬក៏សន្មតឱ្យផ្តល់សក្ខីកម្មតែអ្វីដែលគាត់បានឃើញ និងបានឮតែប៉ុណ្ណោះបានហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ លោកសាក្សីអង្គជំនុំជម្រះបានកំណត់អំពីភារកិច្ចរបស់លោកតាំងពីព្រឹកម្ល៉េះគឺលោកឆ្លើយតបទៅនឹងសំណួរនូវអ្វីដែលលោកចងចាំ លោកបានដឹង បានឮ បានឃើញបានចងចាំ ឬក៏មានបទពិសោធន៍ ឬក៏ការធ្វើសង្កេតនៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងសំណួរដែលសួរនេះនៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលលោកបានជួបប្រទះប៉ុណ្ណោះ។ ហើយលោកគប្បីឆ្លើយតបសមល្មមទៅនឹងភាពចាំបាច់នៃសំណួរដែលសួរបានហើយ។ សាក្សីក៏បាននិយាយខ្លួនឯងដែលព្រឹកមិញ គឺបានបញ្ជាក់ហើយថាមានការភ្លេចភ្លាំងច្រើន រង់ចាំសំណួរដែលសួរគាត់នឹងឆ្លើយ។ សូមបន្តទៀតបាទ។

[១៣:៥២:៤៥]

**លោក ឃីត រេយ៍ន័រ៖**

**ស៖** លោក នូ មោក តើលោកនៅទីកន្លែងណាដែលនៅពេលដែលលោកឃើញទាហានលន់នល់ទាំងហ្នឹងៗត្រូវបានគេនាំខ្លួនទៅបាត់នោះ?

**ឆ៖** ខ្ញុំឃើញគេបញ្ជូនទៅនៅក្នុងឃុំជើងរាស់ដដែល ហើយវត្តព្រៃជុំ។ គេជម្លៀសទៅហ្នឹង ខ្ញុំឃើញទាហាន តែទៅមុខទៀតខ្ញុំអត់បានដឹង សូមចប់ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក នូ មោក។ ខ្ញុំអស់សំណួរសួរលោកបន្តទៅទៀតហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គសវនាការ។ មេធាវីដែលទទួលសិទ្ធិ គឺលោកមេធាវី ឡោ ជុនធី ហើយនិងកញ្ញាមេធាវី បេនី យេ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៣:៥៤:៤៣]

**លោក ឡោ ជុនធី៖**

**ស៖** បាទ ជាបឋមខ្ញុំបាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។ សូមគោរពលោក នូ មោក ផងដែរ។ ខ្ញុំបាទ ឡោ ជុនធី ជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ ហើយនៅទីនេះជាមេធាវីខាងតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលនេះ ខ្ញុំមានសំណួរមួយចំនួនដែលជម្រាបសួរទៅខាងលោកដើម្បីបញ្ជាក់បន្ថែមដែលសហព្រះរាជអាជ្ញាសួរលោកមកហើយ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួរខ្ញុំចង់ដឹងថា កាលពីលោកបានចូលទៅក្នុងបម្រើបដិវត្តន៍ហ្នឹង តើមានការណែនាំពីបងប្អូន ឬមួយសាច់ញាតិដែរដែលអត់ទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** អត់មានទេ។ ទៅតាមសាច់ញាតិដែលមាន មានតែបងប្អូនជីដូនមួយដែលធ្វើគណៈឃុំនៅពីដើមហៅថាជើងរាស់ ឥឡូវហ្នឹងថាយុទ្ធសាមគ្គី។ តែបងប្អូនហ្នឹងគាត់អ្នកចូលបក្សដឹកនាំ។ ហើយមួយទៀតបងប្អូន មួយទៀតឈ្មោះ គួង ឆន។ គាត់បន្ទាប់ហ្នឹង មុំ តុល។ រួចខ្ញុំជាគណៈកម្មការនៅក្នុងឃុំជាសមាជិកនៅក្នុងឃុំជើងរាស់ហ្នឹង។

**ស៖** អរគុណ។ ចំណុចមួយទៀតដែលខ្ញុំសួរភ្ជាប់ទៅលើអ្វីដែលលោកបានចូលនេះ តើហេតុអ្វីដែលលោកបានចូលទៅបម្រើបដិវត្តន៍ហ្នឹងមានមូលហេតុអ្វីដែរបាទ?

[១៣:៥៧:១៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោក ម៉ៅ!

**លោក នូ ម៉ៅ៖**

**ឆ៖** ហេតុដែលខ្ញុំចូលទៅហ្នឹង គឺបងប្អូនដែលធ្វើគណៈឃុំហ្នឹង គេហៅខ្ញុំទៅចូលធ្វើបដិវត្តន៍។ ខ្ញុំៗថាវាទៅមិនរួចទេអក្សរសាស្ត្រ ក៏ខ្ញុំមិនចេះសរសេរ ការបួករៀនហ្នឹងវាបានតិចណាស់។ អ៊ីចឹងចេះតែគេឲ្យថា ឥឡូវបើយូរៗទៅវាចេះហើយ។ រួចខ្ញុំនៅតែប្រកែកមិនបាន តើបើសិនជាខ្ញុំនៅតែទទូចថាមិនធ្វើ វាត្រូវតែគ្រោះថ្នាក់ខ្លួនឯង។ ហ្នឹងមានប៉ុណ្ណឹង។

**ស៖** តើនៅពេលនោះ លោកថាបើមិនព្រមចូល មានគ្រោះថ្នាក់។ តើគេបានគំរាម ឬមួយគេបានធ្វើម៉េចទៅលើលោកដែរ?

**ឆ៖** ខ្ញុំថាគ្រោះថ្នាក់ដោយសម្ងាត់។ ដោយសម្ងាត់យ៉ាងម៉េច? យើងមិនចូលចលនាធ្វើបដិវត្តន៍ប្រឆាំងនឹង លន់ នល់។ អ៊ីចឹងបើសិនជាខ្ញុំមិនចូល ក៏គេមិនទុកចិត្តខ្ញុំដែរ។ ត្បិតអីវានៅក្រោមការដឹកនាំនៅក្នុងសមាជិកឃុំហ្នឹងបានជាខ្ញុំចូលធ្វើបដិវត្តន៍។ មានប៉ុណ្ណឹង។

**ស៖** បាទអរគុណ។ ចំណុចមួយទៀតដែលខ្ញុំជម្រាបសួរលោកដែរ គឺថាការចូលបដិវត្តន៍នេះពេលដែលលោកចូលហើយ តើគេមានការបណ្ដុះបណ្ដាលអប់រំអំពីគោលនយោបាយរបស់បដិវត្តន៍អ្វីខ្លះដែរបាទ?

[១៤:០០:០៦]

**ឆ៖** គឺចូលនៅក្នុងបដិវត្តន៍ ធ្វើបដិវត្តន៍តស៊ូដើម្បីរំដោះប្រទេសជាតិនៅកម្ពុជាយើង។ ម្យ៉ាងបើខ្ញុំ

មិនចូលរួម ខ្ញុំក៏មិនដឹងទៅនៅត្រង់ណាដែរ វារកកន្លែងនៅ ទាល់តែរត់ចូល លន់ នល់។ រត់ចូល លន់ នល់ ក៏គ្រួសារប្រពន្ធកូននៅ។ អ៊ីចឹងខ្ញុំជាសមាជិកក្រោមជារដ្ឋបាលនៅក្នុងឃុំមួយដែលគេឲ្យដឹកនាំមាន ភូមិបី ស្រះធុល ក្រាំងសុទិន ត្រពាំងធំ បីហ្នឹង មានប៉ុណ្ណឹងខ្ញុំ។ បំផុសឡើងចលនាឲ្យយុវជន យុវនារី ដើម្បីឈរក្រោកឡើងធ្វើបដិវត្តន៍ មានតែប៉ុណ្ណឹង។ សូមអស់។

**ស៖** បាទ តើធ្វើបដិវត្តន៍ បដិវត្តន៍នឹងប្រឆាំងជាមួយនឹងរបបណា? ហើយឬមួយប្រឆាំងជាមួយ នឹងអ្នកណាផ្សេងទៀត ឬមួយយ៉ាងម៉េច?

[១៤:០១:៣៥]

**ឆ៖** ប្រឆាំងបដិវត្តន៍ គឺទី១ ប្រឆាំង លន់ នល់ បាទ ដែលយកគ្រាប់បែកមកទម្លាក់នៅកម្ពុជា។ សូមអស់។

**ស៖** បាទ សូមអរគុណ។ តើលោកស្គាល់ តាម៉ុក ពីឆ្នាំណាដែរ? មិនដឹងឆ្នាំទេអាចស្គាល់ពី ជំនាន់មុន៧៤ ឬមួយ៧២ ឬ៧៣?

**ឆ៖** ខ្ញុំមិនបានចាំដែរ ថាក្នុងឆ្នាំប៉ុណ្ណោះៗ ប៉ុណ្ណោះ ទៅជួបតាម៉ុក ខ្ញុំចាំអត់បានដែរ រឿងថ្ងៃ។

**ស៖** បាទ អរគុណ។ ចុះតាម៉ុក ហើយនិង ជូ ជេត, លោកថាស្គាល់ តាម៉ុក ហើយនិង ជូ ជេត ខ្ញុំចង់ដឹងថា តើតាម៉ុក ហើយនិង ជូ ជេត តើមួយណាគាត់មានឋានៈធំជាងគេនៅក្នុងការគ្រប់គ្រងកាល ពីសម័យនោះបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបរង់ចាំបន្តិចសិនណ៎ះ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនសឹមឆ្លើយ ណ៎ះ!

[១៤:០៣:៣៥]

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំដែលស្គាល់ តាម៉ុក ហើយនិង ជូ ជេត ហៅ ស៊ី នេះ ខ្ញុំស្គាល់ត្រង់គាត់បង្រៀនបំពាក់ បំប៉នឃោបាយនៅកន្ទួត។ ជំនាន់នោះមានកម្មាភិបាលចម្រុះ ខ្ញុំភ្លាប់មិនបានមិនដឹងមកពីមជ្ឈដ្ឋានណា ដែរទេ តែចំនួន ២០០ជាងកម្មាភិបាល។ ជូ ជេត ចាប់ផ្តើមបើកវគ្គ ដឹកនាំខាងចលនានយោបាយខ្ញុំរៀន បានប្រហែល១ខែ ១ខែជាងហ្នឹងហើយ។ ក្រោយមកបាន -- ទន្ទឹមនោះក៏មាន តាម៉ុក ហ្នឹងមកចុង ក្រោយថា មកពីតាកែវកំពត មកទាន់។ អ៊ីចឹងគាត់បង្រៀនទៀត គាត់បំពាក់បំប៉នខាងផ្នែកយោធា គាត់

ថា "កម្មាភិបាលនៅមូលដ្ឋានមួយៗ យើងត្រូវចលនាធ្វើបដិវត្តន៍ដើម្បីរំដោះក្រពត្តិអាមេរិកាំង។ លុះត្រាណាទទួលបានជ័យជម្នះ។ ហ្នឹងជាពាក្យ ម៉ុក តែសួរថា អ្នកណាធំជាងអ្នកណា។ អង្កាល់ណោះ ជូ ជេត មានប្រៀបខាងផ្នែកនយោបាយលើ ម៉ុក។ សូមអស់បាទ។

**ស៖** បាទ អរគុណបាទ។ តើនៅពេលដែលលោកបានចូលរៀនសូត្រនយោបាយហ្នឹង ឬមួយពេលណាដែលលោកបានលើកឡើងថា តាម៉ុក ហើយនិង ជូ ជេត ហ្នឹង គាត់មានគំនិតខ្វែងគ្នា។ ខ្ញុំចង់ដឹងថា តើគំនិតគាត់ខ្វែងគ្នាហ្នឹងទៅលើចំណុចណាបាទ?

[១៤:០៥:៥៦]

**ឆ៖** ត្រង់ដែលខ្វែងគំនិតគ្នាហ្នឹង ខ្ញុំមិនបានដឹងដែរទេ តែគ្រាន់តែ តាម៉ុក ដែលបើកវគ្គនយោបាយ អំ! ជូ ជេត ដែលបើកកម្មវិធីនយោបាយ ដែលកម្មាភិបាលមកហើយជាង ២០០ហ្នឹង គាត់ទើបមកក្រោយបានគាត់ប្រជុំកម្មាភិបាល ឲ្យកសាងពង្រឹកកងទ័ព ចលនាប្រជាជន ធ្វើបដិវត្តន៍ដើម្បីរំដោះក្រពត្តិអាមេរិកាំង។ អាហ្នឹងជានយោបាយគាត់។ តែបើសួរថា ម៉ុក ហើយនិង ជូ ជេត ហ្នឹងវាមានប្រៀបបែបបទយ៉ាងណា? ថា ជូ ជេត គាត់ជាអ្នកនយោបាយមួយដែលគាត់លើ ម៉ុក ហ្នឹងហើយលើ ម៉ុក ការដឹកនាំ ចលនាប្រជាជន។ ខ្ញុំសូមមានប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ចំណុចហ្នឹងខ្ញុំចង់ដឹងតែមួយចំណុចទេដែលថា តាម៉ុក ហើយនិង ជូ ជេត ហ្នឹងមានការខ្វែងគំនិតគ្នានៅក្នុងការដឹកនាំ។ តើការដឹកនាំរបស់គាត់ខ្វែងគំនិតគ្នាទៅលើគំនិតអំពីការជម្លៀស ឬមួយយ៉ាងម៉េចបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយលោក ម៉ៅ ឆ្លើយជាហូរហែមកគឺក្បាលមីក្រូហ្វូន មិនទាន់ប្រតិបត្តិការសោះ។ ឥឡូវហ្នឹងកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:០៨:០៤]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន គឺថាមានពីរបី គឺថាមានច្រើនដងហើយ ដែលលោកប្រធានបានជម្រាបដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មិនឲ្យធ្វើការសួរសំណួរដដែលៗដែលផ្អែកទៅលើមូលដ្ឋានដដែល ដូចដែលខាងព្រះរាជអាជ្ញាបានសួររួចទៅហើយនោះ។ សំណួរបែបហ្នឹងគឺថាមូលដ្ឋានដូចគ្នាទៅលើបញ្ហាដូចគ្នាដែលបានសួរដោយខាងព្រះរាជអាជ្ញា។ ដូច្នេះតាមការស្នើសុំរបស់ខ្ញុំគឺថា សំណួរនេះមិន

មែនជាមុខងារជាចម្បងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើម្បីបណ្ដឹងរដ្ឋប្បវេណីត្រូវស្វែងយល់ពីព្យសនកម្ម និងការឈឺចាប់នានា។ ដូច្នេះខ្ញុំគិតថាខាងដើមបណ្ដឹងរដ្ឋប្បវេណីគួរតែគោរពទៅតាមតួនាទីរបស់ខ្លួន ហើយសួរសំណួរពាក់ព័ន្ធទៅនឹងតួនាទីរបស់ខ្លួន។ សូមអរគុណលោកប្រធាន។

[១៤:០៨:៥៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ យើងខ្ញុំអាចទទួលបានមួយចំនួនប្រសិនបើនិយាយថា មានសំណួរច្រំដែល ប៉ុន្តែបើកម្រិតឲ្យមេធាវីនាំមុខ និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនិយាយអំពីតែការឈឺចាប់និងព្យសនកម្ម គំនិតនេះយើងខ្ញុំមិនឯកភាពទេដោយសារមេធាវីនាំមុខ -- មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានតួនាទីនៅក្នុងការគាំទ្រផងដែរទៅនឹងការចោទប្រកាន់។ ដូច្នេះយើងខ្ញុំមិនទទួលនូវការកម្រិតតួនាទីរបស់យើងខ្ញុំនៅត្រឹមនេះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយការកត់សម្គាល់ល្អមួយផ្នែកដែរ គឺត្រឹមត្រូវជៀសវាងនូវសំណួរច្រំដែល។ បាទ អង្គជំនុំជម្រះមិនកំហិតតែលើសំណួរណាពាក់ព័ន្ធនឹងព្យសនកម្ម ឬក៏បង្ហាញអំពីព្យសនកម្មពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីទេ ព្រោះកន្លងមកយើងបានអនុវត្តបែបនេះច្រើនករណីហើយ មិនគួរកើតឡើងនៅពេលចុង -- មុននឹងបញ្ចប់នៃរឿងក្ដី ដែលដេញដោលជាង១ឆ្នាំ ជិត២ឆ្នាំមកនេះនោះទេ។

[១៤:១០:០៨]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ ដោយសារខាងសហព្រះរាជអាជ្ញាគាត់បានលើកឡើងអម្បាញ់មិញ ឥឡូវខ្ញុំសូមលើកចំណុចមួយចំនួនបន្ថែមទៀត ថាតើសួរលោក នូ មោក បន្ថែមបាទ។ ខ្ញុំបានពិនិត្យឃើញថា--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសាក្សីនេះ ឈ្មោះ នូ ម៉ៅ ហៅ មោក ហ្នឹងៗឈ្មោះហៅក្រៅទេ។ គាត់បានឆ្លើយច្បាស់លាស់នៅចំពោះមុខអង្គជំនុំជម្រះកាលពីព្រឹកមិញហើយ។ បើលោកមិនយល់ទេ យើងប្រាប់ថាឈ្មោះផ្លូវការដែលគាត់ឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះគឺឈ្មោះ ម៉ៅ។

**លោក ឡោ ជុនធី៖**

បាទ អរគុណ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ឥឡូវចំណុចសំខាន់ដែលខ្ញុំចង់ជម្រាបសួរបន្ត គឺថា តើមានចំណងពាក់ព័ន្ធឈ្មោះ ស៊ី។ តើគេចាប់ ស៊ុី នៅពេលណាបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ!

មេធាវីប្រឹក្សាសាក្សីអាចធ្វើអ្វីម្យ៉ាងដើម្បីរំឭកគាត់!

អាចសាក្សីរង់ចាំរហូតដល់មេធាវីប្រឹក្សាជួយលោកក្នុងការកេះគាត់ទៅដើម្បីឲ្យកាត់ឆ្លើយ។ សូមឆ្លើយសាក្សី! ខំរំខានខាតពេលឥតប្រយោជន៍ ច្រើនលើកច្រើនសា គ្រប់សំណួរហើយ មិនមែនភាគតិចឯណា។

[១៤:១២:០៩]

**លោក នូ ម៉ៅ៖**

**ឆ៖** សំណួរអំមិញសួរថាតើ ស៊ីៗ ដែលគេចាប់ តើនៅពេលណា? ត្រង់ហ្នឹង ខ្ញុំអត់បានដឹងទេ។

**ប្រធានអង្គជំនុំ៖**

តទៀត តសំណួរទៀត!

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ចុះតើគេ នណាចាប់លោកដាក់គុកដែរបាទ?

**លោក នូ ម៉ៅ៖**

**ឆ៖** សហករណ៍ដែលនាំខ្ញុំទៅ ដែលខ្ញុំអស់ពីតួនាទីទៅ គេយកខ្ញុំទៅប្រសិទ្ធិដែរ យកទៅដាក់គុកនៅប្រសិទ្ធិ។ បើនិយាយពីគុកប្រសិទ្ធិនេះ គឺ *(ឮមិនច្បាស់)* តែឮគេថាៗតាមទេខ្ញុំ គាត់នៅតំបន់១៥ ភូមិភាគខាងលិចស្ដីដែរ ហើយបាត់ខ្លួន តែមិនដឹងអ្នកណាចាប់។ បាត់តាំងពីកាលហ្នឹងមក រួចឪពុកក្មេកគាត់ ឪពុកក្មេកតា ស៊ី ហ្នឹងក៏ស្លាប់ៗហើយប្រពន្ធនៅរស់។ ដែលខ្ញុំជាប់គុកនៅប្រសិទ្ធិហ្នឹងដែរ។ នៅរស់ដែលពេលដែលជាដែលគ្រាប់បែកទម្លាក់នៅពាមចាន់។ នាំគ្នាប្រមូលទាំងអ្នកទោស អ្នកគុកអីទាំងអស់ ខ្លះជាប់ខ្នោះនៅលើគ្រែត្រើង្ស ខ្លះទៀតនៅក្នុងរោងដែលដាក់--

[១៤:១៤:២២]

**ស៖** បាទៗ ខ្ញុំសូមកាត់បន្តិចបាទ។ ខ្ញុំសូមសួរសំណួរលោកចុងក្រោយ។ លោកបានដឹងថា

មានការជម្លៀសចេញពីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកបានដឹងទេ នៅពេលដែលជម្លៀសប្រជាជនចេញហ្នឹងមានពួកខ្មែរក្រហមមានអំពាវនាវឲ្យអ្នកណាខ្លះដែលចូលមកបម្រើការងារនៅក្រុងភ្នំពេញវិញ ហើយតើវាសនារបស់អ្នកទាំងអស់នោះទៅយ៉ាងណាដែរ? សូមអរគុណ។

**ឆ៖** ត្រង់ ខ្ញុំអត់បានដឹងទេ ត្រឡប់ទៅជម្លៀសប្រជាជនវិញ។ ខ្ញុំនិយាយម្តងរួចហើយ។

**លោក ឡោ ជុនធី៖**

បាទ អរគុណ អ៊ីចឹងអរគុណលោកអំច្រើន ។

**លោកស្រី បេនី យេ៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ព្រមទាំងភាគីទាំងអស់នៅក្នុងសាលសវនាការ។ ខ្ញុំឈ្មោះ បេនី យេ ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ ហើយខ្ញុំមានសំណួរពីរបីដើម្បីសាកសួរចំពោះលោក។

[១៤:១៥:៤៥]

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** ជាដំបូង ខ្ញុំចង់និយាយអំពីទាហានលន់ នល់ ដែលលោកបាននិយាយថា លោកបានឃើញគេនាំយកទៅ។ តើលោកអាចប្រាប់បានដែរឬទេ ថាតើលោកឃើញគេនាំយកទាហានទៅហ្នឹងប្រហែលជាប៉ុន្មាននាក់ដែរ?

**លោក នូ ម៉ៅ៖**

**ឆ៖** អាហ្នឹងបកក្រោយវិញ។ ដែលសំណួរហ្នឹង ដែលគេជម្លៀសប្រជាជនពីទក្រុងភ្នំពេញមកទាហានមានច្រើនណាស់ ទាហានដែលមកពីភ្នំពេញ។ ដែលខ្ញុំឃើញផ្ទាល់នៅនឹងភ្នែក កាំភ្លើងអត់មានទេ គេដកអស់ហើយ អាវុធអត់មានទេ។ គេឲ្យតែមានសាក់កាដូ មួយសាក់កាដូ គេជម្លៀសទៅ។ ថាគេថាទៅលើៗ ខ្ញុំបានដឹងតែប៉ុណ្ណឹង តែអត់ឃើញត្រឡប់មកវិញ។ សូមអស់យោបល់ប៉ុណ្ណឹង។

**ស៖** ដូច្នេះ ទាហានលន់ នល់ ដែលលោកឃើញគេយកមកនៅកំពង់ស្ពឺហ្នឹង គឺលោកឃើញថាគឺលោកគិតថា គេយកមកពីទីក្រុងភ្នំពេញ។ តើមែនដែរឬទេ?

[១៤:១៧:០៧]

**ឆ៖** គេជម្លៀសមកពីទីក្រុងភ្នំពេញ។ ដែលមកហ្នឹង ដែលខ្ញុំឃើញនៅព្រៃដុំ ឃុំជើងរាស់ដែរ។ ទាំងប្រជាជន ទាំងទាហាន ជម្លៀសទៅលិចទៅ ហើយខ្ញុំអត់បានដឹងតទៅទៀតទេ។ មានតែប៉ុណ្ណឹងទេ

ដែលខ្ញុំឃើញ។ រួចបើថាទេ ខ្ញុំនឹងចេះតែថាទៅស្រាវជ្រាវសួរមានអ្នកដែលដឹងរឿងច្រើនដែរ នៅកន្លែងហ្នឹង ប្រជាជន។

**ប្រធានអង្គជំនុំ៖**

បានហើយ បន្តសំណួរទៀត!

**លោកស្រី បេនី យេះ**

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់សួរលោកថាតើលោកធ្វើយ៉ាងណាដឹងថាពួកគាត់ហ្នឹងជាទាហាន លន់ នល់ ប្រសិនបើលោកនិយាយអម្បាញ់មិញថា គេធ្វើដំណើរ -- ពួកគាត់ហ្នឹងធ្វើដំណើរជាមួយជនស៊ីវិល តើលោកធ្វើដឹងថា ពួកគាត់ហ្នឹងជាទាហាន លន់ នល់ ទៅ?

[១៤:១៨:០៨]

**លោក នូ ម៉ៅ៖**

**ឆ៖** ទាហាន លន់ នល់ ដែលដឹងហ្នឹង ដឹងខោអាវ សាក់កាដូ គេមានសាក់កាដូ ខោអាវដែលគេនាំទៅថាទៅឲ្យរៀន ដើម្បីចំណេះវិជ្ជាគឺរើបក តស៊ូតទៅទៀត។ អាហ្នឹងដែលគេជម្លៀសទៅហ្នឹង ដែលខ្ញុំនៅវត្តព្រៃជុំ តែអត់មានលោកទេ កាលនុ៎ង អត់មានទេ ដែលវាជម្លៀសទៅ។ ហើយខ្ញុំនឹងក៏ឈឺដែរ តែគ្រាន់តែឃើញ ហើយមិនសន្និដ្ឋានថា "អ្ហែ! ពួគេថាទេ" ឃើញតែម្ដង ដែលទៅហ្នឹង។ ហើយស្នាក់ការដែលត្រូវទទួលបាយទាហានហ្នឹងនៅខាងត្បូងវត្តហ្នឹង នៅពេញវាលហ្នឹងតែម្ដង។ គេហៅថាទាហានៗ លន់ នល់ យកពី ជម្លៀសពីភ្នំពេញមក។ រួចខ្ញុំបានដឹងតែប៉ុណ្ណឹងទេ។ ដែលទៅហើយ ទៅរៀនដល់ណោះ ដល់ណោះ នោះខ្ញុំអត់បានដឹងទេ។ បានឃើញតែប៉ុណ្ណឹង ហើយឃើញហ្នឹង គឺច្បាស់ណាស់ មានសាក់កាដូ មានខោអាវហ្នឹង តែអាវុធអត់មាន គេដកខ្ទេចអស់ហើយ។ ហើយបើថាទេ ខ្ញុំចេះតែថា ឥឡូវទៅឲ្យ--។

**ប្រធានអង្គជំនុំ៖**

បានៗហើយ តទៀត សំណួរសួរតទៀត!

**សួរដោយលោកស្រី បេនី យេះ**

**ស៖** សូមអរគុណលោកសាក្សី។ លោកបាននិយាយថា លោកឃើញទាហានជាច្រើន តើលោកអាចថាទៅមើលថាតើទាហានប៉ុន្មាននាក់ដែរ ដែលលោកឃើញហ្នឹង គឺចំនួនប្រហាក់ប្រហែលហ្នឹងថាប្រហែលជាប៉ុន្មាននាក់ លោកអាចប្រាប់បានដែរឬទេ?

[១៤:១៩:៥៨]

**លោក នូ ម៉ៅ៖**

**ឆ៖** ឲ្យខ្ញុំប៉ាន់ស្មានប្រហែលហ្នឹង ខ្ញុំភ្លាប់អត់ជុំបានទេ ប៉ុន្តែឃើញច្រើនដែរ វាចូលដល់ ចង់រយគ្រាន់តែទាហានដែលជម្លៀសមកហ្នឹង ច្រើន។ រួចដាក់ទីតាំងនៅត្រពាំងខាងត្បូងព្រៃជុំហ្នឹង រួចគេឲ្យបាយទឹកហូបនៅហ្នឹង រួចស្អែកឡើងគេឲ្យទៅរៀនថ្នាក់លើ។ ខ្ញុំបានដឹងដំណឹងហ្នឹង។ សូមអស់។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយអំពីប្រធានបទថ្មីមួយទៀតនៅព្រឹកនេះលោកបាននិយាយថា បន្ទាប់ពីមានការជម្លៀសចេញពីទីក្រុងភ្នំពេញគឺមានការបែងចែកច្បាស់លាស់រវាងប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី។ ឥឡូវនេះតើលោកអាចពន្យល់បានដែរឬទេ តើគេបែងចែកយ៉ាងដូចម្តេចដែររវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីនោះ?

**ឆ៖** ខ្ញុំដូចជាសន្និដ្ឋានមិនបានទេ ត្បិតអីគេថាទទួលប្រជាជនមកពីទីក្រុងរវាងប្រជាជនមូល-ដ្ឋាន និងប្រជាជនមកពីទីក្រុង។ អ៊ីចឹងគេដាក់នៅក្នុងហ្នឹងគេឲ្យខាងមូលដ្ឋានហ្នឹងជួយជាម្ហូបចំណីអាហារអីហ្នឹងគេឧបត្ថម្ភ ហ្នឹងនៅឃុំវល្លិ៍ស ដែលខ្ញុំឃើញ។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលដែលប្រជាជនថ្មីមកដល់ហ្នឹងតើលោកសង្កេតឃើញថាមានការប្រព្រឹត្ត តើមានការប្រព្រឹត្តដូចគ្នាចំពោះប្រជាជនថ្មីនិងប្រជាជនមូលដ្ឋាន ឬក៏គេប្រព្រឹត្តខុសគ្នាចំពោះប្រជាជន ថ្មីនិងប្រជាជនមូលដ្ឋាន។ តើលោកអាចប្រាប់បានដែរឬទេ?

**ឆ៖** អាហ្នឹងហើយដែលខ្ញុំថាខ្ញុំអស់សិទ្ធិចេញពីសហករណ៍ចូលដល់កន្លែងហ្នឹង។ អ៊ីចឹងគ្រាន់ថាគេចែកជាកុក។ ប្រជាជនមកពីទីក្រុងប៉ុន្មាននាក់? បីនាក់នៅក្នុងហ្នឹងប្រជាជននៅមូលដ្ឋានគឺម្នាក់។ ដើម្បីអី? គឺដើម្បីឲ្យការពារប្រជាជនមកពីទីក្រុងភ្នំពេញ ប៉ុន្តែទិសដៅរបស់គេខ្ញុំមិនអាចដឹងទេ សូមអស់ប៉ុណ្ណឹង។

[១៤:២២:៤៩]

**ស៖** តើលោកដឹងដែរឬទេ ហេតុអ្វីបានជាអ្នកមូលដ្ឋានហ្នឹងគេត្រូវត្រួតពិនិត្យអ្នកមកថ្មីទេ? លោកដឹងពីមូលហេតុទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេក្នុងហេតុហ្នឹង ត្បិតអីខ្ញុំទៅគេឲ្យទៅនៅជាសិប្បកម្មទៅហើយ។ សូមអស់ប៉ុណ្ណឹងទៅខ្ញុំមានតែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណលោកសាក្សី។ បន្ទាប់ពីមានការតាមដានប្រជាជនថ្មីនោះ តើអ្នកមូលដ្ឋានគេ

ត្រូវវាយការណ៍ទៅខាងខ្មែរក្រហម ទៅថ្នាក់លើខ្មែរក្រហមដែរទេ បើតាមតែលោកដឹង?

**ឆ៖** នេះបើប្រហែលថាទៅ លោកថាគ្រាន់តែប្រហែលយកជាការមិនបានទេ បើឃើញថាប្រជាជនបីនាក់ ហើយនិងប្រជាជនមូលដ្ឋានម្នាក់ដើម្បីគឺថាឲ្យចេះសាមគ្គីគ្នា ចេះជួយលើកស្ទួយទាំងអស់គ្នា រួចតែគំនិតរបស់គេ ខ្ញុំអត់បានយល់អីទេ គ្រាន់តែឃើញប៉ុណ្ណឹង។

**សៈ** ឥឡូវនេះខ្ញុំចង់លើកនូវប្រធានបទចុងក្រោយរបស់ខ្ញុំ។ មុននេះលោកនិយាយថា មុនពេលដែលខ្មែរក្រហមគ្រប់គ្រង គឺព្រះសង្ឃត្រូវបានគេបង្ខំឲ្យសឹកដើម្បីចូលរួមជាមួយបដិវត្តន៍នៅពេលដែលតាម៉ុក ចុះមក។ តើលោកដឹងដែរឬទេ ថាបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចហ្នឹង គេនៅតែមានបង្ខំព្រះសង្ឃឲ្យសឹក។ តើលោកដឹងដែរឬទេ?

[១៤:២៤:៥១]

**ឆ៖** ពីព្រឹកដោះស្រាយមួយសាហើយកន្លែងហ្នឹង។ រឿងចលនាខ្មែរក្រហមឲ្យលោកសឹកហ្នឹងពីព្រឹកខ្ញុំបានជម្រាបរួចអស់ហើយ។ ហើយខ្ញុំលើកសំណួរហ្នឹងមកទៀត វាដូចជាន់គ្នាពេក។ ត្បិតអីធម្មការ ដែលធម្មការ តាម៉ុក ចាត់តាំងធម្មការដើម្បីចលនាធ្វើមហាសន្និបាទផ្សឹកលោកដើម្បីចូលធ្វើកងទ័ព។ ប៉ុណ្ណឹង ខ្ញុំមានប៉ុណ្ណឹងដែលដឹង។

**សៈ** សូមអរគុណ។ ប្រហែលជាខ្ញុំសួរលោកមិនច្បាស់។ ខ្ញុំចង់និយាយអំពីរយៈពេលក្រោយពេលខ្មែរក្រហមឡើងកាន់អំណាច គឺក្រោយថ្ងៃ១៧ មេសា ៧៥ តើលោកដឹងដែរឬទេថា ក្រោយថ្ងៃ១៧ មេសា ៧៥ហ្នឹងនៅតែមានការបង្ខំព្រះសង្ឃឲ្យសឹក តើនៅមានទៀត ឬក៏អត់ទេ?

**ឆ៖** អស់ហើយលោក អត់មានទេ។ លោកសឹកអស់ហើយ ព្រោះចលនាធ្វើជាមីទ្ទិងតាមវត្តនានា គឺអត់មានប្រពៃណីសាសនាអីទេ ខ្មែរក្រហម។ ឲ្យសឹកទាំងអស់ហ្នឹង ទោះបីមិនសឹក ក៏បង្ខំឲ្យសឹកដែរ។ អាហ្នឹងចំពោះផែនការរបស់ តាម៉ុក ធម្មការ ដែលតាម៉ុកចាត់តាំង។ ត្រូវតែសឹក។ ខ្ញុំសូមជម្រាបជូនប៉ុណ្ណឹង ពីព្រឹកជូនម្តងហើយ។

[១៤:២៦:៥៤]

**លោកស្រី បេនី យេះ**

សូមអរគុណលោកសាក្សី ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមថ្លែងអំណរគុណលោក ហើយជូនពរលោកឲ្យធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព និងសុខភាពល្អ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយយ៉ាងម៉េចទៅ? លោក ម៉ៅ ចង់និយាយអី?

**លោក នូ ម៉ៅ៖**

គាត់ថាអរគុណ, សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៨ នាទី ដល់ម៉ោង ១៤:៥០ នាទី)*

[១៤:៥០:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍នីរ៖**

លោកប្រធាន សូមអរគុណ។ ខ្ញុំគិតថា វាមានចំណុចតូចមួយ ហើយខ្ញុំគិតថាយើងមិនទាន់បានដោះស្រាយទៅលើបញ្ហារូបថតដែលលោក នូ មោក បានបង្ហាញអំពី ប៉ែន យៀវនិន ដែលមិនទាន់បង្ហាញថានេះជារូបថត ប៉ែន យៀវនិន ឬក៏មិនមែន ហើយថាតើជាបុគ្គលដែលគាត់និយាយជាមួយឬក៏មិនមែន។ ដូច្នេះ ខ្ញុំសូមបង្ហាញថា តាមការស្នើសុំរបស់ខ្ញុំ គឺថាយើងអាចធ្វើការស្នើសុំអាចឲ្យសាក្សី

គាត់ចុះហត្ថលេខា ឬក៏ផ្តិតមេដៃទៅលើរូបហ្នឹង ដើម្បីជាភស្តុតាងដាក់នៅក្នុងសំណុំរឿង ហើយធ្វើបែបនេះ គឺស្របទៅតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង ដែលជាឯកសារ ឬក៏រូបថតដែលអាចនាំទៅដល់ស្វែងរកការពិតបាន។ ហើយខ្ញុំគិតថា ខាងព្រះរាជអាជ្ញាដឹងអំពីរូបថតនេះនៅពេលដែលលោក នូ មោក បានបង្ហាញរូបថតនេះនៅក្នុងអង្គជំនុំជម្រះកាលពីព្រឹកមិញនេះ។ សូមអរគុណលោកប្រធាន។

[១៤:៥១:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៥២:៤១]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា ឡើងបញ្ជាក់មើល បង្ហាញមើលឯកសារ រូបថតនៅឯណាឥឡូវនេះ?

**លោក ឃីត សេយ្យ៍ឆ័រ៖**

ខ្ញុំមិនដឹងចម្លើយដែលលោកប្រធាន ខ្ញុំគិតថាប្រហែលជារូបថតហ្នឹងនៅជាមួយសាក្សី។ ហើយខ្ញុំមិនដឹងថា ក្នុងពេលឥឡូវហ្នឹងនៅសាក្សី ឬក៏អ្នកណាផ្សេងគាត់យកទៅរួចទៅហើយទេ។ ដូច្នេះលោកប្រធានអាចសាកសួរទៅលោកសាក្សី នូ មោក បាន។

**ប្រធានអង្គជំនុំ៖**

លោក ម៉ៅ ដែលរូបថតព្រឹកមិញនៅឯណា?

**លោក នូ ម៉ៅ៖**

នៅខ្ញុំ -- នៅកាសែតខ្ញុំ។

**ប្រធានអង្គជំនុំ៖**

កាសែតរបស់លោកទុកនៅឯណា?

**លោក នូ ម៉ៅ៖**

នៅខាងក្រោម។

**ប្រធានអង្គជំនុំ៖**

លោកសាក្សីលើកបង្ហាញបន្តិចមើល!

*(សាក្សីលើករូបថតបង្ហាញ)*

[១៤:៥៤:១២]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីលោកស្រី សែ កុលវុឌ្ឍី ទទួលយករូបថតដែលសាក្សីលើកបង្ហាញនេះយកមករៀបចំដាក់បញ្ចូលទៅក្នុងសំណុំរឿង។ បានហើយ!

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនមេធាវីការពារក្តីលោក ខៀវ សំផន បាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ស៖** សូមជម្រាបសួរលោក នូ ម៉ៅ ជាសាក្សី។ ខ្ញុំឈ្មោះ សុន អរុណ ខ្ញុំមេធាវីរបស់ការពារលោក នួន ជា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរសាក្សីដូចតទៅនេះ។ លោកកាលពីក្មេង លោករៀនបានដល់ថ្នាក់ណា? កម្មវិធីសិក្សាយើងទូទៅនោះ លោករៀនបានដល់ថ្នាក់ត្រឹមណា?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំនៅវត្ត រៀនអក្សរនៅវត្តទេ។ ខ្ញុំអត់មានថ្នាក់បឋម ថ្នាក់ -- គឺខ្ញុំរៀនតែដីស ក្តាខៀនហ្នឹង --

**ស៖** បានហើយ ខ្ញុំចង់ៗដឹងតែប៉ុណ្ណឹង។

**ឆ៖** បាទ។

**ស៖** ពេលដែលលោកធំដឹងក្តីហើយ លោកចូលក្នុងបដិវត្តន៍នៅឆ្នាំណា?

[១៤:៥៦:២០]

**ឆ៖** ត្រង់ហ្នឹង នៅក្នុងឯកសារ--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ សំណួរច្រំដែលទេបាទ ឆ្លើយរួចហើយ សាក្សីឆ្លើយព្រឹកមិញហើយ។

តសំណួរផ្សេងទៀត!

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរបន្ត។ លោកពេលដែលចូលក្នុងបដិវត្តន៍ហ្នឹងលោកធ្វើជាអ្វី មុនដំបូងធ្វើជាអ្វី? ហើយបន្តបន្ទាប់មកធ្វើជាអ្វី? ហើយសំណួរបន្ទាប់ហ្នឹងទៀត លោកដែលធ្លាប់ធ្វើជាយោធាទេ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំៗដែលចូលខាងបដិវត្តន៍ហ្នឹង ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយសំណួរហ្នឹង។

**ស៖** លោកឆ្លើយអស់ហើយ?

**ឆ៖** បាទ។

[១៤:៥៧:៣៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី គប្បីរៀបចំនូវសំណួររបស់លោកឲ្យបានខ្លីៗទៅ ព្រោះលោកមានបំណងសួរខ្លី ដើម្បីឲ្យឆ្លើយបានខ្លី ប៉ុន្តែសំណួរចុងក្រោយរបស់លោកអំមិញសួរឡូកឡំគ្នា។ ទី១ យ៉ាងច្រើនឲ្យរៀបរាប់អំពីការដែលចូលបដិវត្តន៍ហ្នឹង ធ្វើអ្វីខ្លះតាំងពីដើមទាល់ចប់។ នេះជាការអត្ថាធិប្បាយមួយ។ ហើយទី២ វារឿងខុសគ្នារវាងអាជ្ញាធរស៊ីវិល ហើយនិងទាហាន។ អ៊ីចឹងសំណួរនេះគួរតែត្រូវបានបំបែកខ្លីៗទៅព្រោះវាមានលក្ខណៈដាក់ដោលឡែកពីគ្នា ដើម្បីសាក្សីស្ដាប់បាន។ ព្រោះព្រឹកមិញលោកបាននិយាយហើយថាសាក្សីឆ្លើយច្រើន ហើយដល់ពេលមកសំណួរឥឡូវនេះសួរច្រើន អាចចូលគ្នាប្រភេទសំណួរដែលគួរតែត្រូវបានធ្វើផ្សេងគ្នា ពីព្រោះគាត់ចាស់ហើយ។ អាចទំនងភ្លេច ងាយចងចាំ គឺសួរខ្លី។ អាហ្នឹងងាយជាង។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរលោកសាក្សីម្ដងទៀត។ ថាលោកសាក្សីបានធ្លាប់ធ្វើចូលធ្វើជាកងទ័ពទេ ពេលដែលលោកចូលបដិវត្តន៍នោះ?

[១៤:៥៩:00]

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំអត់បានទេធ្វើទ័ព។ អត់បានចូលធ្វើកងទ័ពទេ។ ពិសេសគឺខ្ញុំបានឋានៈខ្ញុំជាសមាជិកឃុំ។

**ស៖** សូមបញ្ជាក់ម្ដងទៀត លោកធ្វើជាសមាជិកភូមិ ឬសមាជិកឃុំ?

**ឆ៖** សមាជិកនៅភូមិ គេឲ្យក្ដាប់បីភូមិ ស្រះធុល និង ត្រពាំងធំ ត្រពាំងទិន បីភូមិហ្នឹង។ សួរដូចមុនអ៊ីចឹងទៀត។

**ស៖** លោកមិនដែលធ្វើកងទ័ព ប៉ុន្តែពីព្រឹកមិញ លោកបានជម្រាបព្រះរាជអាជ្ញាថាលោកដឹងថាតាម៉ុក ជាមេទ័ព ហើយលោក ជូ ជេត ហៅ ស៊ី ជាមេភូមិភាគ។ ហើយលោកបានជម្រាបតុលាការ

ទៀតទេថា លោកធ្លាប់ចូលទៅសិក្សាជាមួយ តាម៉ុក និងជាមួយ ជូ ជេត។ ខ្ញុំសួរថាលោកបានទៅសិក្សាហ្នឹង គេដែលធ្វើការសិក្សាហ្នឹង គេយកមនុស្សថ្នាក់ណាទៅ ដើម្បីចូលសិក្សាជាមួយ តាម៉ុក ជាមួយនឹង ជូ ជេត នោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ដែលគេហៅទៅសិក្សាហ្នឹង ខ្ញុំជាសមាជិកនៅក្នុងឃុំ ដែលគេចាត់តាំងឲ្យទៅរៀនហ្នឹង។ ដូចខ្ញុំបានរាយការណ៍ពីមុនមក ជូននៅអង្គប្រជុំ។

[១៥:០១:៣៨]

**ស៖** សូមបញ្ជាក់ម្តងទៀត ជាសមាជិកភូមិ? ឬជាសមាជិកឃុំ? ខ្ញុំសួរពីរដងហើយ សូមបញ្ជាក់ម្តងទៀត ចុងក្រោយ។

**លោក ឃីត ឃេយ៉ន័រ៖**

លោកប្រធាន ខ្ញុំគិតថានេះជាការសួរជាន់ដដែលៗពីរបីដងហើយ ហើយខ្ញុំអាចនិយាយថា គឺគណៈភូមិហ្នឹង គឺគ្រប់គ្រងទៅលើភូមិបី។ អានេះគឺថាខ្ញុំអាចឆ្លើយជំនួសបាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយម្តងទៀត បញ្ជាក់ឲ្យច្បាស់លាស់ ព្រោះលោកនិយាយទំនងពិបាកស្តាប់ រវាងពាក្យសមាជិកភូមិ ហើយនិងសមាជិកឃុំ។ តើលោកជាសមាជិកឃុំ? ឬក៏ជាសមាជិកភូមិ?

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំបានបញ្ជាក់រួចហើយថា ជំហានទី១ គេឲ្យខ្ញុំក្តាប់បីភូមិ។ ជាសមាជិកភូមិ ក្រោយទៀតគេហៅខ្ញុំទៅបំពេញនៅក្នុងអង្គភាពឃុំ។ ខ្ញុំជាសមាជិកឃុំបន្តទៀត។ តែប៉ុណ្ណឹង។

**សួរដោយលោក សុន អរុណ៖**

**ស៖** អរគុណ។ សូមអរគុណ។ ពេលដែល តាម៉ុក បើកវគ្គសិក្សា ឬក៏ ជូ ជេត បើកវគ្គសិក្សារាល់ពេលគេអញ្ជើញនឹងលោកសាក្សីទៅរួមសិក្សាជាមួយគេដែរ ឬក៏លោកអត់បានទៅទេ ឮតែគេថា?

[១៥:០៣:៣៤]

**ឆ៖** កន្លែងហ្នឹង ខ្ញុំបានបញ្ជាក់ជូនពីព្រឹករួចហើយ។

**ប្រធានអង្គជំនុំ៖**

សំណួរខុសគ្នាលោកសាក្សី។ ឥឡូវនេះ គេសួរថា តើលោកពិតជាបានទៅចូលរួមរៀនសូត្រ

អ៊ីចឹងមែនដែរទេ? ឬក៏លោកនិយាយហ្នឹង គ្រាន់តែជាការឮគេថាទេ? សំណួរខុសគ្នាពីព្រឹក។ សូមឆ្លើយ!

**លោក នូ ម៉ៅ៖**

**ឆ៖** ខ្ញុំនៅក្នុងនោះ គឺគណៈកម្មការឃុំ -- អ៎! សមាជិកឃុំ ទៅរៀនគ្រប់កម្មាភិបាលទាំងអស់នៅក្នុងតំបន់ស្រុកថ្គង។ មកដូចខ្ញុំបានអធិប្បាយពីខាងដើមដែរ គ្រប់ រៀននៅកន្ទួត។ នៅក្នុងនោះមាន តាស៊ី ហើយនិងអ្នកដទៃទៀត ខ្ញុំភ្លេចអស់ហើយ ហ្នឹងហើយ ខ្ញុំមិនស្គាល់។ ស្គាល់តែ ចាន់ ស៊ី។ ជូ ជេត – ចាន់ ស៊ី ហ្នឹង ហើយនិងក្រោយមក តាម៉ុក គាត់មកចាប់ផ្ដើមពាក់កណ្ដាលការបង្រៀននៅពេលនោះ។ អ៊ីចឹងខ្ញុំបានសិក្សាខាងផ្នែកនយោបាយ។ តាស៊ី គាត់ខាងនយោបាយ, ខាង តាម៉ុក គាត់ខាងយោធា--

[១៥:០៥:៣០]

**ស៖** សូមអរគុណ។ ខ្ញុំសូមអរគុណហើយខ្ញុំចង់ស្ដាប់តែប៉ុណ្ណឹងទេ។ លោកជាសមាជិកភូមិ លោកបានចូលទៅរួមសិក្សាជាមួយនឹង តាម៉ុក ឬក៏ ជូ ជេត សូមលោកបញ្ជាក់ម្ដងទៀតលោក ប្រហែលជាស្គាល់ ជូ ជេត ច្បាស់ ព្រោះអីលោកបានសិក្សាជាមួយ។ ជូ ជេត ហៅ ស៊ី ឬក៏ហៅ ចាន់ ស៊ី សូមបញ្ជាក់ម្ដងទៀត។

**ឆ៖** ជូ ជេត ហៅ ចាន់ ស៊ី ឈ្មោះគាត់។ គាត់ដាក់ឈ្មោះគាត់ ចាន់ ស៊ី។

**ស៖** អរគុណ។ ពេលដែលលោកបានទៅសិក្សាជាមួយអស់លោកថ្នាក់ដឹកនាំធំអ៊ីចឹង លោកដឹងទេថាពេលដែលសិក្សាធ្វើការសិក្សាមានមនុស្សរាប់រយនាក់អ៊ីចឹងគេហៅឋានៈត្រឹមថ្នាក់ណាទៅ? អ្នកទទួលខុសត្រូវត្រឹមថ្នាក់ណាទៅ ទៅសិក្សាជាមួយគ្នាសូមលោកបញ្ជាក់ត្រង់ហ្នឹងបានទេ នៅចាំបានទេ?

**ឆ៖** អ្នកដែលទៅសិក្សានៅកន្ទួតហ្នឹងគឺក្ដាប់តាំងពីថ្នាក់ក្រោម ថ្នាក់ត្រឹមគណៈឃុំ គណៈស្រុក គណៈតំបន់ ចូលរួមទៅការសិក្សារៀនសូត្រនៅក្នុងស្រុកថ្គង។ រៀនចំនួន១ខែជាង។

**ស៖** អរគុណណាស់។ លោកថាត្រឹមថ្នាក់ឃុំ ថ្នាក់ស្រុកអញ្ជើញទៅសិក្សា។ ចុះលោកគ្រាន់ជាសមាជិកភូមិម៉េចក៏គេហៅទៅដែរ?

[១៥:០៨:០៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីស្ដាប់អត់បានទេនេះ! គាត់ឆ្លើយថាគាត់ជាសមាជិកភូមិពីដំបូង ក្រោយមកត្រូវដំឡើងស័ក្ដិទៅជាសមាជិកឃុំ។ សំណួរអំមិញយើងសួរច្បាស់លាស់ហើយ។ សមាជិកឃុំតួនាទីចុង

ក្រោយរបស់គាត់ទៅរៀននេះ។ មិនបាច់ឆ្លើយទេសាក្សី!

**លោក សុន អរុណ៖**

ខ្ញុំនៅតែស្តាប់បានថាគាត់ឆ្លើយម្តងភូមិ ម្តងឃុំ ម្តងឃុំ ម្តងភូមិដដែលគ្មានអីប្រាកដសោះ។

**ប្រធានអង្គជំនុំ៖**

គាត់ឆ្លើយច្បាស់លាស់ណាស់។ ដំបូងគឺសមាជិកភូមិ ហើយក្រោយមកគឺឡើងទៅជាសមាជិកឃុំ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តសំណួរទៅមុខទៀត។

**សួរដោយលោក សុន អរុណ៖**

**ស៖** តាំងពីព្រឹកមកលោកបានឆ្លើយចំពោះព្រះរាជអាជ្ញាពីរឿងចំពោះខ្មែរមកពីនៅហាណូយ និងខ្មែរវៀតមិញ។ លោកអាចបញ្ជាក់បានទេ ខ្មែរទាំងពីរក្រុមនេះខុសគ្នារបៀបម៉េច?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ!

**លោក នូ ម៉ៅ៖**

ត្រង់ហ្នឹងឆ្លើយម្តង។ ខ្មែរយៀកមិញៗ ខ្មែរនៅធ្វើគណៈជាតិមុតគាហាមុននោះ។ អាហ្នឹងគេហៅថា "ខ្មែរយៀកមិញ"។ ដែលគេបញ្ជូនមកហ្នឹងចំនួនមិនដល់ ៣០០០ទេ ដូចខ្ញុំរៀបរាប់ពីខាងដើម។ ចាត់តាំងតាមភូមិនានា អ៎! តាមឃុំនានា ស្រុក តំបន់ យោធា អីចឹងទៅ។

[១៥:១០:២២]

**ប្រធានអង្គជំនុំ៖**

សាក្សីស្តាប់សំណួរឲ្យបាន គេសួរហ្នឹងគេឆ្ងល់ថា តើមានភាពខុសគ្នាយ៉ាងដូចម្តេចរវាងខ្មែរវៀតមិញ ហើយនិងខ្មែរមកពីហាណូយ។ ពាក្យពីរហ្នឹងខុសគ្នាទេ? ហើយបើខុសគ្នា តើមនុស្សប្រភេទណាគេបែងចែកថាជា "ខ្មែរវៀតមិញ" ហើយមនុស្សប្រភេទណាគេហៅថា "ខ្មែរហាណូយ"?

**លោក នូ ម៉ៅ៖**

ខ្មែរហៅថា "ខ្មែរយៀកមិញ"។ កាលពីមុន ខ្មែរហ្នឹងចូលរួមជាមួយបងប្អូនវៀតណាម។ រួចដល់ចប់សង្គ្រាមមុនទៅ គេយកខ្មែរ៣០០០ហ្នឹងទៅសិក្សានៅហាណូយមិនដឹង ខ្ញុំអត់បានដឹងដែរត្រង់ហ្នឹង។

ដល់អ៊ីចឹងបានថា ខ្មែរយៀកមិញហ្នឹង វាតាំងពីជំនាន់គណៈជាតិមុតគាហា ដែលខ្មែរគេឲ្យមកហ្នឹង គឺជាង -- បើគិតជាមនុស្សគេថា៣០០០ ដែលឲ្យមកធ្វើជំនាញការក្នុងយោធានៅក្នុងឃុំ នៅក្នុងតំបន់ នៅក្នុងស្រុកទាំងអស់។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមអរគុណលោកសាក្សី។ សំណួរខ្ញុំមិនឲ្យលោកឆ្លើយវែងប៉ុណ្ណឹងទេ។ ខ្ញុំសូមសួរបន្តទៅទៀត។ លោកអំមិញឆ្លើយថា ខ្មែរវៀតមិញហ្នឹងមានប្រហែល៣០០០ ឲ្យមក។ មកពីណា? ហើយពេលវេលាណា? ប្រហែលជាឆ្នាំណា?

**លោក នូ ម៉ៅ៖**

**ឆ៖** ឆ្នាំណា ពេលណា តែគេត្រូវឲ្យមក កងទ័ព អ៎! អ្នកជំនាញការហ្នឹង ឆ្នាំ-- ខ្ញុំវាភ្លេចបាត់បង់ដែរហើយ មិនចាំទេឆ្នាំ។ ទាល់តែបើុងមើលនៅក្នុងឯកសារហ្នឹងបានដឹង។

[១៥:១៣:៣២]

**លោក សុន អរុណ៖**

លោកប្រធាន ខ្ញុំសូមឈប់សួរសាក្សីនេះ ព្រោះខ្ញុំឃើញគាត់ហាក់ដូចជាអស់កម្លាំង ហេវហត់មិនអាចឆ្លើយត្រូវនឹងសំណួររបស់ខ្ញុំទេ។ ខ្ញុំសូមឈប់ ហើយខ្ញុំប្រគល់ឲ្យសហការីរបស់ខ្ញុំសួរបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ពីព្រឹកមិញនេះ គេសួរលោកនូវសំណួរពាក់ព័ន្ធទៅនឹងមូលហេតុនៅពីខាងក្រោយការធ្វើបដិវត្តន៍។ តើលោកអាចពន្យល់មួយសាទៀតបានដែរឬទេ ហេតុអ្វីបានជាបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងត្រូវបានគេផ្តួចផ្តើមឡើង? ហេតុអ្វីបានគេផ្តួចផ្តើមឡើងនូវបដិវត្តន៍នេះ?

[១៥:១៤:៤០]

*(សម្រាករយៈពេលខ្លី)*

[១៥:១៥:១៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានប្រហែលជាគាត់ពិតជាអស់កម្លាំងមែនហើយមើលទៅ ហើយប្រហែលជាយើងមិនគួរជំរុញគាត់តទៅមុខរហូតដល់ម៉ោងបួននោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ គឺថាខ្ញុំនៅសួរ ខ្ញុំអាចសួរដល់ព្រឹកទៀត។ ដូច្នេះខ្ញុំសូមអនុញ្ញាត--

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំគិតថា លោកប្រធាន ខ្ញុំមើលទៅយល់ស្របជាមួយមេធាវីការពារក្តី ប្រហែលមើលសាក្សីគាត់ហាក់ដូចជាចង់សម្រាន្តលក់បាត់ហើយ ដូច្នេះខ្ញុំគិតថា យើងមិនគួរបង្ខំ -- មិនគួរជំរុញ គាត់ពេកទេ។

**ប្រធានអង្គជំនុំ៖**

លោក ម៉ៅ តើលោកអាចបន្តការឆ្លើយនឹងសំណួរបានទៀតទេនាពេលនេះ ឬក៏លោកត្រូវការសម្រាក?

**លោក នូ ម៉ៅ៖**

សូមបន្តបាន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីអាចបន្តបាន ហើយសូមលោកមេធាវីអាចសម្រួលនូវសំណួររបស់លោក សូម្បីតែយើងជាប្រធានអង្គជំនុំជម្រះក៏លំបាកក្នុងការស្តាប់នៅសំណួររបស់លោកដែរ កម្រិតវាខ្ពស់រហូតដល់ប្រធានអង្គជំនុំជម្រះនឹងក៏ពិបាកស្តាប់ភាសារបស់លោកផង។ អ៊ីចឹងកម្រិតសាក្សីនេះទំនងក៏ជាលំបាកយល់អំពីខ្លឹមសារនៃសំណួររបស់លោកផងដែរ តាមទំនង។

[១៥:១៦:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំនឹងព្យាយាម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីហេតុអ្វីបានជាបដិវត្តន៍ចាប់ផ្តើម? តើមានហេតុផលអ្វីដែលធ្វើឱ្យបក្សកុម្មុយ

នីស្តកម្ពុជាហ្នឹងចាប់ផ្តើមមានបដិវត្តន៍នោះឡើង?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ មើលប្រដាប់ស្តាប់ដូចជានៅក្រៅត្រចៀក ប្រហោងត្រចៀកហើយ ប្រហែលជាទំនងគាត់ស្តាប់មិនឮទេ! ហើយមើលថ្មផង មើលថាមពល – បាតទីរី – ថ្មប្រដាប់សាកផង។

*(សម្រាករយៈពេលខ្លី)*

[១៥:១៨:៣៨]

**ប្រធានអង្គជំនុំ៖**

លោក នូ ម៉ៅ ហើយយើងសួរលោកម្តងទៀត តើលោកអាចទៅរួចទេ យើងមើលសភាពកម្លាំងរបស់លោកហ្នឹងដូចជាមិនមានអារម្មណ៍នឹងការស្តាប់នូវសំណួររបស់ភាគីដែលសួរលោកទេ។ ឥឡូវលោកសូមសម្រាកទេ ដើម្បីយើងអាចបន្តធ្វើសវនាការនៅព្រឹកថ្ងៃស្អែកទៀត ដើម្បីឲ្យឱកាសលោកអាចសម្រាកបាន ហើយស្អែកទំនងតែមួយព្រឹកទេ យើងអាចចប់ហើយ។

**លោក នូ ម៉ៅ៖**

អឺចឹង ខ្ញុំវាដូចជាសុខភាពអត់ស្រួល បាទហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអរគុណលោកមេធាវី លោក កូប៉េ មើលទៅយើងមិនអាចបន្តនៅការសួរដេញដោលចំពោះសាក្សីរូបនេះទៅទៀតបានទេ ដោយសារមូលហេតុយើងមើលសភាព សុខភាពរបស់គាត់អាចមានបញ្ហាសុខភាព។ ទោះបីយ៉ាងណាក៏ដោយលោក ម៉ៅ គឺអង្គជំនុំជម្រះអរគុណចំពោះលោកដែលបានមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ ហើយនិងការប្រឹងប្រែង ប៉ុន្តែសក្ខីកម្មមិនទាន់ចប់នៅឡើយទេណ៎ះ។

បាទ កិច្ចដំណើរការសវនការសម្រាប់ថ្ងៃនេះ ដោយសារមូលហេតុបញ្ហាសាក្សីដែលមានបញ្ហាសុខភាព ដូច្នេះគឺអង្គជំនុំជម្រះសម្រេចសម្រាកត្រឹមនេះ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២០ ខែមិថុនា ឆ្នាំ២០១៣។ ថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី នូ ម៉ៅ ដែលនឹងបន្តសួរដេញដោលដោយដោយសារក្រុមមេធាវីការពារក្តី។ ហើយដែលនឹងសួរដេញដោលមុនគឺដោយមេធាវីបន្តដោយមេធាវីការពារក្តីលោក នួន ជា។ សូមភាគីនៃរឿងក្តី បុគ្គលិកគាំទ្រកិច្ចដំណើរ

ការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

[១៥:២០:៤១]

លោក នូ ម៉ៅ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅព្រឹកថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមកោះហៅលោកមកបន្តផ្តល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក នូ ម៉ៅ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកវេលាម៉ោងប្រាំបួន ហើយលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី សូមអញ្ជើញមកចូលរួមដូចគ្នានឹងសាក្សី នូ ម៉ៅ ដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនគាត់មកចូលរួមនៅក្នុងសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:២២នាទី)*